ជំពូក ៥

ស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោង

EXISTING ENVIRONMENT DESCRIPTIONS

ជំពូកទី ៥

ស្ថានភាពធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោង

ក្នុងជំពូកនេះគឺ ពិពណ៌នាអំពីស្ថានភាពធនធានបរិស្ថាន ដែលមានស្រាប់ (ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធាន សេដ្ឋកិច្ច-សង្គម) ក្នុងតំបន់ទីតាំងគម្រោង ដែលប្រមូលព័ត៌មានបានពីស្ថាប័ន អង្គភាពពាក់ព័ន្ធ រួមទាំងការចុះអង្កេតសិក្សា ស្រាវជ្រាវ ផ្ទាល់ពីមូលដ្ឋាន ដើម្បីបានទិន្នន័យគ្រឹះសម្រាប់ធ្វើការវិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) ដែលកើតឬអាច កើតឡើងពីសកម្មភាពនៃការអនុវត្តគម្រោង។

ការសិក្សាធនធានបរិស្ថាននៅក្នុងតំបន់គម្រោង ៩.៣៥៥ ហ.ត។ ក្រុមការងារ SAWAC បានចែកតំបន់នេះជា៤ គឺៈ តំបន់១ មានផ្ទៃដីសរុប៨.៥៩១ហ.ត គ្របដណ្តប់ទីតាំងទំនប់ផ្នែកខាងលើ និងផ្ទៃអាង, តំបន់២គឺ តំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីផ្សេងៗ ដូចជាផ្លូវចូល អាគារថាមពល ទូនេល កន្លែងធ្វើការកន្លែងដាក់សំរាម វាលដាក់គ្រង់ស្តូរ ជាដើម ។ល។ ដែលមានផ្ទៃដី ៥៥៩,៩១ហ.ត, ទំបន់៣ គឺជាតំបន់តាមគន្លងខ្សែ២៣០គ.វ៉ មានផ្ទៃដី ១៣,៦៤ ហ.ត និង តំបន់៤ គឺកន្លែងសម្រាប់អ្នក ដែលរងផលប៉ះពាល់ដោយសារគម្រោងនេះ រួមមានផ្លូវចូល ស្រះទឹក ដីលំនៅឋាន និងដីកសិកម្មផងដែរមានផ្ទៃ ១៩០,៤៥ ហ.ត ។ ***សម្គាល់:*** *តំបន់៤នេះមិនបានបញ្ចូលតំបន់បំរុង ៥០ ហ.តទៀតទេ។*

៥.១ បរិស្ថានធម្មជាតិ (Natural Environment)

៥.១.១ ធនធានរូបសាស្ត្រ (Physical Resources)

៥.១.១.១ ភូគព្ភសាស្ត្រ លក្ខណៈសណ្ឋានភាពដី/ឋានលេខា និង ប្រភេទដី នៅក្នុងតំបន់គម្រោង

១- សណ្ឋានភាពដី (Topography)

លក្ខណៈភូមិសាស្ត្ររបស់តំបន់គម្រោង គឺស្ថិតនៅក្នុងតំបន់ចន្លោះជួរភ្នំក្រវាញ ដែលតំបន់អាងជាជ្រលងរាង U និងV។ នៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងពោធិ៍សាត់ផ្នែកនេះ មានរយៈកំពស់ចាប់ពី ១៨០ម ទៅដល់ជាង ១០០០ម ធៀបនឹងនីវ៉ូសមុទ្រ ដែលមានភ្នំទាបៗគ្របដណ្តប់ទៅដោយព្រៃទឹកភ្លៀងនៃតំបន់ត្រូពិក (មើលផែនទី៦(គ)ក្នុងឧបសម្ព័ន្ធ៨) ។ ជម្រាលដីជាមធ្យមក្នុងតំបន់គម្រោង គឺ ប្រមាណ ពី ៥ ទៅ១៥ អង្សារ (មិនគិតពោះស្ទឹងពោធិ៍សាត់)មើលផែនទី៦(ឃ) ក្នុងឧបសម្ព័ន្ធ៨។

ចំពោះរយៈកំពស់បាតស្ទឹងពោធិ៍សាត់ក្នុងអាងមានរយៈកំពស់ពី ៦០ម-១០៩ម (គិតចាប់ពីទំនប់ ដល់អាគារថាមពល) ហើយបាតស្ទឹង នេះក្រាលទៅដោយសិលាប្រភេទថ្មខ្សាច់ និងថ្មភក់ (Sand and Mud Stone)។ សិលានៅក្នុងតំបន់អាង ជាប្រភេទ ថ្មខ្សាច់ ថ្មភក់ ថ្មកំបោរ និងថ្មបាសាល ដែលកើតឡើងនៅពាក់កណ្តាលយុគ្គសម័យ Devonian, Jurassic-Cretaceous និង Holocene នៃ Himalayan period។ រយៈកំពស់ នៅក្នុងតំបន់អាងមានចាប់ពី ១៨០ម ទៅ ១៩៥ម (មិនគិតពោះស្ទឹងពោធិ៍សាត់) ដែលមានចំណោទចោទទេរទៅរកស្ទឹងពោធិ៍សាត់បង្កើតជា ជ្រលង U (ទំនាបចំណុចអន្លង់ក្រូច និងអន្លង់ឃុត) និង V (ចោតត្រង់ ចន្លោះភ្នំពង្រុល និងភ្នំសន្តាំង) មានមុខកាត់ប្រមាណចាប់ពី ២៧០ម-៨៣០០ម បង្កលក្ខណៈ ក្នុងការស្តុកទឹកសម្រាប់ អាងនេះ បានច្រើន។

លំហូរធម្មជាតិនៃទឹកភ្លៀងក្នុងផ្ទៃរងទឹកភ្លៀងនៃស្ទឹងពោធិ៍សាត់ មានផ្នែកខាងលើ ហៅថាស្ទឹងឫស្សី និងផ្នែកខាងក្រោម ហៅថាស្ទឹងពោធិ៍សាត់ ដែលគ្របដណ្តប់ទៅដោយ ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ហើយទឹកភ្លៀងហូរចូលនៃស្ទឹងទាំងនេះ។ ដីល្បាប់ ដែលហូរនាំដោយទឹកភ្លៀងតាមស្ទឹងមកដល់កន្លែងក្នុងអាងមានចំនួន០,២៧៨ គ.ក្រ/ម^{៣} និងក្នុងរយៈពេល ១០០ឆ្នាំ ល្បាប់នឹងកករក្នុងអាងឡើងដល់នៅវ៉ូ EL:១១៥,៤ម (ទិន្នន័យបានពីរបាយការណ៍ធ្វើបច្ចុប្បន្នភាព សមិទ្ធលទ្ធភាពគម្រោងឆ្នាំ ២០១៧)។

២- ប្រភេទដី (Soil Type)

តាមផែនទីប្រភេទដីរបស់លោក Crocker ឆ្នាំ១៩៦៣មាត្រដ្ឋាន១/១.០០០.០០០បានបង្ហាញថា តំបន់គម្រោងនេះ ៩.៣៥៥ហ.ត មានដី ២ប្រភេទ ដូចតទៅ: (មើលផែនទី៦(ក)ក្នុងឧបសម្ព័ន្ធ៨)

តំបន់១:

No.	Soils Type	Area (ha)
1	Acid Lithosols	1451.41
2	Red-yellow podzols	7139.59
	Total Area	8591

តំបន់២:

No.	Landuse Type	Area (ha)
1	Acid Lithosols	18.87
2	Red-yellow podzols	541.04
	Total Area	**559.91**

តំបន់៣:

No.	Landuse Type	Area (ha)
1	Acid Lithosols	10.72
2	Red-yellow podzols	2.92
	Total Area	**13.64**

តំបន់៤:

No.	Landuse Type	Area (ha)
1	Acid Lithosols	13.7
2	Red-yellow podzols	176.75
	Total Area	**190.45**

សម្គាល់: *តំបន់នេះមិនបានបញ្ចូលតំបន់បំរុង ៥០ ហ.តទៀតទេ។*

សរុបតំបន់គម្រោងទាំងមូល (តំបន់១+តំបន់២+តំបន់៣+តំបន់៤):

No.	**Soils Type**	**Area (ha)**
1	Acid Lithosols	1494.7
2	Red-yellow podzols	7860.3
	Total Area	**9355**

- ប្រភេទដី Acid Lithosols (1536.38 ha) នៅក្នុងតំបន់គម្រោង គឺជាដីមានគំរបព្រៃឈើ ហើយការពុកផុយ នៃស្លឹកឈើធ្វើឱ្យ ដីនេះជាដីប្រមោគជីវជាតិល្អបង្គួរ ដែលមានល្បាយសារធាតុសរីរាង្គ (កើតពីការពុកផុយនៃ ស្លឹកឈើ ឬសឈើ ដើមឈើ អាចម៍សត្វ។ល។) ដីនេះជាដីខ្សាច់ម៉ដ្ឋពណ៌លឿងព្រឿងៗលាយដីកន្តែង មានពណ៌ឈាមជ្រូកស្រាលទៅប្រផេះ កម្រាស់ ប្រមាណចាប់ពី ៣៥ស.ម.ទៅ៥០ស.ម. កន្លែងខ្លះមានដុំថ្មគ្រែ ថ្មភក់ ទៀតផង។ រុក្ខជាតិភាគច្រើនដែលដុះលើដីនេះ គឺជារុក្ខជាតិប្រភេទព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ ជាអន្លើដោយតាមកន្លែង។

- ប្រភេទដី **Red-yellow podzols** (7818.62 ha) នៅក្នុងតំបន់គម្រោងគឺជាដី ដែលមានព្រៃដុះជាអន្លើៗ ហើយមានជីជាតិមធ្យម ព្រោះដីនេះមានល្បាយខ្សាច់លាយកណ្តេងក្រមៅច្រើន។ ដីស្រទាប់លើកម្រាស់ ៣៥ស.ម.ទៅ៥៥ស.ម ជាដីល្បាយខ្សាច់ កណ្តេង មានពណ៌ត្នោត ទៅប្រផេះ នៅកន្លែងខ្លះមានល្បាយ ដុំថ្ម និងផ្ទាំងថ្ម ទៀតផង។ នៅលើដីនេះភាគច្រើនមានគម្រប ព្រៃឈើ ប្រភេទព្រៃល្បោះ និង ពាក់កណ្តាលស្រោងនៅតាមដងអូរ។

ចំណុចទីតាំង សិក្សា X = 310916, Y = 1359190
(datum WGS 84)
ដីប្រភេទ Acid Lithosols នៅក្នុងតំបន់គម្រោង
រូបថតនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០១២



ចំណុចទីតាំង សិក្សា X = 309850, Y = 1361950
(datum WGS 84)
ដីប្រភេទ **Red-yellow podzols** នៅក្នុងតំបន់គម្រោង
រូបថតនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២

៣- **ភូគព្ភសាស្ត្រ** (Geology)

ផ្នែកខាងលើនៃផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងពោធិ៍សាត់ គឺគ្របដណ្តប់ជាមួយស្ទឹងឬស្សីផងដែរ។ នៅក្នុងអាងរងទឹកភ្លៀងនេះ គឺជាតំបន់ខ្ពង់រាប និងតំបន់ភ្នំលាតសន្ធឹងតាមជួរភ្នំសំកុស និងជួរភ្នំក្រវាញមានសណ្ឋាន II_2 រវាង Mawlamyine Grade IV នៃ ទំនាបភ្នំពេញ និង Mesozoic sag LL_2 $^{4-2}$ Grade III នៃខេត្តពោធិ៍សាត់។ ចំពោះ លក្ខណៈ ភូគព្ភសាស្ត្រគឺមានថ្ម ដែលកើតឡើងពីល្បាប់ (sedimentary rock) ដូចជាថ្មភក់ ថ្មខ្សាច់ ក្នុងយុគ្គ Jurassic-Cretaceous និងថ្មកើតឡើង Quaternary unconsolidate sediment ក្នុងយុគ្គ Devonian ដូចជាថ្ម black schist, phtamite និង sandstone ជាដើម។ ជាងនេះទៅទៀត សកម្មភាពភ្នំភ្លើង បានបង្កើតកំអែលភ្នំភ្លើង Magmatic ជាមួយនឹងការហូរគ្របដណ្តប់ទៅលើសណ្ឋានដី Variscan នៃសម័យកកើត Indosinian-Yanshanian ក្នុងយុគ្គ Holocen បង្កើតបានជាសិលាបាសាល ថ្មភក់ និង ថ្មខ្សាច់នៃតំបន់ទាំងនោះ មើលនិមិតសញ្ញាខាងក្រោម។ (មើលផែនទី៦(ខ)ក្នុងឧបសម្ព័ន្ធ៨)

ក. លក្ខណៈស្រទាប់ដី និង ថ្ម

លក្ខណៈស្រទាប់ដី និងថ្មនៅក្នុង និងក្បែរតំបន់គម្រោងគេឃើញមានផ្ទាំងថ្មធំៗ ដែលផ្សំពីពពួកថ្មខ្សាច់ (JCg) ថ្មភក់ (JCa) ដែលកើតតាំងពីពាក់កណ្តាលស័កទី៤ Cenozonic Quaternary, Mesozic និង Palezozic មក។ យោងតាមការសិក្សា របស់ក្រុមហ៊ុនកូរ៉េ HEC ឆ្នាំ២០១២ បានបង្ហាញឱ្យ ឃើញថាៈ សណ្ឋានដី និងស្រទាប់ដីក្នុងតំបន់គម្រោងមានលក្ខណៈ សមស្របសម្រាប់សំណង់នេះ។ ភាគច្រើនដីស្រទាប់លើនៃទីតាំងទំនប់ គឺមានល្បាយដីល្បាប់ ដែលកើតឡើងដោយសារលំហូរទឹកភ្លៀង និងកំណកដី (តាងដោយQ^{col+dl}) នៃស័កទី៤ សព្វថ្ងៃមានគម្រប ព្រៃដុះពីលើ ហើយមានជម្រាលដីជាមធ្យម ក្នុងតំបន់គម្រោងគឺ ៥ ទៅ ៣០អង្សា។ ថ្មបាតស្ទឹង នៅទីតាំងទំនប់ គឺរួមមានប្រភេទថ្មភក់ (JCa) និងថ្មខ្សាច់ (JCg) ដែលស្ថិតនៅពាក់កណ្តាលនៃសម័យហ្សូរ៉ាសិក (Jurassic)។ ផ្អែកតាមលទ្ធផល នៃការខួងដីអង្កេតរបស់ ក្រុមហ៊ុនកូរ៉េ HEC គេអាចចែកស្រទាប់ដីជាបួនស្រទាប់គឺ (ចាប់រាប់ពី ក្រោមមកលើ)ៈ ស្រទាប់ទី១ គឺថ្មភក់ស្អិតភ្ជាប់ (JCa),ស្រទាប់ទី២ គឺថ្មខ្សាច់ល្អិត(JCg), ស្រទាប់ទី៣ គឺជាថ្មភក់ជាមួយ ថ្មខ្សាច់ល្អិត និងមានស្រទាប់ដី ហើយនិងស្រទាប់ទី៤ គឺស្រទាប់លើនៃបាតស្ទឹងមានថ្មខ្សាច់ល្អិតជាមួយល្បាប់ភក់ និងមានកំណកដី។ ដូច្នេះគុណភាពថ្មនេះល្អ មធ្យម សម្រាប់គ្រឹះសំណង់នេះ។ (លក្ខណៈស្រទាប់ដី និងថ្មមើលរូបប្រអប់ខួងដីខាងក្រោម)

យោងទៅតាម ការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ឆ្នាំ២០១២ ដែលសិក្សាដោយក្រុមហ៊ុន HEC កម្លាំងរញ្ជួយដីនៅប្រទេសកម្ពុជា គឺមានល្បឿនសីស្មិក (Seismic Velocity) ចន្លោះពី250 ទៅ 1200m/s ដូចនេះការគ្រោងគម្រោងបានគ្រោងកម្រិតរញ្ជួយដីប្រភេទ IV ដែលអាចទប់និងការរញ្ជួយដី កម្រិត៤-៤,៩ រិចទ័រ។

ខ. លក្ខណៈវារីភូគព្ភសាស្ត្រ

ស្រទាប់ថ្មនៅទីតាំងទំនប់មានលក្ខណៈស្នាមប្រេះ ដែលចែកចេញជាបីផ្នែកគឺៈ ស្នាមប្រេះគងប្រទាក់លើគ្នា (កាត់គ្នា) ស្នាមប្រេះ ទេទៅរកទិសឦសាន (Northeast structural fissure) និងស្រទាប់ស្នាមប្រេះ បែរទៅ ទិសពាយ័ព្យ (Northwest structural fissure)។ ស្នាមប្រេះទាំងនេះគឺលទ្ធផលនៃបំណាក់ស្រុត ដោយសារការសង្កត់នៅផ្នែក សងខាងទំរង់នៃថ្មភក់ ដែលផុយ ជាងគេក្នុងយុគ្គសម័យ Himalayan។ ស្នាមប្រេះនៃស្រទាប់ថ្មទាំងនេះបង្កើតបានជា ស្រទាប់ទឹក



ក្រោមដី (Aquifer) ដែលមានប្រភពពីទឹកភ្លៀង។ ដូចបានរៀបរាប់ក្នុងចំណុច១. ២.និង៣ ខាងលើស្រទាប់ ទឹកក្រោមដីនៅក្នុងតំបន់គម្រោងមាន២ស្រទាប់ ដែលស្រទាប់លើជាស្រទាប់ទឹកក្រោមដីមិនខ្ចប់ហូរចាក់ចូលទៅក្នុងស្ទឹង តាមរយៈស្នាមប្រេះនៃសិលាបាតស្ទឹងទឹកនេះ ជ្រាបទៅតំបន់ខាងក្រោម បង្កើតបានជាស្រទាប់ទឹកក្រោមដីខ្ចប់ ដែលមានសម្ពាធ។



៤- រ៉ែ (Mine)

ផ្អែកលើការសិក្សា ក្នុងតំបន់សាងសង់ទំនប់ រួមទាំងការសាងសង់ទូនែលជារន្ធបំពង់ក្រោមដី និងតំបន់ហេដ្ឋារចនាសម្ព័ន្ធគម្រោង ឱ្យដឹងថា មានក្រុមហ៊ុនសិក្សាស្រាវជ្រាវរ៉ែ ២ គឺ ក្រុមហ៊ុនចិន Northern Mining Co.,Ltd (កំពុងសិក្សាស្រាវជ្រាវ) និង ក្រុមហ៊ុនវៀតណាម Southern Mining Co.,Ltd (ផ្អាកសិក្សាស្រាវជ្រាវ)។ ជាងនេះទៅទៀត ក្នុងតំបន់គម្រោង មានកន្លែងយកថ្មសម្រាប់ សាងសង់គម្រោង និងមានគ្រួសបាយក្រៀម ខាងក្នុងតំបន់ហេដ្ឋរចនាសម្ព័ន្ធទំនប់វារីអគ្គិសនី ជាពិសេស នៅតាមផ្លូវចូលទៅតំបន់គម្រោង មានគ្រួសបាយក្រៀម ជាដីល្បាយដែកអុកស៊ីតលាយថ្មគ្រែ ថ្មខ្សាច់តូចៗ សម្រាប់សាងសង់ផ្លូវ គ្រួសក្រហមបានផងដែរ។

តារាង ៥-១: ចំណុចយាមកា ក្រុមហ៊ុនសិក្សារ៉ែ ក្នុង/និងជុំវិញតំបន់គម្រោង

ល.រ	ប្រភេទនៃធនធានរ៉ែ	សន្ទស្សរ៉ែ	ចំណុចយាមការបស់ទីតាំងសិក្សា	ទំហំក្នុងតំបន់គម្រោង (ហត.)	ឈ្មោះក្រុមហ៊ុន
១	Antimomy (Sb)	វិជ្ជមាន	A: X = 302000, Y = 1370000 B: X = 308000, Y = 1370000 C: X = 308000, Y = 1365000 D: X =302000, Y = 1365000	139.36	Southern Mining Co.,Ltd (Viet Name). Total Area 3000 ha
២	Chromium (Cr)	វិជ្ជមាន			
៣	Uranium (U)	វិជ្ជមាន	A: X = 318000, Y = 1364000 B: X = 308000, Y = 1364000 C: X = 308000, Y = 1376000 D: X =318000, Y = 1376000	1123.75	Northern Mining Co.,Ltd (China). Total Area 12000 ha
៤	Nickel (Ni)	វិជ្ជមាន			

__សម្គាល់:__ A,B,C,D ចំណុចព្រំប្រទល់ដែលក្រុមហ៊ុនត្រូវសិក្សា, Datum: Indian 1960 ។ ក្នុងតំបន់សិក្សារបស់ក្រុមហ៊ុនទាំងនេះក៏មានការប្រើ ប្រាស់ដីរបស់ប្រជាពលរដ្ឋផងដែរ។

នាថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១២ ក្រុមការងារ SAWAC បានជួបប្រឹក្សាយោបល់ជាមួយតំណាងក្រុមហ៊ុនចិន Northern Mining Co.,Ltd លោក **ឆាវ កៃហ្វូ** អ្នកគ្រប់គ្រងទូទៅ, លោក **អ៊ីវ ស៊ី** ជាអ្នកបច្ចេកទេស និងលោក **ប៊ុន ហាក់** អ្នកបកប្រែ ដែលកំពុងសិក្សាស្រាវជ្រាវរ៉ែ ហើយគេបានគាំទ្រគម្រោងវារីអគ្គិសនីនេះ ទោះបីជាមានតំបន់ មួយចំនួននឹងត្រូវលិច

ក៏ដោយ ពីព្រោះ បើក្រុមហ៊ុនបើកធ្វើអាជីវកម្មគេបានភ្លើងប្រើ មិនចាំបាច់ប្រើម៉ាស៊ីនភ្លើង អស់សោហ៊ុយច្រើន។ ប៉ុន្តែឆ្នាំ ២០១៥ នេះ ក្រុមហ៊ុនទាំងនោះបានដកទីតាំងការិយាល័យចេញពីកន្លែងនោះអស់ហើយ។

ប្រភេទសិលានៅបាតស្ទឹងពោធិ៍សាត់ខាងលើទីតាំងទំនប់នៃតំបន់គម្រោងវារីអគ្គិសនីស្ទឹង
ពោធិ៍សាត់១។

មុខកាត់ស្ទឹងពោធិ៍សាត់ មានរាងជា អក្សរ U នៅខាងលើទីតាំងទំនប់ទំនាប ចំណុចអន្លង់ ក្រូច។ (មើលទៅតាមបញ្ជស់ខ្សែទឹកហូរ)

មុខកាត់ស្ទឹងពោធិ៍សាត់ មានរាងជា អក្សរ V នៅខាងលើទីតាំងទំនប់ ចំងាយ ប្រមាណ ៣០០ម ។ (មើលទៅតាមខ្សែទឹកហូរ)

៥.១.១.២ *អាកាសធាតុ* (Climate)

១- **របបទឹកភ្លៀង** (Rainfall)

យោងតាមប្រសាសន៍របស់ លោកស្រី លេខារបស់ប្រធាននាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម បានឱ្យដឹងថា នៅក្នុងតំបន់គម្រោងគ្មានការកត់ត្រាទិន្នន័យទឹកភ្លៀងឡើយ មានតែស្ថានីយ នៅក្នុងខេត្តពោធិ៍សាត់ប៉ុណ្ណោះ (ចំងាយ ៩៥គ.ម ពីតំបន់គម្រោង) ដែលបានកត់ត្រា។

ទិន្នន័យនៅស្ថានីយពោធិ៍សាត់បង្ហាញថា ទឹកភ្លៀងឆ្នាំ២០០០-២០០១ គឺបានពីនាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម។ ចំពោះទិន្នន័យ ឆ្នាំ ២០០២-២០១២ បានពីមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់។ តាមតារាងខាងក្រោម បានបង្ហាញថា បរិមាណទឹកភ្លៀងធ្លាក់នៅក្នុង ខេត្តពោធិ៍សាត់ គិតជាមធ្យមរយៈពេល១៣ឆ្នាំ ពីឆ្នាំ ២០០០ ដល់ ២០១២ គឺ ១៣៦៤,៩មម (Return Period 13years)។ ចំណែកឯ កំពស់ទឹកភ្លៀង ជាមធ្យមប្រចាំឆ្នាំខ្ពស់បំផុតរយៈពេល ១៣ឆ្នាំ គឺ នៅខែតុលា ឆ្នាំ ២០០៣ មានដល់ **៥៥៨,៦ មម.**។ (មើលតារាង ៥-២ ខាងក្រោម)

តារាង ៥-២: បរិមាណទឹកភ្លៀង គិតជា ម.ម ក្នុងរយៈពេល ១២ឆ្នាំ (២០០០-២០១២)

Monthly	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Yearly Total
Yearly	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
2000	2.5	6.9	36.0	182.4	285.8	214.9	153.6	237.1	146.9	411.5	37.5	25.3	1740.4
2001	4.8	0.0	214.1	25.4	143.6	134.3	77.2	260.5	212.0	171.9	31.0	22.0	1296.8
2002	0.0	0.0	31.5	208.6	82.7	102.0	65.7	316.3	198.0	253.2	139.3	11.6	1408.9
2003	0.0	2.0	247.2	13.0	98.2	206.0	237.6	43.0	203.0	454.6	75.6	2.4	1582.6
2004	2.0	9.8	48.4	65.5	175.8	148.8	233.4	105.3	257.6	101.2	26.4	0.0	1174.2
2005	0.0	0.0	42.8	99.8	170.1	164.7	113.6	190.6	309.5	154.0	74.2	4.5	1323.8
2006	0.0	6.5	88.5	101.8	89.7	180.2	120.0	329.0	199.8	191.7	3.7	82.4	1393.3
2007	0.0	0.3	88.2	122.8	264.5	208.7	83.0	181.9	234.7	199.6	111.8	0.0	1495.5
2008	13.5	7.0	77.0	171.7	226.8	168.0	188.8	361.2	210.1	305.9	224.2	8.0	1962.2
2009	3.6	28.4	56.2	135.0	135.1	127.9	146.7	162.9	175.2	140.1	44.7	0.0	1155.8
2010	6.4	26.7	49.6	92.8	86.9	202.5	197.3	241.6	167.6	286.0	42.6	30.3	1430.3
2011	73.2	71.4	70.4	76.5	77.6	79.0	80.2	83.6	84.2	83.9	78.4	78.7	937.0
2012	79.0	80.0	70.0	65.0	68.6	72.0	75.0	85.0	89.0	90.0	88.0	85.0	946.6
Monthly Mean	14.2	18.4	86.1	104.6	146.6	154.5	136.3	199.8	191.4	218.7	75.2	26.9	1372.9
Max	79.0	80.0	247.2	208.6	285.8	214.9	237.6	361.2	309.5	454.6	224.2	85.0	2787.6
Min	0.0	0.0	31.5	13.0	68.6	72.0	65.7	43.0	84.2	83.9	3.7	0.0	465.5

ប្រភពទិន្នន័យពី នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម, និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់



Isohyetal Map around the Project Basin (in mm)



ប្រភពទិន្នន័យ: ក្រុមហ៊ុន HEC ឆ្នាំ ២០១២

២- សីតុណ្ហភាព (Temperature)

ដូចគ្នានិងទឹកភ្លៀងដែរគ្មានទិន្នន័យក្នុងតំបន់គម្រោងទេ យោងតាមប្រភពទិន្នន័យរបស់នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម, និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ បានកត់ត្រានៅស្ថានីយ ខេត្តពោធិ៍សាត់គឺ:

- មធ្យមភាគនៃសីតុណ្ហភាពអតិបរមារយ:ពេល ១ឆ្នាំ មានកម្រិត ៣៣,៧ °C
- មធ្យមភាគនៃសីតុណ្ហភាពអប្បបរមារយ:ពេល ១ឆ្នាំ មានកម្រិត ២៣,២ °C
- មធ្យមភាគនៃសីតុណ្ហភាពរយ:ពេល ១ឆ្នាំ មានកម្រិត ២៨,៤៥ °C
- សីតុណ្ហភាពអតិបរមារយ:ពេល ១៣ឆ្នាំ ខ្ពស់បំផុតមានកម្រិត ៣៩,៨ °C នៅឆ្នាំ ២០១០
- សីតុណ្ហភាពអប្បបរមារយ:ពេល ១៣ឆ្នាំ ទាបបំផុតមានកម្រិត ១៧,០ °C នៅឆ្នាំ ២០១១

តារាង ៥- ៣: សីតុណ្ហភាពអតិបរមាប្រចាំ ខែ គិតជា oC ក្នុងរយៈពេល១៣ឆ្នាំ (២០០០-២០១២)

Month Year	Jan I	Feb II	Mar III	Apr IV	May V	Jun VI	Jul VII	Aug VIII	Sep IX	Oct X	Nov XI	Dec XII	Yeraly Mean
2000	31.3	33.1	35.1	34.1	34.3	33.1	33.0	33.0	31.9	30.1	29.9	30.5	**32.5**
2001	31.8	33.6	33.8	35.9	34.9	34.1	33.9	33.3	32.4	31.3	29.1	30.4	**32.9**
2002	31.3	33.3	35.4	35.7	35.4	35.2	36.1	33.3	32.7	32.1	31.3	31.7	**33.6**
2003	31.2	33.5	34.0	35.4	35.6	35.2	33.6	34.5	33.2	31.3	31.7	29.7	**33.2**
2004	31.8	33.2	36.2	37.1	NA	NA	NA	NA	NA	NA	NA	NA	**34.6**
2005	35.4	35.7	35.1	36.5	36.3	35.2	32.7	33.8	32.1	31.8	31.4	29.7	**33.8**
2006	32.6	34.2	35.8	34.5	34.3	34.7	33.8	32.9	32.1	31.8	32.6	31.0	**33.4**
2007	31.8	33.9	35.6	35.6	33.8	34.3	33.3	33.0	32.7	31.2	29.5	31.3	**33.0**
2008	31.6	32.0	34.6	34.8	33.8	33.3	33.8	32.7	32.1	31.5	29.8	29.7	**32.5**
2009	29.8	33.7	34.5	35.1	33.9	35.0	33.2	33.6	31.9	31.3	30.9	31.7	**32.9**
2010	34.8	37.5	39.0	39.8	39.5	37.3	35.1	34.3	34.5	33.3	32.8	33.5	**36.0**
2011	32.8	35.0	36.5	37.5	36.5	35.1	34.7	35.3	37.5	33.7	33.6	33.6	**35.2**
2012	34.9	36.1	37.1	38.5	37.0	36.5	35.5	37.0	34.3	35.0	34.5	35.1	**36.0**
Monthly Total	**421.1**	**444.8**	**462.7**	**470.5**	**425.3**	**419.0**	**408.7**	**406.7**	**397.4**	**384.4**	**377.1**	**377.9**	**416.3**
Monthly Mean	**32.4**	**34.2**	**35.6**	**36.2**	**35.4**	**34.9**	**34.1**	**33.9**	**33.1**	**32.0**	**31.4**	**31.5**	33.7
Max	**35.4**	**37.5**	**39.0**	39.8	**39.5**	**37.3**	**36.1**	**37.0**	**37.5**	**35.0**	**34.5**	**35.1**	**37.0**

ប្រភពទិន្នន័យពីនាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម, និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់

តារាង ៥- ៤: សីតុណ្ហភាពអប្បបរមាប្រចាំ ខែ គិតជា oC ក្នុងរយៈពេល១៣ឆ្នាំ (២០០០-២០១២)

Month Year	Jan I	Feb II	Mar III	Apr IV	May V	Jun VI	Jul VII	Aug VIII	Sep IX	Oct X	Nov XI	Dec XII	Yeraly Mean
2000	22.1	21.4	24.3	24.8	25.2	25.0	24.5	24.7	24.3	24.1	22.6	22.8	**23.8**
2001	22.5	22.0	24.1	25.9	25.2	25.2	24.5	24.9	24.3	24.5	21`.7	21.1	**24.0**
2002	19.5	21.3	23.8	24.5	24.7	24.7	24.6	23.8	24.1	23.5	23.3	23.0	**23.4**
2003	19.3	22.0	23.6	24.9	25.1	24.3	24.1	24.4	23.9	23.6	22.4	19.5	**23.1**
2004	20.6	21.2	24.1	24.7	NA	NA	NA	NA	NA	NA	NA	NA	**22.7**
2005	23.2	23.3	24.0	25.6	25.9	25.5	24.5	24.7	24.4	24.3	23.6	21.9	**24.2**
2006	21.9	23.3	24.3	24.8	24.9	24.8	25.2	24.4	24.5	24.0	23.5	20.9	**23.9**
2007	21.5	20.8	24.3	25.0	25.0	25.2	24.9	24.4	24.3	23.8	21.8	21.7	**23.6**
2008	21.2	22.1	23.8	24.9	25.1	25.1	25.0	24.6	24.6	24.0	23.2	20.8	**23.7**
2009	18.8	22.1	24.0	24.6	25.0	24.6	24.6	24.5	24.1	23.8	22.1	20.5	**23.2**
2010	20.7	22.7	23.7	24.8	25.3	24.1	23.8	24.4	25.5	24.7	24.1	22.4	**23.9**
2011	17.0	18.8	17.8	22.0	23.5	22.3	21.5	23.2	22.7	21.6	21.6	17.3	**20.8**
2012	20.3	20.9	21.2	21.1	20.4	22.6	22.6	22.6	22.7	20.4	21.0	19.3	**21.3**
Monthly Total	**268.6**	**281.9**	**303.0**	**317.6**	**295.3**	**293.4**	**289.8**	**290.6**	**289.4**	**282.3**	**249.2**	**251.2**	**284.4**
Monthly Mean	**20.7**	**21.7**	**23.3**	**24.4**	**24.6**	**24.5**	**24.2**	**24.2**	**24.1**	**23.5**	**22.7**	**20.9**	23.2
Min	17.0	**18.8**	**17.8**	**21.1**	**20.4**	**22.3**	**21.5**	**22.6**	**22.7**	**20.4**	**21.0**	**17.3**	**20.2**

ប្រភពទិន្នន័យពីនាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម, និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់

៣- ល្បឿន និងទិសដៅខ្យល់ (Wind Speed and Wind Direction)

យោងតាមទិន្នន័យល្បឿន និងទិសដៅខ្យល់ ដែលបានពីក្រុមហ៊ុន Hyundai Engineering Co., LTD បានបង្ហាញថា ល្បឿនខ្យល់បក់ជាមធ្យមក្នុងរយៈពេល១៥ឆ្នាំ គឺ៤,០ម/វិនាទី ហើយល្បឿនខ្យល់ ដែលបក់ខ្លាំងជាងគេ នៅខែមីនា, កក្កដា, សីហា និងវិច្ឆិកា នៃឆ្នាំ១៩៨៦ និងខែកញ្ញា ឆ្នាំ ១៩៨៧ ដែលមានល្បឿនជាមធ្យម ៧ម/វិនាទី។ ជាទូទៅក្នុងខេត្តពោធិ៍សាត់ នៅរដូវប្រាំង ខ្យល់បក់ប្រែប្រួលពីទិស បូព៌ា ឦសាន និងនិរតី។ ចំណែកឯ នៅរដូវវស្សាវិញខ្យល់បក់ពីទិសនិរតី ដែលនាំមក នូវទឹកភ្លៀង ហើយចុងរដូវប្រែប្រួលពីទិសឦសាន និងបូព៌ា ដែលឈានទៅរករដូវប្រាំងវិញ (មើលតារាង ៥-៥ ខាងក្រោម)។

តារាង ៥- ៥: ល្បឿន និងទិសដៅខ្យល់ជាមធ្យមប្រចាំខែ ក្នុងរយៈពេល១២ឆ្នាំ (១៩៨៨-១៩៩៩)

Month	Jan		Feb		Mar		Apr		May		Jun		Jul		Aug		Sep		Oct		Nov		Dec	
Year	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd
1988	4.9	E / NE	5.7	E / NE	5.7	NE / S	6.0	E / SW	4.5	S / SW	5.1	S / SW	5.8	SW / NW	4.8	SW / NW	4.4	SW / S	5.3	SW / N	3.9	N / NE	4.2	E / NE
1989	5.8	E / NE	3.7	E / NE	3.8	E / NE	3.3	SW / E	3.7	SE / SW	3.5	SW / NW	3.7	SW / NW	3.6	SW / NW	3.6	SW / W	3.4	N / NW	3.3	NE / ENE	3.6	NE / ENE
1990	3.1	E / NE	4.4	NE / ENE	3.4	NE / ENE	3.8	SW / NE	3.3	SW / SE	4.3	SW / W	3.3	SW / W	4.1	SW / NW	2.8	SW / S	3.6	SW / NE	3.6	E / NE	3.9	E / NE
1991	5.2	E / NE	5.3	E / NE	4.5	E / NE	4.0	NE / SW	3.8	NE / SW	5.0	SW / W	4.3	SW / W	4.1	SW / W	3.3	W / NW	3.1	SW / NE	3.4	E / NE	5.0	E / NE

Month	Jan		Feb		Mar		Apr		May		Jun		Jul		Aug		Sep		Oct		Nov		Dec	
Year	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd
1992	4.7	E / NE	5.0	NE / E	4.7	NE / NNE	4.5	SW / SE	4.7	S / SW	3.8	SW / W	3.3	W / SW	4.3	W / SW	3.2	SW / W	3.1	SW / NE	3.5	E / NE	4.2	E / NE
1993	4.0	E / NE	3.7	E / NE	4.3	E / SE	3.1	E / SE	3.7	SW / SE	4.2	SW / W	5.2	SW	4.9	SW / W	4.0	SW / W	3.9	SW / SE	3.7	E / NE	3.4	NE / SW
1994	3.9	E / NE	3.5	E / NE	3.8	E / NE	3.5	SW / E	4.2	SW / E	4.3	SW / W	4.6	SW / W	4.0	SW / W	3.6	SW / W	3.5	NE / NW	4.5	E / NE	4.4	E / NE
1995	5.0	E / NE	4.8	E / NE	4.2	NE / SE	3.4	ENE / SW	4.1	E / S	3.6	SW / W	3.7	SW / W	3.5	SW / S	3.5	S / W	3.5	NE / SW	3.3	E / NE	2.4	NE / W
1996	5.0	E / NE	4.0	E / NE	5.0	E / SE	5.0	SW / S	5.0	SE / SW	5.0	SE / SW	7.0	SW / S	7.0	SE / SW	5.0	SW / S	4.0	SW / SE	7.0	SW / NE	4.0	SW / W
1997	4.0	E / NE	4.0	E / NE	7.0	E / SW	6.0	NE / SW	5.0	SW / W	5.0	SW / W	4.0	SW / S	5.0	SW / E	5.0	SW / S	5.0	SW / E	7.0	E / NE	5.0	E / NE
1998	4.0	E / NE	6.0	E / NE	5.0	E / NE	5.0	NE / SE	6.0	NE / SW	6.0	S / SE	3.0	SE / E	3.0	S / SW	4.0	SW / S	4.0	SW / S	4.0	NE / W	4.0	NE / W
1999	4.0	E / NE	4.0	E / NE	3.0	E / NE	3.0	E / S	4.0	SE / SW	4.0	NW / SW	2.0	SE / SW	3.0	SW / W	4.0	SW / E	4.0	SW / E	3.0	N / SW	4.0	N / W
Aver.	4.5		4.5		4.5		4.2		4.3		4.5		4.2		4.3		3.9		3.9		4.2		4.0	
Max	5.8		6.0		7.0		6.0		6.0		6.0		7.0		7.0		5.0		5.3		7.0		5.0	
Min	3.1		3.5		3.0		3.0		3.3		3.5		2.0		3.0		2.8		3.1		3.0		2.4	

ប្រភពទិន្នន័យពី ការសិក្សាសមិទ្ធលទ្ធភាពដំបូង គម្រោង(ឆ្នាំ២០១០) របស់ ក្រុមហ៊ុន Hyundai Engineering Co., LTD

៤-សំណើមបរិយាកាស (Humidity)

យោងតាមប្រភពទិន្នន័យរបស់នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម បានបង្ហាញថា សំណើមបរិយាកាស ប្រចាំឆ្នាំដែលខ្ពស់បំផុត គឺ **៩៨%** នៅខែកញ្ញា និងខែតុលា ឆ្នាំ ២០០៧។ សំណើមបរិយាកាស ជាមធ្យមប្រចាំឆ្នាំ គិតក្នុងរយៈ ពេល១៣ឆ្នាំ គឺ **៨១,០%**។ (មើលតារាង ៥-៦ ខាងក្រោម)

តារាង ៥- ៦: សំណើមបរិយាកាស ក្នុងរយៈពេល១០ឆ្នាំ (២០០១-២០១២)

Month	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Yearly Mean
Years	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
2001	78	76	78	76	80	80	82	86	84	85		81	81
2002	93	88	86	90	91	92	89	94	95	95	95	95	92
2003	92	88	91	89	90	91	92	91	94	95	95	93	92
2004	57	60	48	55	51	64	64	72	72	66	71	65	62
2005	78	73	77	84	83	84	84	89	91	90	85	85	84
2006	71	59	68	76	72	70	74	78	83	82	71	78	74
2007	83	86	92	95	93	95	96	96	98	98	91	93	93
2008	84	81	78	84	90	88	87	89	89	91	88	85	86
2009	73	70	64	77	84	78	75	80	82	83	77	81	77
2010	69	68	59	69	71	78	81	83	84	82	76	73	74
2011	73.2	71.4	70.4	76.5	77.6	79.0	80.2	83.6	84.2	83.9	78.4	78.7	78
2012	79.0	80.0	70.0	65.0	68.6	72.0	75.0	85.0	89.0	90.0	88.0	85.0	79
Monthly Mean	78	75	73	78	79	81	82	86	87	87	83	83	81
Max	93	88	92	95	93	95	96	96	98	98	95	95	95
Min	57	59	48	55	51	64	64	72	72	66	71	65	62

ប្រភពទិន្នន័យពី នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម (ឆ្នាំ២០១២)



៥- រំហួត (Evaporation)

យោងតាមទិន្នន័យរបស់មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ បានបង្ហាញថា បរិមាណរំហួត មធ្យមប្រចាំឆ្នាំនៃ រយៈពេល៥ឆ្នាំមាន **១៨៣០,១៨មម** (មើលតារាង ៥-៧ ខាងក្រោម):

តារាង ៥-៧: បរិមាណរំហួតប្រចាំឆ្នាំ (គតជា មម)

Month	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Yearly Total
Years	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
2005	122.50	135.00	155.70	140.40	131.60	123.00	95.20	108.30	83.20	96.90	89.70	90.40	**1371.90**
2006	112.40	131.20	143.40	125.30	123.30	112.50	108.70	99.30	88.50	96.80	93.30	101.40	**1336.10**
2007	114.70	115.80	143.30	141.70	108.80	129.90	109.90	103.00	108.00	95.40	90.60	130.40	**1391.50**
2008	130.40	148.60	188.40	136.40	127.70	134.00	141.30	133.10	141.40	115.30	108.30	116.30	**1621.20**
Monthly Total	**480.00**	**530.60**	**630.80**	**543.80**	**491.40**	**499.40**	**455.10**	**443.70**	**421.10**	**404.40**	**381.90**	**438.50**	**5720.70**
Monthly Mean	**120.00**	**132.65**	**157.70**	**135.95**	**122.85**	**124.85**	**113.78**	**110.93**	**105.28**	**101.10**	**95.48**	**109.63**	1430.18

ប្រភពទិន្នន័យពី មន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ (ឆ្នាំ២០១២)

៥.១.១.៣ គុណភាពខ្យល់ សំឡេងនិងរំញ័រ (Air Noise and Vibration Quality)

១. ការវិភាគគុណភាពខ្យល់ក្នុងតំបន់គម្រោង

តំបន់គម្រោងនេះ ស្ថិតនៅក្នុងតំបន់ជនបទក្នុងស្រុកវាលវែង ដែលជាតំបន់មានព្រៃឈើ នៅក្នុងតំបន់គម្រោងគ្មានតំបន់ទីប្រជុំជន ឬតំបន់ឧស្សាហកម្ម ឬពាណិជ្ជកម្មទេ។ ចំពោះផ្លូវថ្នល់មានផ្លូវជាតិលេខ៥៥ ក្រាលគ្រួសក្រហម គ្មានស្ពានរឹងមាំទេ ហើយផ្លូវចូលទៀតសោទគ្មានស្ពានទេសព្វថ្ងៃ (ខែកក្កដា ឆ្នាំ២០១២) ហេតុដូច្នេះហើយ នៅក្នុងតំបន់គម្រោងនោះ គឺគុណភាពខ្យល់មានលក្ខណៈនៅជាធម្មជាតិ គ្មានការបំពុលខ្យល់ទេ ហើយក៏គ្មានទិន្នន័យណាដែលបញ្ជាក់ពីការបំពុលខ្យល់នៅតំបន់នោះដែរ។ ប៉ុន្តែ ឆ្នាំ២០១៧នេះ ផ្លូវជាតិលេខ៥៥បានសាងសង់ឡើងវិញរួចរាល់ហើយ។

ទោះជាយ៉ាងនេះក៏ដោយ ការធ្វើតេស្តរកគុណភាពខ្យល់នៅក្នុងតំបន់គម្រោងក្រុមការងារ SAWAC បានសហការជាមួយមន្ទីរពិសោធន៍ នៃក្រសួងបរិស្ថាន បានចុះទៅវាស់គុណភាពខ្យល់ និងសំឡេង២៤ម៉. នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១២ នៅក្បែរតំបន់គម្រោង គឺតាមផ្លូវជាតិលេខ៥៥ ដែលមានសកម្មភាពចរាចរមមាញឹកជាងគេ គឺស្ថិតនៅទីតាំងចំណុចតាំងយ៉ ភូមិស្ទឹងថ្មី ឃុំ ប្រម៉ោយ ស្រុកវាលវែង បានបង្ហាញថា គុណភាពខ្យល់ស្ថិតនៅក្រោមកម្រិត ស្តង់ដារបស់ក្រសួងបរិស្ថាននៅឡើយ (លម្អិតមើលតារាង ៥-៨ ខាងក្រោម)

តារាង ៥-៨: គុណភាពខ្យល់នៅក្នុងតំបន់គម្រោង (ខែមិថុនា ឆ្នាំ២០១២)

ល.រ No.	ប៉ារ៉ាម៉ែត្រ Parameter	ខ្នាត Unit	លទ្ធផល Result	ស្តង់ដារ Standard	វិធីសាស្ត្រវិភាគ/ ឧបករណ៍ Method / Equipment
1	Carbon Monoxide (CO)	ppm	0.417	<20	MEXTECH CO-180
2	Nitrogen Dioxide (NO_2)	mg/m³N	0.018	<0.1	Saltzman Method
3	Sulfur Dioxide (SO_2)	mg/m³N	0.010	<0.3	Pararosaniline Method
4	Total Suspended Particles (TSP)	mg/m³N	0.204	<0.33	Weight Concentration Measuring Method

២. សំឡេងនិងរំញ័រ

ដូចគ្នានិងគុណភាពខ្យល់ដែរ តំបន់គម្រោងមិនស្ថិតនៅក្នុងតំបន់ទីប្រជុំជន ឬតំបន់ពាណិជ្ជកម្ម ឬតំបន់ឧស្សាហកម្មទេ ជាតំបន់នៅក្នុងព្រៃភាគច្រើន ដូចនេះគ្មានការបំពុលណាមួយដោយសារសំឡេងនិងរំញ័រគួរឱ្យកត់សម្គាល់ ទេ ក្រៅពីសំឡេងម៉ូតូ រថយន្តតូច រទេះគោ គោយន្តតិចតួច ព្រមទាំងសំឡេងសត្វព្រៃស្រែក ដូចជាសត្វទោច បក្សីចករ៉ក ព្វាំងជាដើម ។ល។

ក្រុមការងារ SAWAC បានសហការជាមួយមន្ទីរពិសោធន៍ នៃក្រសួងបរិស្ថានបានចុះទៅ វាស់គុណភាពខ្យល់ និងសំឡេង២៤ម៉. នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១២ នៅកន្លែងចេញចូលតាមផ្លូវជាតិលេខ៥៥ ដែលជាកន្លែងមានសកម្មភាពមមាញឹកជាងគេក្នុងតំបន់គម្រោង ពោលគឺជាតំបន់លំនៅឋាន។ យោងតាមតារាងខាងក្រោម បានបង្ហាញថា ពេលព្រឹកចាប់ពីម៉ោង៦:០០ ដល់រសៀលម៉ោង ១៨:០០ សំឡេងជាមធ្យម ៥២,៨ dB គឺលើសស្តង់ដារទីតាំងតំបន់ស្ងប់ស្ងៀម (ស្តង់ដារ ៤៥dB)។ ដូចគ្នាដែរចាប់ពីម៉ោង ១៨:០០ ល្ងាច ដល់ម៉ោង ២២:០០ យប់ សំឡេងជាមធ្យម ៥០,៦dB គឺលើសស្តង់ដារ (ស្តង់ដារ៤០dB)ផងដែរ។ រីឯពេលយប់វិញចាប់ពីម៉ោង ២២:០០ ដល់ពេល ភ្លឺម៉ោង៦:០០ ក៏លើសស្តង់ដារផងដែរ សំឡេងជាមធ្យម គឺ៤៩.១dB(ស្តង់ដារ៣៥dB)។ ដោយឡែកនៅម៉ោង ៥:០០ ដល់ម៉ោង ៦ព្រឹក ក្នុងកំឡុងពេលវាស់ មានយានយន្តធ្វើចរាចរណ៍តាមផ្លូវនេះបានធ្វើឱ្យសំឡេងមានការលើសស្តង់ដារដូច្នេះ។លម្អិតមើលតារាង៥-៩ខាងក្រោម។

តារាង ៥-៩: គុណភាពសំឡេងនៅក្នុងតំបន់គម្រោងមុនពេលសាងសង់ (ខែមិថុនា ឆ្នាំ២០១២)

Survey Period		Noise Level dB (A)				Remarks
		Laeq	Standard	Lmax	Lmin	
Day	06:00 - 07:00	52	45	65.4	46.3	Mean=52.8
	07:00 - 08:00	54.1		68.5	47.4	
	08:00 - 09:00	53.6		66.3	46.7	
	09:00 - 10:00	50.9		60.8	46.3	
	10:00 - 11:00	52.4		64	43.2	
	11:00 - 12:00	52.1		64.5	46.7	
	12:00 - 13:00	53.7		65.1	47.3	
	13:00 - 14:00	53.5		65.1	47.1	
	14:00 - 15:00	53.4		67.2	47.5	
	15:00 - 16:00	52.6		63.1	47.9	
	16:00 - 17:00	52.9		66.4	46.8	
	17:00 - 18:00	51.9		70	46.1	
Evening	18:00 - 19:00	52.3	40	64.8	45.6	Mean=50.6
	19:00 - 20:00	50.5		63.8	46.3	
	20:00 - 21:00	50.1		64.7	45.1	
	21:00 - 22:00	49.5		61	45.2	
Night	22:00 - 23:00	49.1	35	60.8	44.6	Mean=49.1
	23:00 - 24:00	48.6		57.4	44.7	
	24:00 - 01:00	49.8		59.6	44.3	
	01:00 - 02:00	48.7		60.1	44.4	
	02:00 - 03:00	47.9		58.8	44.5	
	03:00 - 04:00	48.9		58.1	44.1	
	04:00 - 05:00	49.1		60.1	43.9	
	05:00 - 06:00	50.6		60.5	44.2	
24 hours Average		51.18		63.17	45.68	

ចំពោះគុណរំញ័រនៅក្នុងតំបន់គម្រោងវិញ គឺស្ថិតនៅក្រោមស្តង់ដាររបស់ប្រទេសជប៉ុននៅឡើយទេ នៅឡើយទេ (លម្អិតមើលតារាងខាងក្រោម)។ ***សម្គាល់៖*** *MoE មិនទាន់មានស្តង់ដាររំញ័រនៅឡើយទេ គឺយកស្តង់ដារពីប្រទេសជប៉ុនមកប្រៀបធៀប។*

តារាង ៥-១០: គុណភាពរំញ័រ នៅក្នុងតំបន់គម្រោងកំឡុងពេលសាងសង់ (ខែមិថុនា ឆ្នាំ២០១២)

Survey Period Day Time	Standard of Type 1*	Leq (db)	Survey Period Night Time	Standard of Type 1*	Leq (db)	Remark
06:00 - 07:00	Max 65db Day Time	40.2	18:00 - 19:00	Max 60db Night Time	40.2	
07:00 - 08:00		38.8	19:00 - 20:00		40.4	
08:00 - 09:00		41.6	20:00 - 21:00		40.3	
09:00 - 10:00		41.9	21:00 - 22:00		40.4	
10:00 - 11:00		38.5	22:00 - 23:00		40.2	
11:00 - 12:00		40.8	23:00 - 24:00		40.3	
12:00 - 13:00		42.2	24:00 - 01:00		40.1	
13:00 - 14:00		42.2	01:00 - 02:00		40.6	
14:00 - 15:00		42.4	02:00 - 03:00		40.4	
15:00 - 16:00		42.7	03:00 - 04:00		40.2	
16:00 - 17:00		42.4	04:00 - 05:00		40.7	
17:00 - 18:00		42.2	05:00 - 06:00		40.6	
Average		41.3	Average		40.4	

៥.១.១.៤ ជលសាស្ត្រ (Hydrology)

យោងតាមផែនទី (Digital Map) មាត្រដ្ឋាន ១:១.០០០.០០០ របស់នាយកដ្ឋានភូមិសាស្ត្រ និងការចុះអង្កេតសិក្សា ក្នុងតំបន់គម្រោងផ្ទាល់តាំងពីថ្ងៃទី ១០ កុម្ភៈ ដល់ ០៩ វិច្ឆិកា ឆ្នាំ២០១២ លើផ្ទៃដី ៩.៣៥៥ ហត. ដែលមានប្រឡាយ អូរ ស្ទឹង ដែលពាក់ព័ន្ធនិងស្ទឹងពោធិ៍សាត់ក្នុងតំបន់គម្រោងដូចតទៅ:

- ផ្ទៃរងទឹកភ្លៀងនៃស្ទឹងនេះ (គិតត្រឹមទីតាំងទំនប់) មានទំហំ១.២៦៣,៣គ.ម២ (ទិន្នន័យបានពី ក្រុមហ៊ុនកូរ៉េ HEC)។

- នៅក្នុងផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងពោធិ៍សាត់ផ្នែកខាងលើ នៃស្ទឹងនេះមានពីរផ្នែក គឺស្ទឹងឬស្សី ចាប់ពីព្រំប្រទល់ផ្ទៃរងទឹកភ្លៀងដល់ចំណុចប្រសព្វអូរមាម ស្ថិតនៅឃុំអន្លង់រាប ស្រុកវាលវែង ហើយចាប់ពីចំណុចនេះ ដល់បឹងទន្លេសាប គឺស្ទឹងពោធិ៍សាត់។
- នៅក្នុងតំបន់គម្រោងស្ទឹងពោធិ៍សាត់ (គិតតែក្នុងផ្ទៃអាង) មានប្រវែង ៣០,១៥ គ.ម ។
- ប្រភពទឹកស្ទឹងពោធិ៍សាត់ គឺបានមកពីទឹកភ្លៀង ដែលហូរក្នុងផ្ទៃរងទឹកភ្លៀងរបស់វាស្ថិតក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងខេត្តពោធិ៍សាត់នេះតែម្តង។ ចំពោះជម្រៅទឹកស្ទឹងពោធិ៍សាត់នៅទៅតាំងសាងសង់ទំនប់មានជម្រៅពី១ម(រដូវប្រាំង) ទៅ ៦ម(នៅរដូវវស្សា)។ ចំពោះធារទឹកលម្អិតមើលតារាង៥-១១ ខាងក្រោម។
- អូរសំខាន់ៗជាសាខានៃស្ទឹងពោធិ៍សាត់ស្ថិតនៅក្នុងតំបន់គម្រោងមាន (រាប់ពីលើចុះក្រោម) នៅផ្នែកខាងឆ្វេងគឺ អូរសំឡាញ, អូរស័ង្កសី, អូរក្បាលខ្ទីង (ផ្នែកខាងលើហៅថា អូរតាគ្រី), អូរពីរ(ផ្នែកខាងក្រោមគឺអូរពាមដា), អូរកំបោរ អូរធូម(អូរគ្រីស់) នៅផ្នែកខាងលើវា ហៅថា អូរកំពង់ក្លោង, អូរឬស្សី, អូរជ្រៅ និងមានអូរតូចៗ ជាច្រើនដែលមិនមានឈ្មោះ។ ចំណែកឯ ផ្នែកខាងស្តាំនៃស្ទឹងពោធិ៍សាត់មាន អូរតាសូរ, អូរសោម, អូរសន្តាំង និងអូរតូចៗ ជាច្រើនទៀត ដែលមិនមានឈ្មោះ។
- យោងតាមទិន្នន័យ ដែលបានសិក្សាគណនាដោយក្រុមហ៊ុនកូរ៉េ HEC ឆ្នាំ២០១២ ផ្នែកលក្ខណៈជលសាស្រ្ត ដើម្បីគណនាហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះមានដូចតទៅៈ

១. ទិន្នន័យសំខាន់ៗនៃស្ទឹងពោធិ៍សាត់

ការប៉ាន់ប្រមាណធារទឹកនៅទីតាំងសាងសង់ទំនប់នៃគម្រោងនេះ ដោយយោងតាមទិន្នន័យ ដែលទទួលបានពីក្រុមហ៊ុន Hyundai Engineering Co., LTD. (HEC) (គណនាតាមរូបមន្ត Creager's Empirical Formula)មានដូចតារាងខាងក្រោមៈ

តារាង ៥-១១: ការប៉ាន់ស្មានធារទឹក គតជា ម៣/វិនាទី តាមកំពស់ទឹកភ្លៀងបានកត់ត្រារយៈពេល ៣០ឆ្នាំ នៅទីតាំងទំនប់

No.	Year	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Average
1	1981	2.0	1.4	0.6	0.9	16.0	18.5	49.9	62.6	91.8	143.9	130.0	46.0	**47.2**
2	1982	22.1	12.9	28.3	22.2	28.0	29.4	29.6	42.3	69.5	38.1	49.0	23.5	**33.0**
3	1983	12.7	7.8	4.0	5.6	8.1	11.3	34.6	33.0	60.8	69.0	94.1	36.5	**31.5**
4	1984	17.8	10.0	5.0	6.2	13.8	22.0	16.5	14.6	44.3	170.9	61.0	27.2	**34.3**
5	1985	17.9	13.1	8.9	12.8	56.1	37.5	50.7	31.8	75.1	57.1	110.0	45.9	**43.2**
6	1986	21.5	11.3	4.8	3.3	6.0	14.8	19.7	43.0	55.5	44.6	31.4	22.2	**23.2**
7	1987	11.4	6.3	3.6	3.8	16.8	26.4	35.5	40.7	89.4	63.6	107.2	39.4	**37.0**
8	1988	19.6	11.1	5.2	13.1	35.1	79.3	80.9	145.0	86.2	128.9	68.5	30.1	**58.9**
9	1989	15.1	7.5	7.3	11.0	33.4	28.3	40.3	107.6	123.2	66.1	50.3	22.0	**42.8**
10	1990	12.2	7.5	10.6	15.8	19.6	20.8	39.3	61.0	85.0	96.0	40.0	19.5	**35.8**
11	1991	10.4	6.1	2.7	2.4	9.0	18.8	48.7	56.3	105.0	100.2	42.9	20.9	**35.4**
12	1992	10.5	5.1	1.2	0.7	1.1	9.6	17.8	60.1	85.4	85.0	46.9	22.0	**28.9**
13	1993	14.6	7.6	7.7	8.4	10.2	40.8	47.2	29.5	71.0	31.1	16.2	8.0	**24.4**
14	1994	3.3	1.4	8.0	4.1	13.6	40.9	28.3	67.6	112.2	78.7	33.9	14.7	**34.0**
15	1995	6.6	4.8	3.2	4.6	25.6	38.0	74.9	83.5	172.6	187.6	111.5	44.8	**63.4**
16	1996	19.3	10.3	3.8	22.7	54.6	52.2	48.0	46.4	73.0	226.5	103.3	45.0	**59.1**
17	1997	20.1	13.7	6.2	14.8	17.4	32.5	47.6	86.3	111.7	90.5	38.5	16.5	**41.5**
18	1998	8.1	6.9	2.0	2.8	2.0	13.0	14.9	33.3	71.1	68.7	66.1	31.8	**26.8**
19	1999	18.7	9.5	3.9	19.8	56.1	84.4	80.5	61.1	86.6	87.8	123.3	46.1	**56.6**
20	2000	22.4	13.6	9.6	28.7	71.8	81.8	69.4	89.3	75.1	162.5	65.2	29.1	**60.2**
21	2001	20.7	14.0	25.9	17.1	16.3	16.8	15.0	70.7	131.2	203.2	55.9	20.6	**50.9**
22	2002	14.6	8.9	4.8	4.8	9.8	16.1	18.2	26.1	83.5	88.7	35.4	76.2	**32.4**
23	2003	23.9	13.6	14.8	15.7	18.9	20.5	39.5	25.0	70.2	319.1	49.9	12.2	**52.4**
24	2004	9.4	7.8	8.6	5.9	6.4	15.6	13.2	20.6	54.3	181.8	14.7	7.7	**29.1**
25	2005	3.6	2.2	2.4	2.7	9.2	11.9	13.0	15.0	83.9	101.7	39.8	25.3	**26.0**
26	2006	4.3	0.6	2.0	27.0	23.7	26.5	82.7	58.7	126.0	93.1	5.9	6.4	**38.3**
27	2007	4.6	3.5	3.4	5.9	13.4	60.2	80.5	70.5	186.9	236.1	29.7	5.4	**58.7**
28	2008	1.6	1.4	1.4	5.4	38.8	62.6	45.3	48.6	90.5	302.4	239.9	23.0	**72.0**
29	2009	6.7	2.1	2.7	20.8	17.9	12.3	23.1	11.6	50.4	152.7	51.3	2.4	**29.7**

No.	Year	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Average
30	2010	1.9	1.7	3.1	5.1	6.5	24.2	53.9	72.3	122.0	389.2	60.5	18.8	**63.9**
Max		23.9	14.0	28.3	28.7	71.8	84.4	82.7	145.0	186.9	389.2	239.9	76.2	72.0
Min		1.6	0.6	0.6	0.7	1.1	9.6	13.0	11.6	44.3	31.1	5.9	2.4	23.2
Mean		12.6	7.4	6.5	10.5	21.8	32.2	42.0	53.8	91.4	135.5	65.7	26.3	42.4

ប្រភពទិន្នន័យពី ការសិក្សាសមិទ្ធលទ្ធភាពដំបូង គម្រោង(ឆ្នាំ២០១០) របស់ក្រុមហ៊ុន Hyundai Engineering Co., LTD



ប្រភពទិន្នន័យពី ការសិក្សាសមិទ្ធលទ្ធភាពដំបូង គម្រោង(ឆ្នាំ២០១០) របស់ ក្រុមហ៊ុន Hyundai Engineering Co., LTD

យោងតាមលទ្ធផលនៃការគណនាលំហូរប្រចាំឆ្នាំ (Annaul Runoff) ខាងលើ, ការប៉ាន់ស្មានទឹកជំនន់ អតិបរមាប្រចាំឆ្នាំ និងទិន្នន័យជលសាស្ត្រសម្រាប់គណនាហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី បង្ហាញនៅក្នុងតារាង ៥-១២ ខាងក្រោម:

តារាង ៥-១២: លទ្ធផលនៃការគណនាលំហូរធារទឹកខ្ពស់ នៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់ ១ នៅទីតាំងទំនប់ (ម៣/វិនាទី) ទៅតាមខួបនៃទឹកជំនន់

P (%)	PMF	0.01	0.1	0.2	0.5	1	2	5	10	20
Qp (m^3/s)	4080	3060	2470	2290	2050	1860	1670	1410	1210	1070

<u>ប្រភពទិន្នន័យ:</u> ការសិក្សាបច្ចុប្បន្នភាពសមិទ្ធលទ្ធភាព គម្រោង(ឆ្នាំ២០១៧) របស់ក្រុមហ៊ុនម្ចាស់គម្រោង

តារាង ៥-១៣: លទ្ធផលនៃការគណនាប្រៀបធៀបធារទឹកខ្ពស់បំផុត នៃគម្រោងនៅទីតាំងទំនប់(ម៣/វិនាទី)

P(%)	Design flood peak flow at different stages (m^3/s)		
	Current recheck (adopted) (Rainfall-runoff model)	Feasibility Study (Rainfall-runoff model)	Pre-Feasibility Study (Creager's Formular)
PMF	4080	2660	7960
0.01	3060	2660	7960
0.1	2470		
0.2	2290	2024	
0.5	2050	1831	1510
1	1860	1686	
2	1670	1541	
5	1410	1347	
10	1210	1199	
20	1070	1045	1190
50	801	817	

ប្រភពទិន្នន័យ: ការសិក្សាបច្ចុប្បន្នភាពសមិទ្ធលទ្ធភាព គម្រោង(ឆ្នាំ២០១៧) របស់ក្រុមហ៊ុនម្ចាស់គម្រោង

សម្គាល់: លំហូរទឹកសម្រាប់ការពារបរិស្ថាននៃស្ទឹងពោធិ៍សាត់ខាងក្រោមទំនប់មេ គឺ ១.៣ ម៣/វិន.។
ប្រភពទិន្នន័យពី ការសិក្សាសមិទ្ធលទ្ធភាព គម្រោង(ឆ្នាំ២០១២) របស់ ក្រុមហ៊ុន Hyundai Engineering Co., LTD

តារាង ៥-១៤: សង្ខេបទិន្នន័យឧតុនិយម និងជលសាស្ត្រសម្រាប់គណនាហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី

#	Description	Unit	Dam and Spillway	Remarks
1	Dam site Perennial Average Flow	m^3/s	42.40	Hyundai Engineering Co., Ltd (2012)
2	Dam Site Minimum Flow	m^3/s	0.60	Udated Feasibility Report (2017)
3	Dam Site Draught Flow	m^3/s	3.9	Hyundai Engineering Co., Ltd (2012)
4	Eco-flow discharge	m^3/s	1.3	Udated Feasibility Report (2017)
5	Dam site Flood Flow (flood frequency 1 000 year)	m^3/s	2,470	Udated Feasibility Report (2017)
6	Plant Building Checking Flood (PMF)	m^3/s	4,080	Udated Feasibility Report (2017)
7	Perennial Average Temperature	°C	28.40	Ministry Of Water Resource and Meteorology
8	Extreme High Temperature	°C	41.3	Ministry Of Water Resource and Meteorology
9	Extreme Low Temperature	°C	12.9	Ministry Of Water Resource and Meteorology
10	Perennial Average Humidity	%	81.4	Ministry Of Water Resource and Meteorology
11	Maximum Wind velocity	m/s	7	Ministry Of Water Resource and Meteorology
12	Perennial Average rainfall	mm	1,750	Hyundai Engineering Co., Ltd (2012)
13	Perennial Average Evaporation Quantity	mm	1,580	Ministry Of Water Resource and Meteorology
14	Sediment Deposit pre Year	$m^3/km^2/yr$	300	Udated Feasibility Report (2017)
15	Elevation of Sedimentaion after operartion 100 years	m	115.4	Udated Feasibility Report (2017) below death level 44.6m (death level EL:160m)
16	Basic Earthquake Fissure	degree	5.00	Hyundai Engineering Co., Ltd (2012)

សម្គាល់: ទិន្នន័យនេះ យកមកធ្វើបច្ចុប្បន្នភាពសមិទ្ធិលទ្ធភាព ឆ្នាំ ២០១៧ នេះផងដែរ

២- ការវិភាគគុណភាពទឹកលើដី (Surface Water Quality Analysis)

ការវិភាគគុណភាពទឹកលើដីនៅក្នុងតំបន់គម្រោង ត្រូវបានក្រុមសិក្សារបស់ SAWAC ជ្រើសរើសពីរចំណុច គឺនៅក្នុងអាងខាងលើទំនប់ និងខាងក្រោមអាគារថាមពល។

ទីតាំងយកសំណាកទឹកមានបង្ហាញដូចខាងក្រោមនេះ :

- ចំណុចទី១ គឺនៅក្នុងអាង ខាងលើទំនប់ ដែលមានកូអរដោនេ X= 302109 និងY= 1365417(សំណាកទី១)។
- ចំណុចទី២ ខាងក្រោមអាគារថាមពល ដែលមានកូអរដោនេ X= 323677 និង Y= 1365770 (សំណាកទី៤)។

(សូមមើលផែនទី ១, ៣ & ៤ ៖ ទីតាំងយកសំណាកទឹក និងការសិក្សារាប់ព្រៃឈើឧបសម្ព័ន្ធ ៤)។

សំណាកទឹកនៃខ្សែទឹកខាងលើ ត្រូវបានយក និងធ្វើការវិភាគក្នុងអំឡុងពេលសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ខែមិនា ២០១២ នេះ និងរៀងរាល់ ២ខែម្តង ឆ្នាំ២០១២ ហើយលទ្ធផលគុណភាពទឹកមានបង្ហាញជូនដូចខាងក្រោម។

តារាង ៥-១៥: លទ្ធផលការពិសោធន៍គុណភាពទឹកលើដី នៃចំណុចទី១ (សំណាកទី១)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដារគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សា ជីវសាស្ត្រចុះ MoE	លេខសំណាក ១		
				នៅក្នុងអាងខាងលើទំនប់	នៅក្នុងអាងខាងលើទំនប់	នៅក្នុងអាងខាងលើទំនប់
				១៤.មិនា.២០១២ (រដូវប្រាំង)	០៩.ឧសភា.២០១២ (រដូវប្រាំង)	១២.កក្កដា.២០១២ (រដូវវស្សា)
1	pH	No Unit	6.5 - 8.5	7.8	7.5	7.6
2	BOD_5	mg/l	1 - 10	2.97	3.80	2.05
3	Dissolved Oxygen (DO)	mg/l	2 - 7.5	6.45	5.92	6.84
4	Manganese (Mn)	mg/l	-	0.1	0.1	0.1
5	Iron (Fe)	mg/l	-	0.11	0.12	0.31
6	Asernic (As)	mg/l	-	0	0	0
7	COD	mg/l	-	5.48	6.27	4.57
8	Total Coliform	MPN/100ml	< 5000	430	0	750
9	Nitrite-N(NO_2-N)	mg/l	-	0.004	0.171	0.014
10	True Nitrate-N(T-N)	mg/l	-	3.096	4.729	6.186
11	Nitrate-N(NO_3 -N)	mg/l	-	3.1	4.9	6.2
12	Nitrate (NO_3)	mg/l	-	13.64	21.56	27.28
14	Nitrate (NO_2)	mg/l	-	0.0132	0.5643	0.0462
14	Temperature (t°c)	°c	-	27.8	29.6	26.9
15	Conductivity	µS/Cm	-	214	161.4	72.4
16	TDS	mg/l	-	107	80.7	36.2
17	Turbidliy	NTU	-	8	5	26
18	Total Nitrogen (TN)	mg/l	-		0.11	0.06
19	Total Phoshorus (TP)	mg/l	-	0.03	0.05	0.022

សម្គាល់៖

- *MoE ៖ ក្រសួងបរិស្ថាន (កម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវសាស្ត្រ ចំរុះនៅក្នុងទឹក សម្រាប់ទន្លេ)*
- *តម្លៃលេខពណ៌ក្រហម ជាតម្លៃលើសស្តង់ដារ*

តារាង ៥-១៦: លទ្ធផលការពិសោធន៍គុណភាពទឹកលើដី នៃចំណុចទី២ (សំណាកទី៤)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដារគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សា ជីវសាស្ត្រចំរុះ MoE	លេខសំណាក ៤		
				ខាងក្រោម អាគារថាមពល	ខាងក្រោម អាគារថាមពល	ខាងក្រោម អាគារថាមពល
				១៣.មិនា.២០១២	០៩.ឧសភា.២០១២	១២.កក្កដា.២០១២
1	pH	No Unit	6.5 - 8.5	7.9	7.6	7.8
2	Manganese (Mn)	mg/l	-	0.1	0.1	0.2
3	Iron (Fe)	mg/l	-	0.18	0.25	0.47
4	Asernic (As)	mg/l	-	0	0	0
5	Dissolved Oxygen (DO)	mg/l	2 - 7.5	6.90	6.21	5.74
6	BODs	mg/l	1 - 10	0.79	1.40	0.49
7	COD	mg/l		1.39	3.51	1.11
8	Total Coliform	MPN/100ml	< 5000	11000	210	12000
9	Nitrite-N(NO_2-N)	mg/l	-	0.003	0.031	0.005
10	True Nitrate-N(T-N)	mg/l	-	4.397	5.569	6.395
11	Nitrate-N(NO_3-N)	mg/l	-	4.4	5.6	6.4
12	Nitrate (NO_3)	mg/l	-	19.36	24.64	28.16
13	Nitrate (NO_2)	mg/l	-	0.0099	0.1023	0.0165
14	Temperature (t°c)	°c	-	30	29.5	28.6
15	Conductivity	µS/Cm	-	157.1	104.6	61.4
16	TDS	mg/l	-	78.55	52.3	30.7
17	Turbidliy	NTU	-	9	8	27
18	Total Nitrogen (TN)	mg/l	-		0.15	0.05
19	Total Phoshorus (TP)	mg/l	-	0.02	0.04	0.02

យោងតាមតួលេខនៃការវិភាគទឹកលើដីខាងលើ បានបង្ហាញថា នៅចំណុចទី១ ក្នុងតំបន់អាង មិនមានប៉ារ៉ាម៉ែត្រដែលលើសស្តង់ដាររបស់ MOE ទេទាំងរដូវប្រាំង និងវស្សា។ ចំណែកឯ នៅចំណុចទី២ ខាងក្រោម អាគារថាមពល Total Cooliform គឺលើសពី តម្លៃស្តង់ដារគុណភាពទឹក នៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិរក្សជីវសាស្ត្រ ចំរុះនៅក្នុងទឹកសម្រាប់ទន្លេ របស់ក្រសួងបរិស្ថាន (MOE) ទាំងរដូវប្រាំង និងវស្សាផងដែរ។

៣- ការវិភាគគុណភាពទឹកក្រោមដី (Ground Water Quality Analysis)

ក្នុងតំបន់គម្រោងគ្មានអណ្តូងណាដែលអាចធ្វើការសិក្សាទឹកក្រោមដីនោះទេ ដូចនេះក្រុមការងារ SAWAC បានជ្រើសរើស ទីតាំង២ចំណុចគឺ ចំណុចដែលមានអណ្តូងស្នប់ Afridev Deep (ទឹកក្រោមដីជ្រៅ ខ្ទប់) ដែលស្ថិតនៅក្បែរតំបន់គម្រោងក្នុងចំណុច ដូនទាគ ភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង និងអណ្តូងស្នប់ VN#6 (ទឹកក្រោមដីរាក់ មិនខ្ទប់)ដែលស្ថិតនៅក្នុងចំណុចស្រែពាំង ភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង មកធ្វើការវិភាគហើយទីតាំងយកសំណាកទឹកមានបង្ហាញ ដូចខាងក្រោមនេះ ៖

- ចំណុចទី១ គឺនៅអណ្តូងស្នប់ Afridev Deep ស្ថិតនៅក្នុងចំណុចដូនទាគ ដែលមានកូអរដោនេ X= 308731 និង Y= 1368702 (សំណាកទី២)។
- ចំណុចទី២ គឺនៅអណ្តូងស្នប់ VN#6 ស្ថិតនៅក្នុងចំណុចស្រែពាំង ដែលមានកូអរដោនេ X=309252 និង Y=1368965 (សំណាកទី៣)។

ក្រុមការងារ SAWAC ក៏បានសិក្សាបរិមាណទឹកក្រោមដីផងដែរ។ រីឯវិធីសាស្ត្រមានចែងក្នុងជំពូក២ខាងលើ ហើយលទ្ធផល យកមកធ្វើការវិភាគដូចខាងក្រោម:

- ស្រទាប់ទឹកក្រោមដីមិនខ្ទប់ (Unconfined Aquifer) ស្រទាប់នេះ គឺមានជម្រៅរាក់ បើប្រៀបធៀបទៅនឹងនីវ៉ូផ្ទៃដីខាងលើ មានជម្រៅចាប់ពី ៥ម ទៅ ១០ម (តាមនីវ៉ូដី) ហើយមានទិសដៅហូរចុះទៅស្ទឹង។ ស្រទាប់នេះ

មានធារទឹកតិចប្រមាណពី ៥០០ ទៅ ៣៥០០ ល/ម៉។ ចំពោះបរិមាណទឹកនៅរដូវប្រាំងមានការថយចុះខ្លាំង រហូតមានអណ្តូងខ្លះរីងគ្មានទឹកទៀតផង ។

- ស្រទាប់ទឹកក្រោមដីខ្ទប់ (Confined Aquifer) ជាស្រទាប់ទឹកក្រោមដី ដែលមានជម្រៅចាប់ពី១៥ម ទៅ៣០ម ហើយមានសម្ពាធទឹក ដែលមាននីវ៉ូស្តាទិកគិតពីផ្ទៃដីខាងលើ ប្រមាណ ៥ម ទៅ ២០ម ។ ស្រទាប់ទឹកក្រោម ដីនេះ មានបរិមាណធារទឹកប្រមាណពី ១ ទៅ ៣ ម^{៣}/ម៉ោង ។

សម្គាល់: វិធីសាស្ត្រមានចែងក្នុងជំពូក២ខាងលើ ហើយលទ្ធផលយកមកធ្វើការវិភាគគុណភាពទឹក ដូចខាងក្រោម:

តារាង ៥-១៧: លទ្ធផលការពិសោធន៍គុណភាពទឹកក្រោមដីចំណុចទី១ (សំណាកទី២)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដារគុណភាពទឹកផឹក MIME	លេខសំណាក ២		
				អណ្តូងស្នប់ជ្រៅ Afridev Deep	អណ្តូងស្នប់ជ្រៅ Afridev Deep	អណ្តូងស្នប់ជ្រៅ Afridev Deep
				១៤.មិនា.២០១២	០៩.ឧសភា.២០១២	១២.កក្កដា.២០១២
1	Manganese (Mn)	mg/l	0.1	0.2	0.1	0.3
2	Fluoide (F)	mg/l	1.5	0.79	0.54	0.51
3	Iron (Fe)	mg/l	0.3	0.08	0.19	0.07
4	Asernic (As)	mg/l	0.05	0	0	0
5	Total Coliform	MPN/100ml	0	2400	0	150
6	Nitrite-N(NO_2-N)	mg/l	-	0.014	0.014	0.016
7	True Nitrate-N(T-N)	mg/l	-	4.086	5.386	4.984
8	Nitrate-N(NO_3-N)	mg/l	-	4.1	5.4	5.0
9	Nitrate (NO_3)	mg/l	≤ 50	18.04	23.76	22.0
10	Nitrate (NO_2)	mg/l	≤ 2	0.0462	0.0462	0.0528
11	pH	No Unit	6.5 - 8.5	6.8	6.9	6.9
12	Temperature (t°c)	°c	-	27.6	26.9	26.9
13	Conductivity	μS/Cm	1500	1354	1343	1332
14	TDS	mg/l	800	677	671.5	666
15	Turbidliy	NTU	5	1	3	5
16	Total Nitrogen (TN)	mg/l	-	0.07	0.08	0.05
17	Total Phoshorus (TP)	mg/l	-	0.01	0.03	0.01

តារាង ៥-១៨: លទ្ធផលការពិសោធន៍គុណភាពទឹកក្រោមដីចំណុចទី២ (សំណាកទី៣)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដារគុណភាពទឹកផឹក MIH	លេខសំណាក ៣		
				អណ្តូងស្នប់រាក់ VN #6	អណ្តូងស្នប់រាក់ VN #6	អណ្តូងស្នប់រាក់ VN #6
				១៤.មិនា.២០១២	០៩.ឧសភា.២០១២	១២.កក្កដា.២០១២
1	Manganese (Mn)	mg/l	0.1	0.1	0.1	0.1
2	Fluoide (F)	mg/l	1.5	0.87	0.69	0.44
3	Iron (Fe)	mg/l	0.3	0.01	0.01	0.05
4	Asernic (As)	mg/l	0.05	0	0	0
5	Total Coliform	MPN/100ml	0	230	0	140
6	Nitrite-N(NO_2-N)	mg/l	-	0.107	0.014	0.095
7	True Nitrate-N(T-N)	mg/l	-	4.793	3.7886	5.805
8	Nitrate-N(NO_3-N)	mg/l	-	4.9	3.8	5.9
9	Nitrate (NO_3)	mg/l	≤ 50	21.56	16.72	25.96
10	Nitrate (NO_2)	mg/l	≤ 2	0.3531	0.0462	0.3135
11	pH	No Unit	6.5 - 8.5	7.1	7.2	7.2
12	Temperature (t°c)	°c	-	28.1	25.9	27.4
13	Conductivity	μS/Cm	1500	975	963	958
14	TDS	mg/l	800	487.5	481.5	479
15	Turbidliy	NTU	5	1	4	7
16	Total Nitrogen (TN)	mg/l	-	0.11	0.13	0.07
17	Total Phoshorus (TP)	mg/l	-	0.02	0.04	0.01

សម្គាល់៖

- *MIH ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (កម្រិតស្តង់ដារគុណភាពទឹកបរិភោគ)*
- *តម្លៃលេខពណ៌ក្រហម ជាតម្លៃលើសស្តង់ដារ*

យោងតាមតួលេខនៃការវិភាគទឹកក្រោមដីខាងលើ បានបង្ហាញថា មានប៉ារ៉ាម៉ែត្រដូចជា Mn, Total Coliform និងភាពល្អក់ នៃអណ្តូងរាក់ លើសពីតម្លៃស្តង់ដារសម្រាប់ទឹកផឹករបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (MIH)។

៤- សន្និដ្ឋានលើគុណភាពទឹកក្នុងតំបន់គម្រោងវារីអគ្គិសនីនេះមុនការសាងសង់គម្រោង

ក. គុណភាពទឹកលើដី

គុណភាពទឹកលើដី យោងតាមការវិភាគទឹកទាំងពីរចំណុចខាងលើ យើងអាចធ្វើការសន្និដ្ឋាន ដូចតទៅៈ (ការតេស្តគុណភាពទឹកលើដីមានចំនួន ១៩ ប៉ារ៉ាម៉ែត្រ ក្នុងរយៈពេលពីរខែធ្វើតេស្តម្តងចំនួន៦ខែ ជាប់ៗគ្នា។ រីឯប៉ារ៉ាម៉ែត្រ ការលើកយកមកបរិយាយ ខាងក្រោមនេះ ចំពោះតែតម្លៃនៃប៉ារ៉ាម៉ែត្រ ដែលលើសស្តង់ដារតែប៉ុណ្ណោះ)។

- ក្នុងអាងទឹខាងលើទំនប់ៈ មានប៉ារ៉ាម៉ែត្រខ្លះដូចជា Total Coliform មានការលើសស្តង់ដាររបស់ MOE ក៏ពិតមែនតែចំពោះ ការបំពុលមុនពេលសាងសង់គម្រោងនេះ មានកម្រិតតិចតួចនៅឡើយកត្តាទាំងនេះ គឺកើតឡើងដោយសារ មានមនុស្សរស់នៅច្រើនដូចជា ឃុំអន្លង់រាប, ប្រម៉ោយ ទីរួមស្រុកវាលវែងជាដើម ដូចនេះពួកគេរាល់គ្នា ត្រូវការងូតទឹក បោកគក់បញ្ចេញសំណល់រាវ-រឹង ជាពិសេស បំពុលពី លាមក ដែលហូរចូលទឹកស្ទឹងនេះ។ ចំពោះ Total Coliform មានការប្រែប្រួលពី 430 ទៅ 750 MPN/100ml។
- Total Coliform មានការកើនឡើងនៅរដូវវស្សាផងដែរ គឺដោយសារ នៅតំបន់ខាងលើខ្សែទឹក ខាងក្រោមទំនប់ <u>ខាងក្រោមអាគារថាមពលៈ</u> ដូចតំបន់អាងដែរ គុណភាពទឹកស្ទឹងពោធិ៍សាត់ គឺមានប៉ារ៉ាម៉ែត្រ Total Coliform មានការកើនឡើងពី 210 ទៅ 12000 MPN/100ml គឺវាកើនឡើងក្នុងរដូវវស្សា ដោយសារមានតំបន់មនុស្សរស់នៅច្រើនផ្នែកខាងលើ ខ្សែទឹក ដូចជា ឃុំអន្លង់រាប, ប្រមោយ, ភូមិស្ទឹងថ្មី (អ្នកស្រុកនៅចំណុច ស្វាយកោង ចំណុចអន្លង់យូត ចំណុចអន្លង់ក្រូច) ជាដើម។ល។

ដូច្នេះយោងតាមសំណាកទឹកទាំងពីរចំណុច ដែលក្រុមសិក្សាបានយកមកធ្វើការពិសោធន៍ និងការសង្កេតមើលឃើញដោយ ភ្នែក និងការយកព័ត៌មានពីប្រជាពលរដ្ឋមូលដ្ឋាន អាចសន្និដ្ឋានបានថា គុណភាពទឹកស្ទឹងនោះ ក្នុងដំណាក់កាលមុនសាងសង់គម្រោង ការបំពុល ដោយសារជាតុគីមីតិចតួច ដែលកើតឡើងដោយសារតែធម្មជាតិ និងមនុស្សដែលរស់នៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀង របស់វាប៉ុណ្ណោះ។

បណ្តុំការបំពុលទឹកពីសកម្មភាពមនុស្សរួមមានៈ

- ការប្រើប្រាស់ជី និងថ្នាំពុលកសិកម្មលើដីដំណាំ (សំណល់ជី និងថ្នាំពុលទាំងនោះ អាចជ្រាប ឬហូរចូលក្នុងស្ទឹង) ផ្នែកខាងលើស្ទឹង គឺនៅតំបន់អន្លង់រាប ឃុំក្រពើពីរ (មួយផ្នែក) និងតំបន់ទីរួមស្រុកវាលវែង ប្រម៉ោយ ដែលស្ថិត ក្នុងផ្ទៃរងទឹកភ្លៀងនៃស្ទឹងពោធិ៍សាត់។
- ការចុះងូតទឹកលេងកម្សាន្ត និងការបោកគក់ លាងជុស របស់ ប្រជាជនរស់នៅក្នុងតំបន់ទាំងនោះ។
- ការចោលកាកសំណល់នានាពីអ្នកភូមិក្នុងតំបន់ និងអ្នកចំនូលថ្មី ហើយហូរចូលក្នុងទឹកស្ទឹង។
- ការបង្ហូរសំណល់រាវពីអ្នកស្រុកក្នុងតំបន់ខាងលើចូលក្នុងស្ទឹង។

ខ. គុណភាពទឹកក្រោមដី

គុណភាពទឹកក្រោមដីនៅក្បែរតំបន់គម្រោង បានធ្វើនៅពីរប្រភេទ គឺអណ្តូងជ្រៅ (ជម្រៅ ២៥ ម) និងអណ្តូងរាក់ (ជម្រៅ១៥ម) ការតេស្តប្រភពនីមួយៗចំនួន១៧ប៉ារ៉ាម៉ែត្រ។ យោងតាមលទ្ធផលនៃតម្លៃទៅតាមប៉ារ៉ាម៉ែត្រនីមួយៗ មិនឃើញមានការបំពុលដោយសារសាជាតុគីមីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពនោះទេ តែមានសារធាតុដែក និងម៉ង់កាណែសខ្លះៗនៅ ក្នុងខ្សែទឹកក្រោមដីទាំងនេះ។ ការលើសស្តង់ដារ នៃតម្លៃប៉ារ៉ាម៉ែត្រនិមួយៗ បានធ្វើការវិភាគដូចខាងក្រោមៈ

- គុណភាពទឹកក្រោមដីជ្រៅ ដែលមានជម្រៅលើសពី ១៥ ទៅ ៣០ម មានគុណភាពល្អអាចទទួលទានបាន ប៉ុន្តែត្រូវដាំទឹកនៅក្នុងអណ្តូងនេះជាមុន ព្រោះវាបំពុលដោយលាមកមនុស្ស គឺ Total Coliform ប្រែប្រួលពី 0 ទៅ

2400 MPN/100ml ហើយមានរសជាតិភ្លាវបន្តិចពីព្រោះ Conductivity មានតម្លៃចន្លោះពី 1332 ទៅ 1354 μS/Cm (បើវាមានតម្លៃលើពី 1000 μS/Cm ទៅនោះធ្វើឱ្យទឹកមានរសជាតិភ្លាវ)និងម៉ង់កាណែស ចន្លោះពី០,១ ទៅ០,៣ mg/l ។ ជាទូទៅ ទឹកក្រោមដីជ្រៅ លើសពីជម្រៅ ២០ ម ទៅមិនមានមេរោគ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្សទេ។ ចំពោះអណ្តូងនេះ យោងតាមលទ្ធផលវិភាគគុណភាពទឹក ទាំង៣លើក ឃើញវត្តមាននៃ Total Coliform ពីរលើកដូចនោះទាមទារឱ្យធ្វើការសំលាប់មេរោគ (Disinfection) ក្នុងអណ្តូងនេះ។ ទៅថ្ងៃអនាគត បើគេចង់ខួងអណ្តូងយកប្រភពទឹកជ្រៅប្រើប្រាស់សម្រាប់បរិភោគ ត្រូវធ្វើការខួងអណ្តូង ដោយដាក់បំពង់ចំរោះពី ២០ម ដល់ ៣០ម ហើយមុននឹងប្រើប្រាស់ត្រូវធ្វើការសំលាប់មេរោគក្នុងអណ្តូងនោះជាមុនសិនពីព្រោះពេលខួង និងដំឡើងបំពង់ អណ្តូងមានការបំពុល ពីមនុស្ស។

- គុណភាពទឹកក្រោមដីរាក់ មានជម្រៅ ១៥ម គុណភាពទឹកក្នុងអណ្តូងនេះ មិនមាន សារធាតុគីមីណា ដែលធ្វើឱ្យប៉ះ ពាល់ដល់សុខភាពមនុស្ស សត្វនោះទេ តែនៅរដូវវស្សា ភាពល្អក់មានការលើសស្តង់ដារទឹកផឹកតិចតួច ពោលគឺវាមានការប្រែប្រួលពី ១ ដល់ ៧ NTU។ ចំណែកឯ Total Coliform ប្រែប្រួលពី 0 ទៅ 230 MPN/100ml ដូចនេះទឹកក្នុង អណ្តូងនេះត្រូវដាំទឹកឱ្យពុះមុនពេលបរិភោគ ។

៥.១.១.៥ ប្រព័ន្ធស្រោចស្រព (Irrigation system)

នៅក្នុងតំបន់គម្រោងនេះ យោងតាមការសិក្សារបស់ក្រុមការងារ SAWAC មានដីស្រែចំការ (ដីកសិកម្ម) ដីបុស្ស និងដីលំនៅឋាន ចំពោះដីស្រែចំការទាំងនោះ ពុំមានប្រព័ន្ធស្រោចស្រពទេ គឺប្រជាពលរដ្ឋធ្វើកសិកម្មអាស្រ័យ និងទឹកភ្លៀង។ ចំពោះ អ្នកដែលមានដីស្រែចំការតាមមាត់ស្ទឹង ហើយមានជីវភាពមធ្យមគេប្រើម៉ាស៊ីនបូមទឹកពីស្ទឹងដើម្បីស្រោចស្រពដំណាំកសិកម្ម ដូចជា ពោត ល្ង សណ្តែកបាយ ជាដើម (ដំណាំសំខាន់ៗនៅក្នុងតំបន់នោះគឺពោតក្រហម ល្ង ស្រូវ និងសណ្តែកបាយ)។ បន្ថែមពីលើនេះ នៅក្នុងសិក្ខាសាលាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០១២ ក៏បានបញ្ជាក់ថា គ្មានប្រព័ន្ធស្រោចស្រពដែលបានសង់ក្នុងតំបន់គម្រោងផងដែរ។

៥.១.១.៦ សេចក្តីសន្និដ្ឋានទៅលើការសិក្សាជនជានរូបសាស្ត្រ

យោងតាមការសិក្សា ដែលបានបង្ហាញខាងលើ យើងអាចដកស្រង់សង្ខេបនៃទិន្នន័យសំខាន់ៗ សម្រាប់វិភាគផ្នែកបច្ចេកទេស និងបរិស្ថានមានដូចតទៅៈ

-លក្ខណៈភូមិសាស្ត្ររបស់តំបន់គម្រោង គឺស្ថិតនៅក្នុងតំបន់ចន្លោះជួរភ្នំក្រវាញ ដែលតំបន់អាងមានសណ្ឋាន U និង V ដែលមានជម្រាលពី៥ ទៅ១៥ អង្សា។

-ប្រភេទដីនៅក្នុងតំបន់គម្រោង មាន២ប្រភេទគឺ Acid Lithosols និង Red-yellow Podzols

-យោងតាមលក្ខណៈភូគព្ភសាស្ត្រ គម្រោងនេះក្រោងកម្រិតរញ្ជួយដី ប្រភេទ IV។

-បរិមាណទឹកភ្លៀងធ្លាក់ជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេល១២ឆ្នាំ មាន១៣៧២.៩មម។ ទឹកភ្លៀងធ្លាក់ខ្លាំងជាងគេមានកម្រិត ៤៥៤.៦ មម នៅខែតុលាឆ្នាំ២០០៣ ហើយខែដែលមិនមានភ្លៀងធ្លាក់គឺខែមករា ដល់ខែកុម្ភៈ។

-មធ្យមភាគសីតុណ្ហភាពរយៈពេល១ឆ្នាំមានកម្រិត ២៨,៤៥°C។ មធ្យមភាគសីតុណ្ហភាពអតិបរមារយៈពេល១ឆ្នាំមានកម្រិត ៣៣,៧°C។ មធ្យមភាគសីតុណ្ហភាពអតិប្បបរមារយៈពេល១ឆ្នាំមានកម្រិត ២៣,២°C។ សីតុណ្ហភាពអតិបរមារយៈពេល១៣ឆ្នាំមានកម្រិត ៣៩,៨°C នៅឆ្នាំ២០១០។

- ល្បឿនខ្យល់បក់ជាមធ្យម ក្នុងរយៈពេល១៥ឆ្នាំ គឺ ៤ម/វិនាទី។ ល្បឿនខ្យល់ខ្លាំងជាងគេ នៅខែមិនា កក្កដា សីហា និងវិច្ឆិកា ដែលមានល្បឿនមធ្យម ៧ម/វិនាទី។
- សំណើមបរិយាកាសជាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេល១៣ឆ្នាំ មាន៨១% សំណើមខ្ពស់បំផុតគឺនៅខែកញ្ញា និងតុលា ឆ្នាំ២០០៧។
- រំហួតមធ្យមប្រចាំឆ្នាំនៃរយៈពេល ៥ឆ្នាំ មាន ១៤៣០,១៨មម។

- គុណភាពខ្យល់នៅក្នុងតំបន់គម្រោង ក្នុងដំណាក់កាលមុនសាងសង់គម្រោង ស្ថិតក្រោមស្តង់ដាររបស់ក្រសួងបរិស្ថាន។
- គុណភាពសំឡេងនៅក្នុងតំបន់គម្រោង ក្នុងដំណាក់កាលមុនសាងសង់គម្រោងស្ថិតក្រោមស្តង់ដារ របស់ក្រសួងបរិស្ថានលើកលែងតែនៅម៉ោង៥ទៅម៉ោង៦ព្រឹកលើសស្តង់ដារតិចតួចដោយសារមានរថយន្តបើកកាត់ក្បែរនោះ។
- គុណភាពរំញ័រក្នុងតំបន់គម្រោង ក្នុងដំណាក់កាលមុនសាងសង់គម្រោងស្ថិតក្រោមស្តង់ដាររបស់ក្រសួងបរិស្ថាន។
- ស្ទឹងពោធិ៍សាត់ មានប្រភពពីទឹកភ្លៀង ដែលក្នុងតំបន់ផ្ទៃរងទឹកភ្លៀង(គិតត្រឹមកន្លែងសាងសង់ទំនប់) មានទំហំ ១.២៦៣,៣ គម²។ នៅឆ្នាំ២០១០ ស្ទឹងនេះមានធារទឹកអតិបរមា ៣៨៩,២ ម³/វិនាទី ដែលមានជម្រៅ៦ម ហើយនៅឆ្នាំ ១៩៨១ និងឆ្នាំ២០០៦ ស្ទឹងនេះមានធារទឹកអប្បបរមា 0,៦ ម³/វិនាទី ដែលមានជម្រៅជ្រៅបំផុត១ម។
- គុណភាពទឹកលើដី ខាងលើទីតាំងទំនប់ ក្នុងដំណាក់កាលមុនសាងសង់គម្រោង មានប៉ារ៉ាម៉ែត្រខ្លះដូចជា Fe, Mn, Turbidity និង Totoal coliform លើសស្តង់ដាររបស់ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម។
- គុណភាពទឹកលើដី ខាងក្រោមទីតាំងថាមពល ក្នុងដំណាក់កាលមុនសាងសង់គម្រោង មានប៉ារ៉ាម៉ែត្រខ្លះដូចជា Fe, Mn, Turbidity និង Totoal coliform លើសស្តង់ដាររបស់ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម។
- គុណភាពទឹកក្រោមដី នៅក្បែរតំបន់គម្រោង ក្នុងដំណាក់កាលមុនសាងសង់គម្រោង មានប៉ារ៉ាម៉ែត្រខ្លះដូចជា Turbidity, Conductivity និង Totoal coliform លើសស្តង់ដាររបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

៩.១.២ ធនធានជីវសាស្ត្រ (Biological Resources)

៩.១.២.១ ព្រៃឈើ (Forestry)

ក្រុមការងារបានចែកតំបន់គម្រោង ៩.៣៥៥ ហ.ត ជាបួនផ្នែក ដូចតទៅ:

1. តំបន់ ១ គឺផ្ទៃអាង មានទំហំ ៨.៥៩១ ហ.ត។
2. តំបន់ ២ គឺ តំបន់សាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី មានទំហំ ៥៥៩,៩១ ហ.ត។
3. តំបន់ ៣ គឺ តំបន់តាមគន្លង ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គ.វ៉ មានទំហំ ១៣,៦៤ ហ.ត។
4. តំបន់ ៤ គឺកន្លែងតាំងលំនៅឋានថ្មីរបស់អ្នករងការប៉ះពាល់ដោយសារគម្រោងមានទំហំ ១៩០,៤៥ ហ.ត និងបំរុង ៥0 ហ.ត។

យោងតាមផែនទីគម្រប ព្រៃឈើរបស់រដ្ឋបាលព្រៃឈើ (GIS Datasets FA 2010 មាត្រដ្ឋាន១/1.000.000) រួមទាំងតាមរូបភាពថតពីលើអាកាស ដែលមាន Resolution 1m year 2005 និង យោងការចុះធ្វើការសិក្សាផ្ទាល់ របស់ក្រុមការងារ SAWAC (ធ្វើបច្ចុប្បន្នភាពឆ្នាំ២០១៧) បានបង្ហាញថាតំបន់គម្រោងនេះ ដែលមានផ្ទៃដីសរុបចំនួន៩.៣៥៥ហ.ត មាន ប្រភេទព្រៃឈើដូចតទៅ:

១-ដីព្រៃឈើ ដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង

តំបន់១: ដីព្រៃឈើដែលប៉ះពាល់ដោយសារអាងស្តុកទឹក.ចំនួន ៥.៨៣៥,៦ ហ.ត

- ព្រៃស្រោង	៧៣៥	ហ.ត
- ព្រៃពាក់កណ្តាលស្រោង	៨៤៧,៦០	ហ.ត
- ព្រៃល្បោះ	៤.២៥៣	ហ.ត

តំបន់២: ដីព្រៃដែលដីដែលប៉ះពាល់ដោយសារសាងសង់ហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីផ្សេងៗ.ចំនួន ១២០,២៥ ហ.ត

- ព្រៃស្រោង	១១៩,១៨	ហ.ត
- ព្រៃពាក់កណ្តាលស្រោង	១,០៧	ហ.ត

តំបន់៣: ដីព្រៃដែលដីដែលប៉ះពាល់ដោយសារសាងសង់ខ្សែបញ្ជូនអគ្គិសនីខ្ពស់២៣០kV ចំនួន ១២.៨៩ហ.ត

- ព្រៃស្រោង	១១.៣១	ហ.ត
- ព្រៃពាក់កណ្តាលស្រោង	១.៥៨	ហ.ត

តំបន់៤: ដីព្រៃដែលដីដែលប៉ះពាល់ដោយសារសាងសង់កន្លែងតាំងលំនៅឋានថ្មី ចំនួន ៣៨,៥០ ហ.ត

- ព្រៃល្បោះ ៣៨,៥០ ហ.ត

<u>សរុបផ្ទៃដីព្រៃឈើដែលនឹងត្រូវប៉ះពាល់(តំបន់១+តំបន់២+តំបន់៣+តំបន់៤): ៦.០០៧,២៤ ហ.ត</u>

សម្គាល់: *ចំពោះផ្ទៃដីនៅសល់ ២.៩១៦,៥៩ហ.ត គឺ ជាដីព្រៃសហគមន៍ ផ្លូវ វាលស្មៅ ផ្ទាំងថ្ម ស្ទឹង និង ដីប្រជាជន និងដីព្រៃមិនសម្អាតតាមទំនៃល ៤៣១,១៧ ហ.ត ហើយប្រភេទផ្ទៃដីលម្អិតតាម តំបន់នីមួយៗ មានចែងក្នុងតារាងលេខ ២៥ក , ២៥ខ, ២៥គ, ២៥ឃ, ខាងក្រោម)។*

<u>តារាង ៥-១៩</u>: ទំហំ និងប្រភេទផ្ទៃដីដែលនឹងប៉ះពាល់ដោយសារគម្រោងនៅ តំបន់១ (ធ្វើបច្ចុប្បន្នភាពឆ្នាំ ២០១៧)

No.	Landuse Type	Area (ha)	Remark
1	ដីកសិកម្ម Agriculture Land (productive Land)	932.1	
2	ដីបុស្ស (Bos Land)	1,068.39	
3	ដីលំនៅឋាន (Residential Land)	38.4	
4	ដី បម្រុង យោធា (Reserved for Army Land)	290.29	
5	ដីសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី	9,89	Forest Area include with 7,8,9,10
6	ដីសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង	341.73	Forest Area include with 7,8,9,10
	Total affected forest in zone-1	**5,835.60**	Total affected forest in zone-1=7+8+9
7	ព្រៃស្រោង (Evergeen forest (EF))	735	
8	ព្រៃពាក់កណ្ដាលស្រោង (Semi-Evergreen forest (SE))	847.6	
9	ព្រៃល្បោះ (Deciduous forest (DF))	4253	
10	ផ្លូវNR55/ ផ្លូវរទេះ (NR55/Oxcart Road)	73.22	
11	ដីស្ទឹង/អូរ	169	
12	ដីឈូសឆាយដោយក្រុមហ៊ុនកូរ៉េ NEO VISION Agriculture	184	
	Total Area	**<u>8,591.00</u>**	Total =1+2+3+4+7+8+9+10+11+12

<u>តារាង ៥-២០</u>: ទំហំ និងប្រភេទផ្ទៃដីដែលមាននៅក្នុងទីតាំងគម្រោងនៅ តំបន់២ (ធ្វើបច្ចុប្បន្នភាពឆ្នាំ ២០១៧)

No.	Landuse Type	Area (ha)	Remark
	Total affected forest in zone-2	120.25	1+2+3
1	ព្រៃស្រោង EF	119.18	
2	ព្រៃពាក់កណ្ដាលស្រោង SE	1.07	
3	ព្រៃល្បោះ DF	0	
4	ផ្លូវ/ ផ្លូវរទេះ (Road/Oxcart Road)	0.83	
5	ដីស្ទឹង/អូរ	7.66	
6	ដីមិនសម្អាតព្រៃ (None-Cleared Forest)	431.17	
	Total Area	**559.91**	Total =1+2+3+4+5+6

<u>តារាង ៥-២១</u>: ទំហំ និងប្រភេទផ្ទៃដីដែលមាននៅក្នុងទីតាំងគម្រោងនៅ តំបន់៣ (ធ្វើបច្ចុប្បន្នភាពឆ្នាំ ២០១៧)

No.	Landuse Type	Area (ha)	Remark
	Total affected forest in zone-3	12.89	1+2+3
1	ព្រៃស្រោង EF	11.31	
2	ព្រៃពាក់កណ្ដាលស្រោង SE	1.58	
3	ព្រៃល្បោះ DF	0	
4	ផ្លូវ/ ផ្លូវរទេះ (Road/Oxcart Road)	0.03	
5	ដីស្ទឹង/អូរ	0.72	
6	ដីមិនសម្អាតព្រៃ (None-Cleared Forest)	0	
	Total Area	**13.64**	Total =1+2+3+4+5+6

<u>តារាង ៥-២២</u>: ទំហំ និងប្រភេទផ្ទៃដីដែលមាននៅក្នុងទីតាំងគម្រោងនៅ តំបន់៤

No.	Landuse Type	Area (ha)	Remark
1	None forest area	150.88	
2	Total affected forest in zone-4	38.5	3+4+5

No.	Landuse Type	Area (ha)	Remark
3	ព្រៃស្រោង EF	0	
4	ព្រៃពាក់កណ្ដាលស្រោង SE	0	
5	ព្រៃល្បោះ DF	38.5	
6	ផ្លូវ/ ផ្លូវរទេះ (Road/Oxcart Road)	0.82	
7	ដីស្ទឹង/អូរ	0.25	
	Total Area	190.45	Total =1+3+4+5+6+7

សម្គាល់: *តារាង ៥-១៩, ៥-២០, ៥-២១, ៥-២២ សិក្សាបញ្ជាក់ម្តងទៀតក្នុងឆ្នាំ២០១៧។ ម្ចាស់គម្រោង នឹងធ្វើផែនការដោះស្រាយផលប៉ះពាល់ របស់គម្រោង នៅ ឆ្នាំ២០១៧ ដែលមានការប្រែប្រួល ខុសគ្នាពីឆ្នាំ២០១៥ប្រមាណ៣ដង ព្រោះនៅការប្រើប្រាស់ដីរបស់ប្រជាជន ពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើង។*

ការសិក្សារាប់ព្រៃឈើនៅតំបន់ទាំងបួន ដែលប៉ះពាល់ដោយសារគម្រោងមាន ៣០៧គំរូសាក ដោយមួយគំរូសាកមានផ្ទៃ ៥០ម x៥០ម=២៥០០ ម^{២} សិក្សាលើផ្ទៃដីព្រៃឈើសរុប ៧៦,៧៥ហ.ត. អាចធ្វើការសន្និដ្ឋាន ដូចតទៅ (វិធីសាស្ត្រនៃការសិក្សា ព្រៃឈើ មើលក្នុងជំពូក២ ចំណុច ២.២.៣.១):

ក- ប្រភេទព្រៃល្បោះ

ក-១ វត្តមានប្រភេទឈើ

យោងតាមលទ្ធផលវិភាគទិន្នន័យសារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើ បានបង្ហាញថា ក្នុងតំបន់ប្រភេទព្រៃល្បោះនៃគម្រោង អភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានវត្តមានប្រភេទឈើចំនួន ៨៨ប្រភេទ(តារាង ៥-២៣) ដែលក្នុងនោះលប់ទៅដោយប្រភេទឈើធ្លឹក ជាឈើប្រភេទឈើលេខ១ ដែលមានអត្រាលប់ប្រមាណជា 56.04% និងប្រភេទ ឈើលប់បន្ទាប់គឺ ខ្លុង ជាប្រភេទឈើ២ មានអត្រាប្រមាណជា 10.71% សុក្រម ជាប្រភេទឈើលេខ១ មានអត្រាប្រមាណ ជា 9.70% និងឈ្លីក ជាប្រភេទឈើលេខ១ផងដែរ មានអត្រាប្រមាណជា 9.36%។ ក្រៅពីនោះ ឃើញមានប្រភេទឈើបេងមានអត្រាប្រមាណជា 0.19% ជាប្រភេទឈើប្រណីត និង មានដោយកម្រផងដែរ។ លើសពីនេះទៀត ប្រភេទឈើ មានដោយកម្រមានចំនួន ៥ប្រភេទ និងប្រភេទឈើស្ថិតក្នុងចំណាត់ថ្នាក់ IUCN Red List មានចំនួន១២ប្រភេទ។ ដោយឡែក ប្រភេទឈើផ្សេងៗទៀត ជាច្រើនប្រភេទ និងកម្រិតលប់របស់វា គិតជាភាគរយ ដូចមានបង្ហាញលម្អិតក្នុងតារាង បញ្ជីឈ្មោះឈើខាងក្រោមនេះ។

តារាង ៥-២៣: បញ្ជីឈ្មោះឈើក្នុងតំបន់អភិវឌ្ឍគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់ (%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
១	ធ្លឹក	*Shorea obtusa Wall. ex Bl.*	ឈើលេខ១	56.04		LC
២	ខ្លុង	*Dipterocarpus tuberculatus Roxb.*	ឈើលេខ២	10.71		LC
៣	សុក្រម	*Xylia xylocarpa (Roxb.) Taub.*	ឈើលេខ១	9.70		
៤	ឈ្លីក	*Terminalia alata Hey. ex Roth*	ឈើលេខ១	9.36		
៥	មមាំង	*Diospyros ehretioides Wall. ex G.Don*	ឈើក្រៅលំដាប់	1.19		
៦	ក្ទូ	*Dillenia indica L.*	ឈើក្រៅលំដាប់	1.07		
៧	អញ្ចាញ់	*Buchanania reticulata Hance*	ឈើក្រៅលំដាប់	0.75		
៨	រាំងភ្នំ	*Shorea siamensis Miq.*	ឈើលេខ១	0.65		LC

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់ (%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៩	ស្រឡៅ	*Lagerstroemia cochinchinensis Pierre*	ឈើលេខ១	0.50		
១០	ក្មៅនាង	*Cleistanthus tomentosus Hance*	ឈើក្រៅលំដាប់	0.50		
១១	ពពួល	*Vitex pinnata L.*	ឈើលេខ១	0.50		
១២	ទ្រយឹង	*Diospyros pilosanthera Blanco*	ឈើប្រណីត	0.50	ឈើមានដោយកម្រ	
១៣	កណ្ដោល	*Careya arborea Roxb.*	ឈើលេខ៣	0.43		
១៤	ធ្នង់	*Pterocarpus macrocarpus Kurz*	ឈើប្រណីត	0.41		
១៥	កកោះ	*Sindora siamensis Miq.*	ឈើលេខ១	0.41		
១៦	ល្ងៀង	*Cratoxylum formosum (Jack) Benth. & Hook.f. ex Dyer*	ឈើលេខ៣	0.40		
១៧	ស្នួល	*Dalbergia nigrescens Kurz*	ឈើក្រៅលំដាប់	0.39		
១៨	ញព្រៃ	*Morinda coreia Ham.*	ឈើក្រៅលំដាប់	0.39		
១៩	ពពាលខែ	*Terminalia bialata (Roxb.) Steud.*	ឈើក្រៅលំដាប់	0.36		
២០	ពាន់តាឡី	*Lophopetalum wallichii Kurz*	ឈើក្រៅលំដាប់	0.33		
២១	ពោនស្វា	*Spondias pinnata (L.f.) Kurz*	ឈើក្រៅលំដាប់	0.30		
២២	រកា	*Bombax anceps Pierre*	ឈើក្រៅលំដាប់	0.29		
២៣	ក្រឡាំពុក		ឈើក្រៅលំដាប់	0.23		
២៤	ត្រាច	*Dipterocarpus intricatus Dyer*	ឈើលេខ២	0.21		LC
២៥	សង្កែ	*Combretum quadrangulare Kurz*	ឈើក្រៅលំដាប់	0.20		
២៦	ក្ទម្ព	*Mitragyna hirsuta Hav.*	ឈើក្រៅលំដាប់	0.20		
២៧	បេង	*Afzelia xylocarpa (Kurz) Craib*	ឈើប្រណីត	0.19		
២៨	ក្រឡោមក្អុក		ឈើក្រៅលំដាប់	0.19		
២៩	ឈើអែម	*Acacia pennata Willd. subsp. insuavis (Lace) I. Nielsen*	ឈើក្រៅលំដាប់	0.18		
៣០	ផ្ដៃស្រែង	*Cananga latifolia (Hk. f. & Th.) Fin. & Gagnep.*	ឈើក្រៅលំដាប់	0.18		
៣១	ពក្លាប្រើស	*Pterospermum grewiifolium Pierre*	ឈើក្រៅលំដាប់	0.18		
៣២	ភ្លង់	*Memecylon lilacinum Zoll. & Moritz*	ឈើក្រៅលំដាប់	0.17		
៣៣	ព្រីងភ្នំ	*Syzygium sp*	ឈើលេខ៣	0.16		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់ (%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៣៤	ព្រីង	*Syzygium sp*	ឈើលេខ៣	0.16		
៣៥	ផ្ចា	*Acacia harmandiana (Pierre) Gagnep.*	ឈើក្រៅលំដាប់	0.15		
៣៦	គ្រង់	*Aporosa ficifolia Baill.*	ឈើក្រៅលំដាប់	0.15		
៣៧	ស្លែង	*Strychnos nux-vomica L.*	ឈើក្រៅលំដាប់	0.13		
៣៨	កន្ទួតព្រៃ	*Phyllanthus emblica L.*	ឈើក្រៅលំដាប់	0.12		
៣៩	អង្កត់ខ្មៅ	*Diospyros venosa Wall. ex A.DC.*	ឈើប្រណិត	0.11	ឈើមានដោយកម្រ	
៤០	ត្របែកព្រៃ	*Lagerstroemia floribunda Jack*	ឈើក្រៅលំដាប់	0.10		
៤១	ស្តុកស្តោ	*Walsura trichostemon Miq.*	ឈើក្រៅលំដាប់	0.09		
៤២	រាជកុល	*Erythophleum succirubrum Gagnep.*	ឈើក្រៅលំដាប់	0.09		
៤៣	ព្រះខ្ពៅ	*Terminalia nigrovenulosa Pierre*	ឈើក្រៅលំដាប់	0.09		
៤៤	ត្រសេក	*Peltophorum dasyrhachis (Miq.) Kurz*	ឈើលេខ១	0.09		
៤៥	ក្តុមភ្នំ	*Mitragyna speciosa (Korth) Havil.*	ឈើក្រៅលំដាប់	0.09		
៤៦	ត្បែង	*Dipterocarpus obtusifolius Teijsm.*	ឈើលេខ២	0.09		LC
៤៧	តាឡាត់	*Vatica philastreana, Pierre*	ឈើលេខ២	0.09		
៤៨	គគីរក្នង	*Shorea hypochra Hance*	ឈើលេខ២	0.09		CR
៤៩	ដង្កៀបក្តាម	*Antidesma ghaesembilla Gaertn.*	ឈើក្រៅលំដាប់	0.08		
៥០	ស្រម៉	*Terminalia chebula Retz.*	ឈើក្រៅលំដាប់	0.07		
៥១	មៀនព្រៃ	*Euphoria fragifera Gagnep.*	ឈើក្រៅលំដាប់	0.07		
៥២	ពពេល	*Shorea roxburghii G. Don*	ឈើលេខ១	0.07		
៥៣	ពក្វា	*Microcos tomentosa Sm.*	ឈើក្រៅលំដាប់	0.06		
៥៤	ជ្រៃ	*Ficus rumphii Bl.*	ឈើក្រៅលំដាប់	0.06		
៥៥	ភ្វាស	*Memecylon scutellatum (Lour.) Hook. & Arn.*	ឈើក្រៅលំដាប់	0.05		
៥៦	ច្រេស	*Albizia lebbeck (L.) Benth.*	ឈើប្រណិត	0.05		
៥៧	ក្តុល	*Nauclea orientalis (L.) L.*	ឈើលេខ៣	0.05		
៥៨	អន្ទង់ស	*Eurycoma longifolia*	ឈើក្រៅលំដាប់	0.04		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់ (%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៥៩	រវៀង	*Catunaregam tomentosa (Bl. ex DC.) Tirv.*	ឈើក្រៅលំដាប់	0.04		
៦០	ក្រឡាញ់	*Dialium cochinchinense Pierre*	ឈើលេខ១	0.04		NT
៦១	ទ្រដង		ឈើលេខ៣	0.04		
៦២	ចំបក់	*Irvingia malayana Oliv. ex Benn.*	ឈើក្រៅលំដាប់	0.04		LC
៦៣	ហៃសាន	*Senna garrettiana (Craib) Irwin & Barneby*	ឈើប្រណីត	0.03	ឈើមានដោយកម្រ	
៦៤	ផ្ចឹក	*Anisoptera costata Korth.*	ឈើលេខ២	0.03		EN
៦៥	ទំពូង	*Croton poilanei Gagnep.*	ឈើក្រៅលំដាប់	0.03		
៦៦	ឈើជ័រ	*Strophanthus caudatus Kurz*	ឈើក្រៅលំដាប់	0.03		
៦៧	អង្គារសិល្ប	*Ochna integerrima (Lour.) Merr.*	ឈើក្រៅលំដាប់	0.02		
៦៨	ស្តៅភ្នំ	*Aglaia leptantha Miq.*	ឈើក្រៅលំដាប់	0.02		NT
៦៩	បង្គងក្អែក		ឈើក្រៅលំដាប់	0.02		
៧០	តាត្រាវ	*Fagraea fragrans Roxb.*	ឈើប្រណីត	0.02	ឈើមានដោយកម្រ	
៧១	រង	*Garcinia hanburyi Hook. f.*	ឈើក្រៅលំដាប់	0.01		
៧២	ពពូលថ្ម	*Vitex glabrata R. Br.*	ឈើលេខ១	0.01		
៧៣	គគីត	*Semecarpus cochinchinensis Engl.*	ឈើក្រៅលំដាប់	0.01		
៧៤	កប្បាសព្រៃ	*Mallotus paniculatus Müll. Arg.*	ឈើក្រៅលំដាប់	0.01		
៧៥	ព្រលប់		ឈើក្រៅលំដាប់	0.01		
៧៦	ស្វាយព្រៃ	*Mangifera cochinchinensis Engl.*	ឈើលេខ៣	0.01		
៧៧	ស្មាច់ដោម	*Syzygium zeylanicum (L.) DC.*	ឈើក្រៅលំដាប់	0.01		
៧៨	ស្លួយ		ឈើក្រៅលំដាប់	0.01		
៧៩	ព្រីងស្រទាប់	*Syzygium sp*	ឈើលេខ៣	0.01		
៨០	បាក់ដោក	*Siphonodon celastrineus Griff.*	ឈើក្រៅលំដាប់	0.01		LC
៨១	ដកព	*Markhamia stipulata (Wall.) Seem.*	ឈើក្រៅលំដាប់	0.01		
៨២	ឈើក្មៀង	*Diospyros undulata Well. ex. G. Don.*	ឈើក្រៅលំដាប់	0.01		
៨៣	ឈើទាល	*Dipterocarpus alatus Roxb. & G.Don*	ឈើលេខ២	0.01		EN

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់ (%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៨៤	គ្រើល	*Gluta laccifera (Pierre) Ding Hou*	ឈើក្រៅលំដាប់	0.01	ឈើមានដោយកម្រ	
៨៥	ខ្វាវ	*Haldina cordifolia (Roxb.) Rids.*	ឈើលេខ២	0.01		
៨៦	ក្រូចព្រៃ	*Atalantia citroides Pierre ex Guill.*	ឈើក្រៅលំដាប់	0.01		
៨៧	ក្រាយ	*Xylopia vielana Pierre*	ឈើក្រៅលំដាប់	0.01		
៨៨	ក្រខុបព្រៃ	*Flacourtia indica (Burm. f.) Merr.*	ឈើក្រៅលំដាប់	0.01		

- LC :Least Concern
- CR :Critically Endangered
- NT :Near Threatened
- EN :Endangered (ប្រភេទកំពុងរងគ្រោះ)

ក-២ បរិមាណធនធានឈើឈរមធ្យមប៉ាន់ស្មាន

យោងតាមលទ្ធផលវិភាគទិន្នន័យសារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើបានបង្ហាញថា ក្នុងតំបន់ព្រៃល្បោះនៃគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានចំនួនដើម និងមាឌឈើមធ្យមប៉ាន់ស្មានតាមថ្នាក់អង្កត់ផ្ចិត និងថ្នាក់ប្រភេទឈើនៃគ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី ១០សង់ទីម៉ែត្រឡើងទៅ ស្មើនឹង៤៩២ដើមក្នុង១ហ.ត ស្មើនឹង ៩៥,៣១m^3 ក្នុង១ហ.ត ក្នុងនោះប្រភេទឈើប្រណីត មានចំនួន៧ដើមក្នុង១ហ.ត ស្មើនឹង១,២៥ m^3ក្នុង១ហ.ត ឈើលេខ១មានចំនួន៣៨៦ដើមក្នុង១ ហ.ត ស្មើនឹង៧៦,០៦m^3ក្នុង១ហ.ត ឈើលេខ២មានចំនួន៥៨ដើម ក្នុង១ហ.ត ស្មើនឹង ១១,៥៧ m^3 ក្នុង១ហ.ត ឈើលេខ៣ មានចំនួន៥ដើមក្នុង១ហ.ត ស្មើនឹង០,៨៩m^3ក្នុង១ហ.ត និងឈើក្រៅ លំដាប់មានចំនួន៣៦ដើមក្នុង១ហ.ត ស្មើនឹង៥,៥៤m^3 ក្នុង១ហ.ត (តារាង ៥-២៣)។

តារាង ៥-២៤: ចំនួនដើម និងមាឌឈើមធ្យមក្នុង០១ហ.ត តាមថ្នាក់ប្រភេទ និងថ្នាក់អង្កត់ផ្ចិត ក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់

ថ្នាក់អង្កត់ផ្ចិត	សរុប		ឈើប្រណីត		ឈើលេខ១		ឈើលេខ២		ឈើលេខ៣		ឈើក្រៅលំដាប់	
ស.ម	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត
10'-29	395	47.95	7	0.94	304	36.28	47	6.06	4	0.49	33	4.18
≥ 30	97	47.36	1	0.31	82	39.78	10	5.51	1	0.40	3	1.36
សរុប	**492**	**95.31**	**7**	**1.25**	**386**	**76.06**	**58**	**11.57**	**5**	**0.89**	**36**	**5.54**

ក-៣ បរិមាណសន្និធិកាបូនប៉ាន់ស្មាន

ផ្អែកតាមលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ***ការប៉ាន់ស្មានបរិមាណសន្និធិកាបូនបានអនុវត្តរូបមន្ត*** Brown,1997 **ដែលជាលទ្ធផលបានបង្ហាញ**ថាក្នុងតំបន់ព្រៃល្បោះ មាន***បរិមាណសន្និធិកាបូន*** មធ្យមនៃប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅស្មើនឹង៨៤,១១តោនក្នុង១ហ.ត។ ផ្ទៃដីព្រៃល្បោះដែលនឹងទទួលរងផលប៉ះពាល់ចំនួន ៤.២៩១,៥០ ហ.ត និងមាន***បរិមាណសន្និធិកាបូន*** នៃប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅ***ប៉ាន់ស្មាន*** ៣៦០.៩៥៨,០៧ តោនទទួលរងផល ប៉ះពាល់ផងដែរ (តារាងទី ៥-២៥)។

តារាង ៥-២៥: សន្និធិកាបូនប៉ាន់ស្មានសរុបនៃផ្ទៃដីរងផលប៉ះពាល់ដោយសារការអភិវឌ្ឍ វារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃល្បោះ)

ថ្នាក់អង្កត់ផ្ចិត	ចំនួនដើម	ចំនួនមាឌឈើ	ជីវម៉ាស់លើដី	ជីវម៉ាស់ក្រោមដី	សរុប(AGB+BGB)	(CF)	សន្និធិកាបូនមធ្យម,ហត	ផ្ទៃដីប៉ះពាល់	សន្និធិកាបូនសរុប
ស.ម	ដើម	មាឌ(m3)	AGB (kg)	BGB(kg)	(Kg)	tonne C	CS(tonne)	ហ.ត	CS(tonne)
10'-29	395	47.95	57,679.41	17,303.82	74,983.23	0.49	36.74	4291.50	157,669.71
≥ 30	97	47.36	74,366.68	22,310.00	96,676.68	0.49	47.37	4291.50	203,288.36
សរុប	**492**	**95.31**	**132,046.09**	**39,613.82**	**171,659.91**		**84.11**		**360,958.07**

កំណត់សម្គាល់ BGB=30%AGB
CF=Carbon fraction
CS= Carbon Stock

ក-៤ ប្រភេទរុក្ខជាតិបន្តពូជ

យោងតាមទិន្នន័យសារពើភ័ណ្ឌបានបង្ហាញថា ក្នុងតំបន់ព្រៃល្បោះនៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ ឃើញមានប្រភេទរុក្ខជាតិបន្តពូជចំនួន៩៦ប្រភេទរួមមាន គកោះ កណ្ដោល កន្ទុយវេ កន្ទួតព្រៃ កន្ទ្រោបដំរី កប្បាសព្រៃ គួយ ក្ដុល ក្ទម្ព ក្ទម្ពភ្នំ ក្រខុបព្រៃ ក្រចកចាប ក្រឡាំពៃ ក្រពុលបាយ ក្រឡាញ់ ក្រឡោមភ្លុក ក្រាយ ក្រូចព្រៃ ខ្លុង គគីត គគីរភ្នង គ្រង់ គ្រើល ចារ ច្រេស ឆ្កែស្រែង ជ្រៃ ឈ្លីក ឈើជ័រ ឈើអែម ឈ្លីក ញព្រៃ ដកព ដង្កៀបក្ដាម តាឡាត់ ត្បែង ត្រយឹង ត្រចុក ត្របែកព្រៃ ត្រយឹង ត្រសេក ត្រាច ទ្រនំកំភេម ទ្រមែង ធ្នង់ ធ្នា ធ្មេញត្រី នប់ ប៉ប្រើស បាក់ដោក បាយក្ដាំង បេង ប្រង់ ផ្ចឹក ផ្តៀក ផ្នុង ពង្រ ពពាលខែ ពពូល ពភ្លា ពភ្លាប្រើស ពាន់តាឡី ពោន ពោនស្វា ព្រាល ព្រីង ព្រីងភ្នំ ភ្ញៀវ ភ្លូង ភ្លូ ភ្លូបាត ភ្លៅនាង មមាំង មៀនព្រៃ រកា រវៀង រាជកុល រាំងភ្នំ លៀង សង្កែ សុក្រម ស្លែង ស្លួយ ស្តុកស្តោ ស្នាយ ស្រគុំ ស្រម៉ ស្រឡៅ ស្លែង សំលៀង សំឡាញ អង្កត់ខ្មៅ អង្គារសិល្ប អង្រ្កង អញ្ចាញ និងអន្ទង់ស។

ក-៥ ប្រភេទវល្លិ៍ និងស្មៅ: វ.ជុយ, វ.ចាក់សែង, វ.ដំឡូងជ្រូក, វ.ប៉ប្រើស, វ.អំបុក, វ.បន្លាសុខ័រ, វ.ត្រដឹត, វ.ស្លែង, វ.ថ្លឹង, វ.ពពាយ, វ.ខ្មែរ, វ.អណ្ដាតគោ, វ.ជង្គង់គោ, វ.អំពិល, វ.ឃ្លោក, វ.អង្រ្កង, វ.ទឹក, វ.អណ្ដាតត្រកួត, វ.កំបោរ, វ.ធ្លក, វ.អាវេច, វ.ប្រេង់, វ.ក្រឡាំពៃ, វ.ទំពាំងបាយជូរ, វ.ក្រិច, វ.ឃ្លៀក, វ.ដំឡូងទឹក, វ.ដំឡូងទាន, វ.ស្លែងពណ៌, វ.អាណោល, វ.ចារ, ស្បូវឃ្លាំង, ស្មៅតាសិត, ពពាលព្រៃ, ក្រចុក, ព្រាល, ប្រោសស្វា, ទឹកដោះខ្លា, ដូងព្រះ, ត្រែង, រំដេងព្រៃ, យិនស៊ិន, ដង្ហិត, បាតផ្តិល, ប្រង់, កំពីងដូង, បាក់ដោក, ក្តកំប្រុក, ក្លាំងបាយ, មើមថ្នាំចិន, កំភ្លឹង, ចាហួយ។

ក-៦ ប្រភេទឬស្សី និងពពួកស្មៅ: ឬស្សីព្រិច, ឬស្សីថ្ង ។

ក-៧ ប្រភេទតាលព្រឹក្ស: សំឡាញ, ផ្តៅ។

ខ- ប្រភេទព្រៃស្រោង

ខ-១ វត្តមានប្រភេទឈើ

យោងតាមលទ្ធផលវិភាគទិន្នន័យសារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើ បានបង្ហាញថា ក្នុងតំបន់ប្រភេទព្រៃស្រោង នៃគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានវត្តមានប្រភេទឈើចំនួន៩៦ប្រភេទ (តារាង៥-២៦)ដែលក្នុងនោះលប់ទៅដោយប្រភេទស្រឡៅជាប្រភេទឈើលេខ១ ដែលមានអត្រាលប់ប្រមាណជា 12.96% និងប្រភេទឈើលប់បន្ទាប់ គឺសេមាន់ ជាប្រភេទឈើក្រៅលំដាប់ មានអត្រាប្រមាណជា 7.83% ត្រសេកជាប្រភេទឈើលេខ១មានអត្រាប្រមាណជា 4.54% និងគគីរខ្សាច់ជាប្រភេទឈើលេខ២ មានអត្រាប្រមាណជា 3.91%។ ក្រៅពីនោះ ឃើញមានប្រភេទឈើ ធ្នង់មានអត្រាប្រមាណជា 0.63% និងប្រភេទឈើនាងនួនមាន អត្រាប្រមាណជា 0.04% ជាប្រភេទឈើប្រណីត និងមានដោយកម្រផងដែរ។ លើសពីនេះទៀត ប្រភេទឈើមានដោយកម្រមាន ចំនួន ៧ប្រភេទ និងប្រភេទឈើស្ថិតក្នុងចំណាត់ថ្នាក់ IUCN Red List មានចំនួន ១៤ប្រភេទ។ ដោយឡែក ប្រភេទឈើផ្សេងៗទៀត ជាច្រើនប្រភេទ និងកម្រិតលប់របស់វាគិតជាភាគរយ ដូចមានបង្ហាញលម្អិតក្នុងតារាងបញ្ជីឈ្មោះឈើខាងក្រោមនេះ។

តារាង ៥-២៦: បញ្ជីឈ្មោះឈើក្នុងតំបន់អភិវឌ្ឍគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃស្រោង)

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
១	ស្រឡៅ	*Lagerstroemia cochinchinensis Pierre*	ឈើលេខ១	12.96		
២	សេមាន់	*Xerospermum noronhianum (Bl.) Bl.*	ឈើក្រៅលំដាប់	7.83	.	
៣	ត្រសេក	*Peltophorum dasyrhachis (Miq.) Kurz*	ឈើលេខ១	4.54		
៤	គគីរខ្សាច់	*Hopea pierrei Hance*	ឈើលេខ២	3.91		EN
៥	ចំបក់	*Irvingia malayana Oliv. ex Benn.*	ឈើក្រៅលំដាប់	3.60		LC

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៦	ព្រះពៅ	*Terminalia nigrovenulosa Pierre*	ឈើក្រៅលំដាប់	3.33		
៧	ជ្រៃ	*Ficus rumphii Bl.*	ឈើក្រៅលំដាប់	3.15		
៨	ឈើទាល	*Dipterocarpus alatus Roxb. & G.Don*	ឈើលេខ២	2.97		EN
៩	អង្កត់ខ្មៅ	*Diospyros venosa Wall. ex A.DC.*	ឈើប្រណីត	2.65	ឈើមានដោយកម្រ	
១០	នាងផ្អែក	*Dehaasia cuneata (Bl.) Bl.*	ឈើលេខ២	2.52		
១១	សុក្រម	*Xylia xylocarpa (Roxb.) Taub.*	ឈើលេខ១	2.34		
១២	កកោះ	*Sindora siamensis Miq.*	ឈើលេខ១	2.34		
១៣	ភ្លូង	*Memecylon lilacinum Zoll. & Moritz*	ឈើក្រៅលំដាប់	2.20		
១៤	ផ្ដៀក	*Anisoptera costata Korth.*	ឈើលេខ២	2.20		EN
១៥	ត្របៀកស្វា	*Symplocos caudata Wall. ex G. Don*	ឈើក្រៅលំដាប់	2.07		
១៦	ស្នាក្របី	*Knema globularia (Lam.) Warb.*	ឈើលេខ៣	1.84		LC
១៧	គ្រង់	*Aporosa ficifolia Baill.*	ឈើក្រៅលំដាប់	1.84		
១៨	រាជកុល	*Erythophleum succirubrum Gagnep.*	ឈើក្រៅលំដាប់	1.80		
១៩	ជ្រែស	*Albizia lebbeck (L.) Benth.*	ឈើប្រណីត	1.71		
២០	តាឡាត់	*Vatica philastreana, Pierre*	ឈើលេខ២	1.66		
២១	ល្ងៀង	*Cratoxylum formosum (Jack) Benth. & Hook.f. ex Dyer*	ឈើលេខ៣	1.62		
២២	ផ្អុង	*Calophyllum inophyllum L.*	ឈើលេខ៣	1.53		LC
២៣	ព្រូស	*Garcinia schefferi Pierre*	ឈើលេខ៣	1.35		
២៤	ទ្រយឹង	*Diospyros pilosanthera Blanco*	ឈើប្រណីត	1.35	ឈើមានដោយកម្រ	
២៥	ពាន់តាឡី	*Lophopetalum wallichii Kurz*	ឈើក្រៅលំដាប់	1.12		
២៦	ខោស	*Castanopsis pyriformis Hickel & A. Camus*	ឈើក្រៅលំដាប់	1.12		
២៧	ពពាលខែ	*Terminalia bialata (Roxb.) Steud.*	ឈើក្រៅលំដាប់	1.08		
២៨	ពពូល	*Vitex pinnata L.*	ឈើលេខ១	0.94		
២៩	ធ្នូក	*Parinari anamensis Hance*	ឈើលេខ៣	0.94		
៣០	ក្រាយ	*Xylopia vielana Pierre*	ឈើក្រៅលំដាប់	0.90		
៣១	ស្ពួល	*Dalbergia nigrescens Kurz*	ឈើក្រៅលំដាប់	0.85		
៣២	រកា	*Bombax anceps Pierre*	ឈើក្រៅលំដាប់	0.85		
៣៣	ពព្លា	*Microcos tomentosa Sm.*	ឈើក្រៅលំដាប់	0.81		
៣៤	ក្រូចព្រៃ	*Atalantia citroides Pierre ex Guill.*	ឈើក្រៅលំដាប់	0.81		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៣៥	ពក្លាប្រើស	Pterospermum grewiifolium Pierre	ឈើគ្រៅលំដាប់	0.76		
៣៦	គគីត	Semecarpus cochinchinensis Engl.	ឈើគ្រៅលំដាប់	0.72		
៣៧	ពពេល	Shorea roxburghii G. Don	ឈើលេខ១	0.67		
៣៨	រំដួល	Melodorum fruticosum Lour.	ឈើគ្រៅលំដាប់	0.63		
៣៩	ភ្លូ	Dillenia indica L.	ឈើគ្រៅលំដាប់	0.63		
៤០	ធ្នង់	Pterocarpus macrocarpus Kurz	ឈើប្រណីត	0.63	ឈើមានដោយកម្រ	
៤១	តាត្រាវ	Fagraea fragrans Roxb.	ឈើប្រណីត	0.63	ឈើមានដោយកម្រ	
៤២	ទ្រមូងសេក	Suregada multiflora (A. Juss.) Baill.	ឈើគ្រៅលំដាប់	0.58		
៤៣	ក្រឡាញ់	Dialium cochinchinense Pierre	ឈើលេខ១	0.58		NT
៤៤	មៀនព្រៃ	Euphoria fragifera Gagnep.	ឈើគ្រៅលំដាប់	0.54		
៤៥	ស្តៅភ្នំ	Aglaia leptantha Miq.	ឈើគ្រៅលំដាប់	0.49		NT
៤៦	គគីរ	Hopea odorata Roxb.	ឈើលេខ១	0.49		VU
៤៧	ស្វាយព្រៃ	Mangifera cochinchinensis Engl.	ឈើលេខ៣	0.45		
៤៨	រលួស	Erythrina variegata L.	ឈើគ្រៅលំដាប់	0.45		LC
៤៩	ព្រីងស្រទាប់	Syzygium sp	ឈើលេខ៣	0.45		
៥០	ព្រីងភ្នំ	Syzygium sp	ឈើលេខ៣	0.45		
៥១	ផ្កាស្រែង	Cananga latifolia (Hk. f. & Th.) Fin. & Gagnep.	ឈើគ្រៅលំដាប់	0.45		
៥២	ស្តី	Altingia cambodiana H. Lec.	ឈើលេខ១	0.40		
៥៣	រាំងភ្នំ	Shorea siamensis Miq.	ឈើលេខ១	0.36		LC
៥៤	ភ្លៀវ	Baccaurea ramiflora Lour.	ឈើគ្រៅលំដាប់	0.36		
៥៥	ព្រីង	Syzygium sp	ឈើលេខ៣	0.36		
៥៦	ជំពូទឹក		ឈើគ្រៅលំដាប់	0.36		
៥៧	ច្រម៉ាស់	Vatica odorata (Griff.) Sym.	ឈើលេខ២	0.36		
៥៨	មមាំង	Diospyros ehretioides Wall. ex G.Don	ឈើគ្រៅលំដាប់	0.31		
៥៩	ទ្រមែង	Carallia brachiata (Lour.) Merr.	ឈើលេខ៣	0.31		
៦០	ឈើក្មេង	Diospyros undulata Well. ex. G. Don.	ឈើគ្រៅលំដាប់	0.27		
៦១	ក្របៅ	Hydnocarpus anthelminthicus Pierre ex Laness.	ឈើលេខ៣	0.27		
៦២	អង្គុញស្វា	Archidendron quocense (Pierre) I. Nielsen	ឈើគ្រៅលំដាប់	0.22		
៦៣	ស្មាច់ដោម	Syzygium zeylanicum (L.) DC	ឈើគ្រៅលំដាប់	0.22		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៦៤	គ្រៅទាង	Cleistanthus tomentosus Hance	ឈើគ្រៅលំដាប់	0.22		
៦៥	ភ្លូងកែវ	Memecylon caeruleum Jack	ឈើគ្រៅលំដាប់	0.22		
៦៦	ពោនស្វា	Spondias pinnata (L.f.) Kurz	ឈើគ្រៅលំដាប់	0.22		
៦៧	ពង្រ	Schleichera oleosa (Lour.) Merr	ឈើគ្រៅលំដាប់	0.22		
៦៨	ទំពូង	Croton poilanei Gagnep.	ឈើគ្រៅលំដាប់	0.22		
៦៩	បេង	Afzelia xylocarpa (Kurz) Craib	ឈើប្រណិត	0.18	ឈើមានដោយកម្រ	
៧០	បាក់មាត់		ឈើគ្រៅលំដាប់	0.18		
៧១	អង្គារសិល្ប	Ochna integerrima (Lour.) Merr.	ឈើគ្រៅលំដាប់	0.13		
៧២	ស្លែង	Strychnos nux-vomica L.	ឈើគ្រៅលំដាប់	0.13		
៧៣	ស្រម៉	Terminalia chebula Retz.	ឈើគ្រៅលំដាប់	0.13		
៧៤	បាក់ដោក	Siphonodon celastrineus Griff.	ឈើគ្រៅលំដាប់	0.13		LC
៧៥	ឈើខ្មៅ	Diospyros castanea (Craib) Fletcher	ឈើប្រណិត	0.13		
៧៦	គគីរដែក	Hopea helferi (Dyer) Brandis	ឈើលេខ១	0.13		
៧៧	ខ្វាញ់ក្តាម	Ellipanthus tomentosus Kurz	ឈើគ្រៅលំដាប់	0.13		
៧៨	ក្រសាំងភ្នំ	Xanthophyllum sp	ឈើគ្រៅលំដាប់	0.13		
៧៩	កប្បាសព្រៃ	Mallotus paniculatus Müll. Arg.	ឈើគ្រៅលំដាប់	0.13		
៨០	កណ្តោល	Careya arborea Roxb.	ឈើលេខ៣	0.13		
៨១	សំលៀង	Tristania merguensis Griff.	ឈើគ្រៅលំដាប់	0.09		
៨២	ស្លាបប៉ាង	Macaranga triloba (Reinw. ex Bl.) Muell. Arg.	ឈើគ្រៅលំដាប់	0.09		
៨៣	ទ្រាល	Peltophorum dasyrhachis (Miq.) Kurz	ឈើលេខ១	0.09		
៨៤	ញព្រៃ	Morinda coreia Ham.	ឈើគ្រៅលំដាប់	0.09		
៨៥	កូនឃ្មុំ	Dracaena cambodiana Pierre ex Gagnep.	ឈើគ្រៅលំដាប់	0.09		
៨៦	ស្រគុំ	Madhuca bejaudi Aubrév.	ឈើលេខ២	0.04		
៨៧	រាំង	Barringtonia acutangula (L.) Gaertn.	ឈើគ្រៅលំដាប់	0.04		
៨៨	រង្គ	Garcinia hanburyi Hook. f.	ឈើគ្រៅលំដាប់	0.04		
៨៩	ព្រីងបាយ	Syzygium cumini (L.) Skeels	ឈើលេខ៣	0.04		
៩០	នាងនួន	Dalbergia bariensis Pierre	ឈើប្រណិត	0.04	ឈើមានដោយកម្រ	EN
៩១	ត្រាច	Dipterocarpus intricatus Dyer	ឈើលេខ២	0.04		LC
៩២	ត្រយូង	Parkia sumatrana Miq.	ឈើគ្រៅលំដាប់	0.04		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៩៣	ត្របែកព្រៃ	*Lagerstroemia floribunda Jack*	ឈើក្រៅលំដាប់	0.04		
៩៤	ល្បើក	*Terminalia alata Hey. ex Roth*	ឈើលេខ១	0.04		
៩៥	គ្រើល	*Gluta laccifera (Pierre) Ding Hou*	ឈើប្រណីត	0.04	ឈើមានដោយកម្រ	
៩៦	កន្ទួតព្រៃ	*Phyllanthus emblica L.*	ឈើក្រៅលំដាប់	0.04		

- EN :Endangered (ប្រភេទកំពុងរងគ្រោះ)
- VU :Vulnerable (ប្រភេទងាយរងគ្រោះ)
- LC :Least Concern
- NT :Near Threatened

ខ-២ បរិមាណធនធានឈើឈរមធ្យមប៉ាន់ស្មាន

យោងតាមលទ្ធផលវិភាគទិន្នន័យសារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើ បានបង្ហាញថា ក្នុងតំបន់ព្រៃស្រោងនៃគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានចំនួនដើម និងមាឌឈើមធ្យមប៉ាន់ស្មានតាមថ្នាក់អង្កត់ផ្ចិត និងថ្នាក់ប្រភេទឈើនៃគ្រប់ប្រភេទឈើ ដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅ ស្មើនឹង២៨៤ ដើមក្នុង ១ហ.ត ស្មើនឹង៥៩,៥២ ក្នុង១ហ.ត ក្នុងនោះប្រភេទឈើប្រណីត មានចំនួន១៨ដើមក្នុង១ហ.ត ស្មើនឹង៣,៨៤ ក្នុង ១ហ.ត ឈើលេខ១ មានចំនួន១០៧ ដើមក្នុង១ ហ.ត ស្មើនឹង១៩,៤៥ m^3ក្នុង១ហ.ត ឈើលេខ២មានចំនួន២៤ដើម ក្នុង១ហ.ត ស្មើនឹង ៨,៦៧ m^3ក្នុង១ហ.ត ឈើលេខ៣ មានចំនួន២១ដើមក្នុង១ហ.ត ស្មើនឹង៤,៤៧m^3 ក្នុង១ហ.ត និងឈើ ក្រៅលំដាប់មានចំនួន១១៤ ដើមក្នុង១ហ.ត ស្មើនឹង២៣,០៩៨m^3ក្នុង១ហ.ត (តារាង៥-២៧)។

តារាង ៥-២៧: ចំនួនដើម និងមាឌឈើមធ្យមក្នុង០១ហ.ត តាមថ្នាក់ប្រភេទ និងថ្នាក់អង្កត់ផ្ចិត ក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃស្រោង)

ថ្នាក់អង្កត់ផ្ចិត	សរុប		ឈើប្រណីត		ឈើលេខ១		ឈើលេខ២		ឈើលេខ៣		ឈើក្រៅលំដាប់	
ស.ម	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត
10'-29	239	36.89	14	2.11	93	13.09	21	5.32	16	2.63	95	13.74
≥ 30	45	22.63	3	1.73	14	6.36	3	3.35	4	1.84	19	9.35
សរុប	<u>284</u>	<u>59.52</u>	**18**	**3.84**	**107**	**19.45**	**24**	**8.67**	**21**	**4.47**	**114**	**23.09**

ខ-៣ បរិមាណសន្និធិកាបូនប៉ាន់ស្មាន

*ផ្អែកតាមលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់*អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ***ការប៉ាន់ស្មានបរិមាណសន្និធិកាបូនបានអនុវត្តរូបមន្ត*** Brown,1997 **ដែលជាលទ្ធផលបានបង្ហាញថា** ក្នុងតំបន់ព្រៃស្រោង មាន***បរិមាណសន្និធិកាបូន***មធ្យមនៃប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅស្មើនឹង ៧២,៩៦តោនក្នុង១ហ.ត។ ផ្ទៃដីព្រៃស្រោងដែលនឹងទទួលរងផលប៉ះពាល់ចំនួន៨៦៦,១៩ហ.ត និងមាន***បរិមាណសន្និធិកាបូន*** នៃប្រភេទឈើ ដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី ១០សង់ទីម៉ែត្រឡើងទៅ ***ប៉ាន់ស្មាន*** ៦៣.១៩៧,២២តោន ទទួលរងផលប៉ះពាល់ផងដែរ(តារាង ៥-២៨)។

តារាង ៥-២៨: សន្និធិកាបូនប៉ាន់ស្មានសរុបនៃផ្ទៃដីរងផលប៉ះពាល់ដោយសារការអភិវឌ្ឍ វារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃស្រោង)

ថ្នាក់អង្កត់ផ្ចិត	ចំនួនដើម	ចំនួនមាឌឈើ	ជីវម៉ាស់លើដី	ជីវម៉ាស់ក្រោមដី	សរុប(AGB+BGB)	(CF)	សន្និធិកាបូនមធ្យម/ហត	ផ្ទៃដីប៉ះពាល់	សន្និធិកាបូនសរុប
ស.ម	ដើម	មាឌ(m3)	AGB (kg)	BGB(kg)	(Kg)	tonne C	CS(tonne)	ហ.ត	CS(tonne)
10'-29	239	36.89	59,178.78	17,753.63	76,932.42	0.49	37.70	866.19	32,655.36
≥ 30	45	22.63	55,359.63	16,607.89	71,967.52	0.49	35.26	866.19	30,541.86
សរុប	<u>284</u>	<u>59.52</u>	**114,538.41**	**34,361.52**	**148,899.94**		**72.96**		**63,197.22**

កំណត់សម្គាល់: BGB=30%AGB

CF=Carbon fraction

CS= Carbon Stock

ខ-៤ ប្រភេទរុក្ខជាតិបន្តពូជ

យោងតាមទិន្នន័យសារពើភ័ណ្ឌបានបង្ហាញថា ក្នុងតំបន់ស្រោងនៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ ឃើញមានប្រភេទរុក្ខជាតិបន្តពូជចំនួន ៩៦ប្រភេទរួមមាន កកោះ កន្ទួតព្រៃ កន្ទ្រោបដំរី កប្បាសព្រៃ បាយក្ដាំង ក្រពុលបាយ ក្របៅ ក្រវ៉ាន់ ក្រសាំងភ្នំ ក្រាយ ក្រឡាញ់ ក្រូចព្រៃ ខោស ខ្វាស់ ខ្នុរព្រៃ ខ្លាញ់ក្ដាម គគីត គគីរខ្សាច់ គគីរដែក គ្រង់ គ្រើល គ្រៀល ច្រម៉ាស់ ច្រេស ចំបក់ ផ្ដៃស្រែង ជង្គង់សេក ជ្រៃ ជំពូទឹក ជំពូព្រៃ ឈើទាល ឈើភ្លើង ញរព្រៃ ដកព ដង្ហៀបក្ដាម តាឡាត់ ត្បែង ត្រចៀកស្វា ត្របែកព្រៃ ត្រប់ទុំ ទ្រមូង ទ្រមូងសេក ទ្រមែង ត្រយឹង ត្រសេក ទ្រនំកំភេម ទ្រមូង ទំពូង ធ្នង់ ធ្លក នាងផ្អែក បាក់ដោក បាក់មាត់ បាយក្រៀម ដូនចែម ផ្ទឹក ផ្ចៀក ផ្ចុង ពពូល ពពេល ពភ្លា ពភ្លាប្រើស ព្រីង ព្រីងបាយ ព្រីងភ្នំ ព្រីងស្រទាប់ ព្រូស ព្រះពន្លៅ ពាន់តាឡី ភ្លូង ភ្លូងកែវ ភ្លូ ភ្លៅនាង មៀនព្រៃ រកាមមាំង រលួស រាជកុល រាំង រាំងភ្នំ រំដួល លៀង សុក្រម ស្ដី សេមាន់ ស្នួល ស្មាក្របី ស្រឡៅ ស្លាបប៉ាង ស្លែង សំព័រ សំរង សំលៀង អង្កត់ខ្មៅ អង្គារសិល្ប អង្រ្គង។

ខ-៥ ប្រភេទវល្លិ៍ និងស្មៅៈ ផ្ដៅសោម, វ.អំពិល, វ.អន្ទង, វ.អំបោះ, វ.តាអាន, វ.ផុយ, វ.ក្រឡាំពៃ, វ.ចារ, វ.ឈាម, វ.ប្រេង, វ.ចាក់សែង, វ.ស្ទីង, បន្លាសុខ័រ, វ.ដំឡូង, វ.កំបោរ, វ.អំបុក, វ.គ្រៀល, វ.ក្រមួន, វ.ចំពុះសេក, វ.ឃ្លោក, វ.តាហឹង, វ.យៀវ, វ.ប៉ប្រើស, វ.ឃ្លោះ, វ.ជ្រៃ, វ.ចាម, វ.ស្លែងពំណ, វ.ជណ្ដើស្វា, វ.ក្អែប, វ.គ្រដឹក, វ.ឡេវអាវ, វ.ជើងគោ, វ.ត្រជាក់ត្រជុំ, វ.ចាន់, វ.ស្លាបពៃ, វ.អង្គុញ, វ.ស្រែង, វ.តាអើក, វ.អារេច, ព្រាល, ស្មៅតាសិត ។

ខ-៦ ប្រភេទឬស្សី និងពពួកស្មៅៈ ឬស្សីព្រិច, ។

ខ-៧ ប្រភេទតាលព្រឹក្សៈ ស្លាព្រៃ, ផ្ដៅ។

គ- ប្រភេទព្រៃពាក់កណ្ដាលស្រោង

គ-១ វត្តមានប្រភេទឈើ

យោងតាមលទ្ធផលវិភាគទិន្នន័យ សារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើបានបង្ហាញថា ក្នុងតំបន់ប្រភេទព្រៃពាក់កណ្ដាលស្រោង នៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះមានវត្តមានប្រភេទឈើចំនួន៧៦ប្រភេទ(តារាង ៥-២៩) ដែលក្នុងនោះលប់ទៅដោយប្រភេទស្រឡៅជាប្រភេទឈើលេខ១ ដែលមានអត្រាលប់ប្រមាណជា 23.38% និងប្រភេទ ឈើលប់បន្ទាប់គឺសុក្រម ជាប្រភេទឈើលេខ១ មានអត្រាប្រមាណជា 13.13% លៀងជាប្រភេទឈើលេខ៣មានអត្រា ប្រមាណជា 4.59% និងត្រសេកជាប្រភេទឈើ លេខ១មានអត្រាប្រមាណជា 4.04%។ ក្រៅពីនោះ ឃើញមានប្រភេទ ឈើអាជាងមានអត្រាប្រមាណជា 0.09% ជាប្រភេទឈើ ក្រៅលំដាប់សម្រាប់ប្រើប្រាស់ក្នុងសិប្បកម្មចម្លាក់បានល្អប្រសើ។ លើសពីនេះទៀត ប្រភេទឈើមានដោយកម្រមានចំនួន ៣ប្រភេទ និង ប្រភេទឈើស្ថិតក្នុងចំណាត់ថ្នាក់ IUCN Red List មានចំនួន ១២ប្រភេទ។ ដោយឡែក ប្រភេទឈើផ្សេងៗទៀត ជាច្រើនប្រភេទ និងកម្រិតលប់របស់វាគិតជាភាគរយដូចមានបង្ហាញលម្អិតក្នុងតារាងបញ្ជីឈ្មោះឈើខាងក្រោមនេះ។

តារាង ៥-២៩: បញ្ជីឈ្មោះឈើក្នុងតំបន់អភិវឌ្ឍន៍គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃពាក់កណ្ដាលស្រោង)

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
១	ស្រឡៅ	*Lagerstroemia cochinchinensis Pierre*	ឈើលេខ១	23.38		
២	សុក្រម	*Xylia xylocarpa (Roxb.) Taub.*	ឈើលេខ១	13.13		
៣	លៀង	*Cratoxylum formosum (Jack) Benth. & Hook.f. ex Dyer*	ឈើលេខ៣	4.59		LC
៤	ត្រសេក	*Peltophorum dasyrhachis (Miq.) Kurz*	ឈើលេខ១	4.04		
៥	ព្រះពន្លៅ	*Terminalia nigrovenulosa Pierre*	ឈើក្រៅលំដាប់	3.62		
៦	រកា	*Bombax anceps Pierre*	ឈើក្រៅលំដាប់	3.53		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៧	ផ្ចឹក	Shorea obtusa Wall. ex Bl.	ឈើលេខ១	3.29		LC
៨	ត្រយឹង	Diospyros pilosanthera Blanco	ឈើប្រណីត	3.01	ឈើមានដោយកម្រ	
៩	ភ្លង	Memecylon lilacinum Zoll. & Moritz	ឈើក្រៅលំដាប់	2.69		
១០	ស្លួល	Dalbergia nigrescens Kurz	ឈើក្រៅលំដាប់	2.60		
១១	កកោះ	Sindora siamensis Miq.	ឈើលេខ១	2.27		
១២	អង្គត់ខ្មៅ	Diospyros venosa Wall. ex A.DC.	ឈើប្រណីត	2.09	ឈើមានដោយកម្រ	
១៣	ពពាលខែ	Terminalia bialata (Roxb.) Steud.	ឈើក្រៅលំដាប់	1.76		
១៤	ពពូល	Vitex pinnata L.	ឈើលេខ១	1.76		
១៥	ឆ្កែស្រែង	Cananga latifolia (Hk. f. & Th.) Fin. & Gagnep.	ឈើក្រៅលំដាប់	1.72		
១៦	ផ្ដៀក	Anisoptera costata Korth.	ឈើលេខ២	1.67		EN
១៧	នាងផ្អែក	Dehaasia cuneata (Bl.) Bl.	ឈើលេខ២	1.53		
១៨	ពក្វាប្រើស	Pterospermum grewiifolium Pierre	ឈើក្រៅលំដាប់	1.25		
១៩	ព្រីងភ្នំ	Syzygium sp	ឈើលេខ៣	1.11		
២០	ផ្អុង	Calophyllum inophyllum L.	ឈើលេខ៣	1.11		LC
២១	តាឡាត់	Vatica philastreana, Pierre	ឈើលេខ២	1.02		
២២	ស្លែង	Strychnos nux-vomica L.	ឈើក្រៅលំដាប់	0.93		
២៣	ធ្នង់	Pterocarpus macrocarpus Kurz	ឈើប្រណីត	0.93	ឈើមានដោយកម្រ	
២៤	មៀនព្រៃ	Euphoria fragifera Gagnep.	ឈើក្រៅលំដាប់	0.83		
២៥	គគីរ	Hopea odorata Roxb.	ឈើលេខ១	0.83		VU
២៦	ស្មាច់ដោម	Syzygium zeylanicum (L.) DC.	ឈើក្រៅលំដាប់	0.79		
២៧	ស្ដៅភ្នំ	Aglaia leptantha Miq.	ឈើក្រៅលំដាប់	0.79		NT
២៨	ពោនស្វា	Spondias pinnata (L.f.) Kurz	ឈើក្រៅលំដាប់	0.79		
២៩	ពក្វា	Microcos tomentosa Sm.	ឈើក្រៅលំដាប់	0.70		
៣០	គ្រង់	Aporosa ficifolia Baill.	ឈើក្រៅលំដាប់	0.70		
៣១	រាជកុល	Erythophleum succirubrum Gagnep.	ឈើក្រៅលំដាប់	0.65		
៣២	សេមាន់	Xerospermum noronhianum (Bl.) Bl.	ឈើក្រៅលំដាប់	0.60		
៣៣	ក្រឡាញ់	Dialium cochinchinense Pierre	ឈើលេខ១	0.60		NT
៣៤	ជ្រៃ	Ficus rumphii Bl.	ឈើក្រៅលំដាប់	0.56		
៣៥	បេង	Afzelia xylocarpa (Kurz) Craib	ឈើប្រណីត	0.56		
៣៦	ស្នាយ	Streblus asper Lour.	ឈើក្រៅលំដាប់	0.51		
៣៧	ភ្លូ	Dillenia indica L.	ឈើក្រៅលំដាប់	0.51		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៣៨	ព្រីង	Syzygium sp	ឈើលេខ៣	0.51		
៣៩	ល្បឹក	Terminalia alata Hey. ex Roth	ឈើលេខ១	0.51		
៤០	ក្រាយ	Xylopia vielana Pierre	ឈើក្រៅលំដាប់	0.42		
៤១	គគីរខ្សាច់	Hopea pierrei Hance	ឈើលេខ២	0.42		EN
៤២	រាំងភ្នំ	Shorea siamensis Miq.	ឈើលេខ១	0.42		LC
៤៣	ពាន់តាឡី	Lophopetalum wallichii Kurz	ឈើក្រៅលំដាប់	0.37		
៤៤	បាក់មាត់		ឈើក្រៅលំដាប់	0.37		
៤៥	អំបែងបែក		ឈើក្រៅលំដាប់	0.32		
៤៦	ស្តុកស្តោ	Walsura trichostemon Miq.	ឈើក្រៅលំដាប់	0.32		
៤៧	គគីត	Semecarpus cochinchinensis Engl.	ឈើក្រៅលំដាប់	0.32		
៤៨	ធ្លក	Parinari anamensis Hance	ឈើលេខ៣	0.32		
៤៩	ចំបក់	Irvingia malayana Oliv. ex Benn.	ឈើក្រៅលំដាប់	0.28		
៥០	សង្កែ	Combretum quadrangulare Kurz	ឈើក្រៅលំដាប់	0.23		
៥១	ក្តៅនាង	Cleistanthus tomentosus Hance	ឈើក្រៅលំដាប់	0.23		
៥២	ខ្វាស់	Castanopsis pyriformis Hickel & A. Camus	ឈើក្រៅលំដាប់	0.23		
៥៣	ឈើទាល	Dipterocarpus alatus Roxb. & G.Don	ឈើលេខ២	0.23		EN
៥៤	មមាំង	Diospyros ehretioides Wall. ex G.Don	ឈើក្រៅលំដាប់	0.19		
៥៥	ត្នងកែវ	Memecylon caeruleum Jack	ឈើក្រៅលំដាប់	0.19		
៥៦	ក្រូចព្រៃ	Atalantia citroides Pierre ex Guill.	ឈើក្រៅលំដាប់	0.19		
៥៧	ញរព្រៃ	Morinda coreia Ham.	ឈើក្រៅលំដាប់	0.14		
៥៨	គគីរដែក	Hopea helferi (Dyer) Brandis	ឈើលេខ១	0.14		
៥៩	អាជាង	Garuga pierrei Guill.	ឈើក្រៅលំដាប់	0.09		
៦០	រំដួល	Melodorum fruticosum Lour.	ឈើក្រៅលំដាប់	0.09		
៦១	បន្តង់ភ្លែក	Aidia cochinchinensis Lour.	ឈើក្រៅលំដាប់	0.09		
៦២	ឈើក្មើង	Diospyros undulata Well. ex. G. Don.	ឈើក្រៅលំដាប់	0.09		
៦៣	កប្បាសព្រៃ	Mallotus paniculatus Müll. Arg.	ឈើក្រៅលំដាប់	0.09		
៦៤	ស្វាយព្រៃ	Mangifera cochinchinensis Engl.	ឈើលេខ៣	0.09		
៦៥	ព្រីងស្រទាប់	Syzygium sp	ឈើលេខ៣	0.09		
៦៦	ខ្លុង	Dipterocarpus tuberculatus Roxb.	ឈើលេខ២	0.09		LC
៦៧	អង្គារសិល្ប	Ochna integerrima (Lour.) Merr.	ឈើក្រៅលំដាប់	0.05		
៦៨	ទ្រមូងសេក	Suregada multiflora (A. Juss.) Baill.	ឈើក្រៅលំដាប់	0.05		

លេខរៀង	ឈ្មោះឈើ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ប្រភេទ	កម្រិតលប់(%)	ប្រកាស០៨៩កសក	ចំណាត់ថ្នាក់IUCN
៦៩	ត្របែកព្រៃ	*Lagerstroemia floribunda Jack*	ឈើក្រៅលំដាប់	0.05		
៧០	ដង្កៀបក្តាម	*Antidesma ghaesembilla Gaertn.*	ឈើក្រៅលំដាប់	0.05		
៧១	ខ្វាញ់ក្តាម	*Ellipanthus tomentosus Kurz*	ឈើក្រៅលំដាប់	0.05		
៧២	កន្ទួតព្រៃ	*Phyllanthus emblica L.*	ឈើក្រៅលំដាប់	0.05		
៧៣	ព្រូស	*Garcinia schefferi Pierre*	ឈើលេខ៣	0.05		
៧៤	ក្តុល	*Nauclea orientalis (L.) L.*	ឈើលេខ៣	0.05		
៧៥	ត្រាច	*Dipterocarpus intricatus Dyer*	ឈើលេខ២	0.05		LC
៧៦	ខ្វាវ	*Haldina cordifolia (Roxb.) Rids.*	ឈើលេខ២	0.05		

- EN :Endangered (ប្រភេទកំពុងរងគ្រោះ)
- VU :Vulnerable (ប្រភេទងាយរងគ្រោះ)
- LC :Least Concern
- NT :Near Threatened

គ-២ បរិមាណធនធានឈើឈរមធ្យមប៉ាន់ស្មាន

យោងតាមលទ្ធផល វិភាគទិន្នន័យសារពើភ័ណ្ឌតាមវិធានស្ថិតិព្រៃឈើបានបង្ហាញថា ក្នុងតំបន់ព្រៃពាក់កណ្តាលស្រោងនៃ គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានចំនួនដើម និងមាឌឈើមធ្យមប៉ាន់ស្មានតាមថ្នាក់អង្កត់ផ្ចិត និងថ្នាក់ប្រភេទ ឈើនៃគ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅស្មើនឹង ៤៤៩ដើមក្នុង១ហ.ត ស្មើនឹង ១០៣,៦៥ m^3 ក្នុង ១ហ.ត ក្នុងនោះប្រភេទឈើប្រណីតមានចំនួន ២៦ដើមក្នុង១ហ.ត ស្មើនឹង ៥,៤៤m^3 ក្នុង១ហ.ត ឈើលេខ១មានចំនួន ២២៨ដើម ក្នុង១ហ.ត ស្មើនឹង ៥៥,៣៧ m^3ក្នុង ១ហ.ត ឈើលេខ២មានចំនួន២០ដើមក្នុង១ហ.ត ស្មើនឹង៤,៣៩ m^3ក្នុង១ហ.ត ឈើលេខ៣ មានចំនួន៤៣ដើមក្នុង១ហ.តស្មើនឹង៨,៨២ m^3ក្នុង១ហ.ត និងឈើក្រៅលំដាប់មានចំនួន១៣១ដើមក្នុង១ហ.តស្មើនឹង២៩,៦៣m^3ក្នុង១ហ.ត(តារាង៥-៣០)។

តារាង ៥-៣០: ចំនួនដើម និងមាឌឈើមធ្យមក្នុង០១ហ.ត តាមថ្នាក់ប្រភេទ និងថ្នាក់អង្កត់ផ្ចិត ក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់(ព្រៃពាក់កណ្ដាលស្រោង)

ថ្នាក់អង្កត់ផ្ចិត	សរុប		ឈើប្រណីត		ឈើលេខ១		ឈើលេខ២		ឈើលេខ៣		ឈើក្រៅលំដាប់	
ស.ម	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត	ដើម/ហ.ត	ម^3/ហ.ត
10'-29	386	69.84	22	3.49	193	36.17	17	3.40	40	7.13	114	19.65
≥ 30	63	33.81	3	1.95	36	19.20	3	0.99	3	1.69	18	9.98
សរុប	449	103.65	**26**	**5.44**	**228**	**55.37**	**20**	**4.39**	**43**	**8.82**	**131**	**29.63**

គ-៣ បរិមាណសន្និធិកាបូនប៉ាន់ស្មាន

ផ្អែកតាមលទ្ធផលសារពើភ័ណ្ឌក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ការប៉ាន់ស្មានបរិមាណសន្និធិកាបូនបានអនុវត្តរូបមន្ត Brown,199 ដែលជាលទ្ធផលបានបង្ហាញថាក្នុង តំបន់ព្រៃពាក់កណ្ដាលស្រោង មានបរិមាណសន្និធិកាបូនមធ្យមនៃប្រភេទឈើ ដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅស្មើនឹង៧៩.៤២តោនក្នុង១ហ.ត។ ផ្ទៃដីព្រៃពាក់កណ្ដាលស្រោងដែលនឹងទទួលរងផលប៉ះពាល់ចំនួន ៨៥០,២៦ហ.ត និងមានបរិមាណសន្និធិកាបូននៃប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតចាប់ពី១០សង់ទីម៉ែត្រឡើងទៅប៉ាន់ស្មាន ៦៧.៥២៧,៦៥ តោនទទួលរងផលប៉ះពាល់ផងដែរ (តារាង ៥-៣១)។

តារាង ៥-៣១: សន្និធិកាបូនប៉ាន់ស្មានសរុបនៃផ្ទៃដីរងផលប៉ះពាល់ដោយសារការអភិវឌ្ឍ វារីអគ្គិសនីស្ទឹងពោធិ៍សាត់ (ព្រៃពាក់កណ្ដាលស្រោង)

ថ្នាក់អង្កត់ផ្ចិត	ចំនួនដើម	ចំនួនមាឌឈើ	ជីវម៉ាស់លើដី	ជីវម៉ាស់ក្រោមដី	សរុប(AGB+BGB)	(CF)	សន្និធិកាបូនមធ្យម/ហត	ផ្ទៃដីប៉ះពាល់	សន្និធិកាបូនសរុប
ស.ម	ដើម/ហ.ត	មាឌ(m^3)	AGB (kg)	BGB(kg)	(Kg)	tonne C	CS(tonne)	ហ.ត	CS(tonne)
10'-29	386	69.84	76,082.77	22,824.83	98,907.60	0.49	48.46	850.26	41,203.60
≥ 30	63	33.81	48,597.00	14,579.10	63,176.10	0.49	30.96	850.26	26,324.05
សរុប	449	103.65	**124,679.77**	**37,403.93**	**162,083.70**		**79.42**		**67,527.65**

កំណត់សម្គាល់: BGB=30%AGB
CF=Carbon fraction
CS= Carbon Stock

គ-៤ ប្រភេទរុក្ខជាតិបន្តពូជ

យោងតាមទិន្នន័យសារពើភ័ណ្ឌបានបង្ហាញថា ក្នុងតំបន់ព្រៃពាក់កណ្ដាលស្រោង នៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍ សាត់នេះ ឃើញ មានប្រភេទរុក្ខជាតិបន្តពូជចំនួន ៧៨ប្រភេទរួមមាន កកោះ កន្ទួតព្រៃ ក្រខុបព្រៃ ក្រឡាញ់ ក្រាយ ក្រូចព្រៃ ខ្លុង គគីរ គគីរខ្សាច់ គគីរដែក គ្រង់ គ្រញូង ឆ្កែស្រែង ជង្គង់សេក ជ្រៃ ឈើខ្មៅ ឈើអែម ឈ្លីក ញរព្រៃ ដូន ចែម ត្រយឹង ត្រសេក ថ្កូវព្រៃ ទ្រមូង ទ្រមែង ទំពូង ធ្នង់ ធ្នា ធ្លក នាងផ្អែក បាក់ដង បាក់ដោក បាក់មាត់ បេង ប្រីសទ្រូ ផ្ទឹក ផ្ទុង ពពាលខែ ពពូល ពភ្លា ពភ្លាប្រើស ពាន់តាឡី ពោន ពោនស្វា ព្រីង ព្រីងភ្នំ ព្រីងស្រទាប់ ព្រះធ្នៅ ភ្លូង ភ្លូងកែវ ភ្លូភ្លៅនាង មមាំង មៀនព្រៃ រកា រលួស រាជកុល រាំង រាំងភ្នំ រំដួល លៀង សង្កែ សុក្រម សេមាន់ ស្តុកស្តោ ស្តៅ ស្តៅភ្នំ ស្នាយ ស្នួល ស្នាច់ដោម ស្រទ្បៅ ស្លាបប៉ាង ស្លែង ស្វាយព្រៃ អង្កត់ខ្មៅ អង្កាញ់ អង្គារសិល្ប និងអញ្ចាញ់យ។

គ-៥ ប្រភេទវល្លិ៍ និងពពួកស្មៅ: វ.ស្ទឹង, វ.ដំឡូងជ្រូក, វ.ជុយ, វ.កំបោរ, វ.ខ្ញែ, វ.ប៉ប្រើស, វ.ត្រដិត, វ.ចាក់សែង, វ.អំបុក, វ.អណ្ដាតត្រកួត, វ.បន្លាស្អិត, វ.ជណ្ដើរស្វា, វ.ចាម, វ.អន្ទុង, វ.ស្លែងពណ៌, វ.ល្មៀត, វ.ជើងគោ, វ.ប្រេង, វ.តាអាន, វ.ស្លែង, វ.អំពិល, វ.យាវ, វ.ក្អែប, វ.គ្រៀល, វ.ថ្មឹង, វ.សុខ័ន, វ.តាហ៊ឹង, វ.ក្រឡាំពៃ, វ.អង្រ្កង, វ.កន្ទាប់ចង្អេរ, វ.ដឹស, វ.ដោះគន់, វ.ប្រេង, ស្មៅតាសិត, ស្បូវឃ្លាំង, ព្រាល, ក្រខុប, ជង្គង់គោ, ប្រោសស្វា ។

គ-៦ ប្រភេទឬស្សី និងពពួកស្មៅ: ឬស្សីព្រិច, ឬស្សីឃ្លៃ។

គ-៧ ប្រភេទឬស្សី និងពពួកស្មៅ: សំឡាញ, ស្លាព្រៃ, ផ្តៅ។

តារាង ៥-៣២: ចំនួនដើម និងមាឌឈើមធ្យមសរុបក្នុង០១ហ.ត តាមថ្នាក់ប្រភេទនិងថ្នាក់អង្កត់ផ្ចិត ក្នុងតំបន់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់

ថ្នាក់អង្កត់ផ្ចិត	សរុប		ឈើប្រណីត		ឈើលេខ១		ឈើលេខ២		ឈើលេខ៣		ឈើក្រៅលំដាប់	
ស.ប	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត	ដើម/ហ.ត	ម³/ហ.ត
10'-29	340	51.56	14	2.18	196	28.51	29	4.93	20	3.42	80	12.52
≥ 30	68	34.60	3	1.33	44	21.78	6	3.28	3	1.31	14	6.90
សរុប	**408**	**86.16**	**17**	**3.51**	**240**	**50.29**	**34**	**8.21**	**23**	**4.73**	**94**	**19.42**

តារាង ៥-៣៣: សន្និធិកាបូនប៉ាន់ស្មានជាមធ្យមសរុបនៃផ្ទៃដីរងផលប៉ះពាល់ដោយសារការអភិវឌ្ឍវារីអគ្គិសនីស្ទឹងពោធិ៍សាត់

ប្រភេទឈើ	ចំនួនដើម	ចំនួនមាឌឈើ	ជីវម៉ាស់លើដី	ជីវម៉ាស់ក្រោមដី	សរុប(AGB+BGB)	សន្និធិកាបូនមធ្យម,ហត	ផ្ទៃដីប៉ះពាល់	សន្និធិកាបូនសរុប
ស.ឋ	ដើម/ហ.ត	មាឌ(m^3)	AGB (kg)	BGB(kg)	(Kg)	CS(tonne)	ហ.ត	CS(tonne)
DF	492	95.31	132,046.09	39,613.82	171,659.91	84.11	4,291.50	360,958.07
EF	284	59.52	114,538.41	34,361.52	148,899.94	72.96	866.19	63,197.22
SE	449	103.65	124,679.77	37,403.93	162,083.70	79.42	850.26	67,527.65
បញ្ជូប	**408**	**86.16**	**123,754.76**	**37,126.42**	**160,881.18**	**78.83**	**6,007.95**	**163,894.31**

២-សន្និដ្ឋានលើព្រៃឈើ ដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង

យោងតាមការសិក្សាព្រៃឈើរបស់ក្រុមការងារ SAWAC និងការគណនាដង់ស៊ីតេមាឌ ដូចបានបង្ហាញក្នុងតារាង ៥-៣១, ៥-៣២ និង៥-៣៣ ខាងលើអាចធ្វើការសន្និដ្ឋានដូចតទៅ៖

- គម្រោងនេះមានគម្របព្រៃឈើសរុបចំនួន ៦.៤៣៩,១២ ហ.ត ក្នុងនោះគម្របព្រៃឈើដែលមិនត្រូវកាប់សំអាតចំនួន៤៣១,១៧ហ.ត និងគម្របព្រៃត្រូវកាប់សំអាតចំនួន ៦០០៧,២៤ ហ.ត (មានគម្របព្រៃស្រោង ៨៦៥,៤៩ហ.ត គម្របព្រៃពាក់កណ្តាលស្រោង ៨៥០,២៥ហ.ត និង គម្របព្រៃល្បោះ ៤.២៩១,៥០ហ.ត) ។
- ព្រៃស្រោងមានឈើ ៩៦ប្រភេទ ក្នុងនោះមានឈើកម្រ ៧ប្រភេទ ដូចជា អង្កត់ខ្មៅ, ត្រយឹង, ធ្នង់, តាត្រាវ, បេង, នាងនួន, និងគ្រើល ។ ដង់ស៊ីតេមាឌជាមធ្យមរបស់ព្រៃស្រោងគិតអង្កត់ផ្ចិតឈើពី ១០០ម.ម ឡើងទៅមានចំនួន ៥៩,៥២ម៣/ហ.ត ហើយមាន ២២,៦៣ម៣/ហ.ត ចំពោះអង្កត់ផ្ចិត ចាប់ពី ៣០០មម ឡើងទៅ។ អត្រានៃ ព្រៃស្រោងអាចស្តុកកាបូន ជាមធ្យមបាន ៧២,៩៦តោន/ហ.ត ។
- ព្រៃពាក់កណ្តាលស្រោងមានឈើ ៧៦ប្រភេទ ក្នុងនោះមានឈើកំរ ៣ប្រភេទ ដូចជា ត្រយឹង, អង្កត់ខ្មៅ, និងធ្នង់។ ដង់ស៊ីតេ មាឌជាមធ្យម ១០៣,៦៥ម៣/ហ.ត ចំពោះអង្កត់ផ្ចិតចាប់ ១០០មម ឡើងទៅ និង ៣៣,៨១ ម៣/ហ.ត ចំពោះអង្កត់ ផ្ចិតចាប់ពី ៣០០មម ឡើងទៅ។ អត្រានៃព្រៃពាក់កណ្តាលស្រោង អាចស្តុក កាបូនជាមធ្យមបាន ៧៩,៤២ តោន/ហ.ត។
- ព្រៃល្បោះមានឈើ ៨៨ប្រភេទ ក្នុងនោះមានឈើកំរ ៥ប្រភេទ ដូចជា ត្រយឹង, អង្កត់ខ្មៅ, ហែសាន, តាត្រាវ, និងគ្រើល។ ដង់ស៊ីតេមាឌជាមធ្យម ៩៥,៣១ម៣/ហ.ត ចំពោះអង្កត់ផ្ចិតចាប់ ១០០មម ឡើងទៅនិង ៤៧,៣៦ ម៣/ហ.ត ចំពោះអង្កត់ ផ្ចិតចាប់ពី ៣០០មម ឡើងទៅ។ អត្រានៃព្រៃល្បោះ អាចស្តុកកាបូន ជាមធ្យមបាន ៨៤,១១ តោន/ហ.ត។
- ដង់ស៊ីតេមាឌជាធ្យម ៥១,៥៦ ម៣/ហ.ត (គិតអង្កត់ផ្ចិត ឈើពី១០ស.មឡើងទៅ) និងឈើដែលមានអង្កត់ ផ្ចិត ៣០ស.ម គឺ ៣៤,៦ ម៣/ហ.ត។

៥.១.២.២ សត្វព្រៃ និងមច្ឆជាតិក្នុងតំបន់គម្រោង (Wildlife and Fishes)

ចំពោះអំពីវត្តមានសត្វព្រៃ-មច្ឆជាតិនៅតំបន់គម្រោងនេះ ដោយមានលទ្ធផលដូចមានបង្ហាញក្នុងតារាងនៃចំណុចខាងក្រោម ដូចតទៅ (វិធីសាស្ត្រនៃការសិក្សា មើលក្នុងជំពូក ២ ចំណុច ២.២.៣.២):

សម្គាល់: *- ព័ត៌មានពីធនធានសត្វព្រៃនៅក្នុងតំបន់គម្រោង គឺបានពីការសម្ភាសជាមួយនឹងអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋមូលដ្ឋាន និងមន្ត្រីអភិរក្សសត្វព្រៃ និងការសិក្សាតាមចំណុចសិក្សាព្រៃឈើ។*

- ចំនួនប្រភេទសត្វព្រៃ និងមច្ឆជាតិ តាមក្រុមប្រភេទនីមួយៗ (ថនិកសត្វ បក្សី ឧរង្គសត្វ មច្ឆជាតិ និងវារីសត្វ អាចមានចំនួនច្រើនជាងចំនួនប្រភេទសត្វដែលបានបរិយាយនៅក្នុងតាង ៥-៣៤, ៥-៣៥ និង៥-៣៦ អាស្រ័យតាមរដូវកាល និងពេលវេលាឆ្លងកាត់របស់ពួកវាទាំងនោះ។

I. **ថនិកសត្វ** (Mammal)

ថនិកសត្វសំខាន់ៗ ដែលរកឃើញក្នុងតំបន់គម្រោងនេះ មានចំនួន៤៤ប្រភេទ ក្នុងនោះមាន ២០ប្រភេទ ស្ថិតក្នុងឧបសម្ព័ន្ធ សាយតេស គឺឧបសម្ព័ន្ធ I មាន ៧ប្រភេទ, ឧបសម្ព័ន្ធ II មាន ៩ ប្រភេទ, និងឧបសម្ព័ន្ធ III មាន ៤ ប្រភេទ។ យោងតាមប្រកាសចំណាត់ថ្នាក់សត្វព្រៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ ក្រុមដែលជិតផុតពូជ CR មាន២ប្រភេទ, ក្រុមមានដោយកម្រ R ចំនួន១០ប្រភេទ, និងក្រុមមានដោយបង្គួរចំនួន៣២ប្រភេទ។ ចំណែកឯ ប្រភេទសត្វក្នុងបញ្ជីក្រហមរបស់ IUCN វិញសរុបមាន ១៧ប្រភេទ ក្នុងនោះមាន CR ១ប្រភេទ គឺពង្រូល, EN មាន៦ប្រភេទគឺ ទន្សោងឈ្លូសយក្ស ឆ្កែព្រៃ ភេរោមច្រមុះ ទោចមុជ ខ្លាត្រី ក្រុម, និង VU មាន១០ប្រភេទ គឺខ្ទីង ប្រើស ភេខ្លួនរលោង សំពោចធំ សំពោចភ្នំ រញ៉េផេះ រញ៉េភ្លើង ស្វាក្រោស ស្វាអង្កត់ និងខ្លាឃ្មុំធំ ដូចដែលមានក្នុងតារាង ៥-៣៤ ខាងក្រោមៈ

តារាង ៥-៣៤: ឈ្មោះថនិកសត្វមាននៅក្នុងតំបន់គម្រោងសិក្សាថ្ងៃទី ១០ ខែកុម្ភៈ ដល់ថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ២០១២ និងបញ្ជាក់ឡើងវិញខែកញ្ញា២០១៥

Nº	Khmer Name	Scientific Name	English Name	CITES ប្រក.កសក	IUCN
1	ពង្រូល	*Manis javanica*	Sunda Pangolin	I, Cr	CR
2	ទន្សោង	*Bos javanicus*	Wild Ox	R	EN
3	ខ្ទីង	*Bos gaurus*	Gaur	I, R	VU
4	កែះ	*Naemorbedus Sumatraensis*	Southern Serow	I, R	
5	ប្រើស	*Cervus unicolor*	Sambar		VU
6	ឈ្លូស	*Muntiacus muntjak*	Red Muntjac		
7	ឈ្លូសយក្ស	*Megamuntiacus vuquangensis*	Large-antlered Munjac	I, R	En
8	ក្តាន់ញ្ញែង ឬផ្ទង់ ធំ	*Tragulus napu*	Greater Mousedeer		LC
9	ក្តាន់ញ្ញែង ឬផ្ទង់ តូច	*Tragulus javanicus*	Lesser Mousedeer		LC
10	ស្វាន	*Canis indicus*	Indian Jackal		
11	ឆ្កែព្រៃ	*Cuon alpinus*	Dholes	II	EN
12	ភេរោមច្រមុះ	*Lutra sumatrana*	Hairy-nosed Otter	II, R	EN
13	ភេខ្លួនរលោង	*Lutrogale perspicillata*	Smooth Otter	II	VU
14	ស្កាតូច	*Herpestes javanicus*	Small Asiun Mongoose		LC
15	ស្កាធំ	*Herpestes urva*	Crab-eating Mongoose	III	LC
16	សំពោចកលឿង ឬកាំង	*Martes flavigula*	Yellow-throated Marten	III	LC
17	សំពោចក្រអូប/ត្មោត	*Paradoxurus hermaphroditus*	Common palm Civet	III	LC
18	សំពោចពណ៌លាត	*Paguma larvata*	Masked Palm Civet	III	LC
19	សំពោចធំ	*Viverra megaspila*	Large-spotted Civet	III	VU
20	សំពោចអុជខ្នង	*Arctogalidia trivirgata*	Small-toothed Palm Civet		LC
21	ឈ្លូសប្រែង ឬសំពោចភ្នំ	*Arctictis binturong*	Binturong	III	VU
22	ឆ្លក	*Melogale personata*	Large-toothed Ferret Badger		DD
23	រញ៉ីផេះ	*Nycticebus coucang*	Slow Loris	II	VU
24	រញ៉ីភ្លើង	*Nycticebus pygmaeus*	Pygmy Loris	II	VU
25	ប្រម៉ា	*Hystrix brachyura*	East Asian Porcupine		LC
26	កំប្រុកពណ៌	*Callosciurus finlaysoni*	Variable Squirrel	.	
27	កំប្រុកធំ ឬខ្ទីន	*Ratufa bicolor*	Black Giant Squirrel	II, R	NT
28	កំប្រុកស្លាបភ្នំ	*Hylopetes alboniger*	Particulored Flying Squirrel		LC
29	កំប្រុកស្លាប	*Hylopetes phayrei*	Phayre's Flying Squirrel		LC
30	កង្ហិច	*Tamiops maritimus*	Eastern Striped Squirrel		LC
31	កង្ហិចកម្ពុជា	*Tamiops rodolphii*	Cambodian Striped Tree Squirrel		LC
32	ឆ្មាបាកន្ទុយក្រហម	*Petaurista petaurista*	Giant Flying Squirrel	R	LC
33	ជ្រូកព្រៃ	*Sus scrofa*	Wild Pig (Boar)		LC
34	ស្វាត្រោស	*Macaca nemestrina*	Pig-tailed Macaque	II, R	VU
35	ស្វាអង្គត់	*Macaca arctoides*	Stump-tailed Macaque	II, R	VU
36	ស្វាក្រេះ/ ស្វាក្តាម	*Macaca fascicularis*	Long-tailed Macaque	II	LC
37	ទោចម្កុដ	*Hylobates pileatus*	Pileated Gibbon	I, R	EN
38	ខ្លាត្រី	*Prionailurus viverrinus*	Fishing Cat	II	EN
39	ខ្លារខិន	*Panthera pardus*	Leopard	I, R	NT
40	ខ្លាឃ្មុំធំ	*Ursus thibetanus*	Asiatic Black Bear	Cr	VU
41	ខ្លាឃ្មុំតូច	*Ursus malayanus*	Sun Bear	I	
42	ប្រចៀវ	*(Order: CHIROPTERA)*	Bats		
43	ប្រចៀវភ្នំត្បែង	*Otonops wroughtoni*	wroughton's Free-tailed Bat	R	
44	ជ្រឹងកោះ	*Pteropus hypomelanus*	Island Flying-fox	II, R	LC

*<u>សម្គាល់:</u> I, II, III ជាលេខឧបសម្ព័ន្ធអនុសញ្ញា CITES ។ ចំណាត់ថ្នាក់ដោយ ក្រសួងកសិកម្ម **Cr :** ប្រភេទជិតផុតពូជ, **R :** ក្រុមមានដោយកម្រ។ បញ្ជីក្រហម IUCN: CR: ប្រភេទជិតផុតពូជ, EN: ប្រភេទកំពុងរងគ្រោះ, VU: ប្រភេទងាយរងគ្រោះ។*

ក្រុមការងារ SAWAC ថតបានថនិកកសត្វមួយចំនួននៅក្នុងតំបន់គម្រោងមានដូចតទៅ:

ដានជើង ឈ្លូសប្រែង ឬសំពោចភ្នំ ថតនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

ស្វាក្តាម ថតនៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

ដានប្រើស ថតនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

ស្វាអង្កត់ ថតនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

ភេខ្លួនរលោង ថតនៅថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

ជ្រូកព្រៃ ថតនៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០១២ នៅក្នុងតំបន់គំរោង

២-បក្សីសត្វ (Bird)

ចំពោះសត្វស្លាបសំខាន់ៗ ដែលបានកត់ត្រាមានក្នុងតំបន់គម្រោង មានចំនួន ១២០ប្រភេទ ក្នុងនោះមាន ២៧ ប្រភេទ ស្ថិតក្នុងឧបសម្ព័ន្ធសាយតេសក្នុងនោះឧបសម្ព័ន្ធ I មាន ១ប្រភេទ , ឧបសម្ព័ន្ធ II មាន ២៥ ប្រភេទនិង ឧបសម្ព័ន្ធ III មាន១ប្រភេទ។ យោងតាមប្រកាសចំណាត់ថ្នាក់សត្វព្រៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៈ ក្រុមមានដោយកម្រ R ចំនួន៥ប្រភេទ, និងក្រុមមានដោយបង្គួរចំនួន១១៥ប្រភេទ។ ចំណែកឯ ប្រភេទសត្វក្នុងបញ្ជីក្រហមរបស់ IUCN វិញសរុបមាន២ប្រភេទ ក្នុងនោះមាន EN មាន១ប្រភេទគឺ ក្ងោកបៃតង, និង VU មាន១ប្រភេទ គឺត្រសេះធំប្រផេះ ដូចដែលមានចែងក្នុងតារាង៥-៣៥ ខាងក្រោម ៖

តារាង ៥-៣៥: ឈ្មោះបក្សីដែលមាននៅក្នុងតំបន់គម្រោង សិក្សាថ្ងៃទី១០ ខែគុម្ភៈ ដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១២ និងបញ្ជាក់ឡើងវិញខែកញ្ញា ២០១៥

Nº	Khmer Name	Scientific Name	English name	ប្រក.កសក CITES	IUCN
1	បាគូ	*Upupa epops*	Common Hoopoe		LC
2	ពពិចកំប៉ោយបំពង់ក ស ទ្រូងប្រផេះ	*Alophoixus ochraceus*	Ochraceous Bulbul		LC
3	ពពិចកំប៉ោយស្លាប បៃតងខ្មៅ	*Hemixos flavala*	Ashy Bulbul		LC
4	ពពិចកំប៉ោយតូច	*Erpornis zantholeuca*	white-bellied erpornis		
5	ពពិចខ្នងដេក	*Phylloscopus plumbeitarsus*	Two-barred Wabler		
6	ពពិចក្បាលខ្មៅ	*Pycnonotus atriceps*	Black-headed Bulbul		LC
7	ពពិចព្រៃគម្លោធ	*Saxicola caprata*	Pied Bushchat		LC
8	ពញ្លាក់ចង់	*Caprimulgus macrurus*	Large-tailed Nightjar		LC
9	ពភ្លាក់ផុក	*Caprimulgus indicus*	Grey Nightjar		LC
10	ពភ្លាក់តូច	*Caprimulgus asiaticus*	Indian Nightjar		LC
11	ពពូលទ្រូងភ្លើង ក្បាលប្រផេះ	*Treron vernans*	Pink-necked Green Pigeon		LC
12	ចាបចង្រ្កង	*Lonchura punctulata*	Scaly-breasted Munia		LC
13	ចាបដង្ហងពណ៌ស្លាបច្រេះ	*Prinia rufescens*	Rufescent Prinia		LC
14	ចាបដង្ហូវចិញ្ចើមស	*Prinia inormata*	Plain Prinia		LC
15	ចាបដង្ហូវធំ	*Prinia polychroa*	Brown Prinia		LC
16	ចាបដូនតា	*Acrocephalus orientalis*	Oriental Reed Wabler		
17	ចាបតេត	*Orthotomus sutorius*	Common Tailorbird		LC
18	ចាបតេតព្រៃ	*Orthotomus atrogularis*	Dark-necked Tailorbird		LC
19	ចាបស្រុក	*Passer montanus*	Eurasian Tree Sparrow		LC
20	ចាបក្រច	*Pycnonotus goiavier*	Yellow-vented Bulbul		LC
21	ចកវ៉ែកកំប៉ោយស ឬត្រលែងវែក	*Garrulax leucolophus*	White-crested Laugh-ingthrush		LC
22	ប៉ោលតោកក្បាលព្រលែត	*Megalaima lineata*	Lineated Barbet		LC
23	ប៉ោលតោកអំបុក	*Megalaima haemacephala*	Coppersmith Barbet		LC
24	ប៉ោលតោកបំពង់ក លឿង	*Megalaima oorti*	Black-browed Barbet		LC
25	ប៉ោលតោកគូថក្រហម	*Megalaima lagrandieri*	Red-vented Barbet		LC
26	ប៉ោលតោកតុកកូឡុក	*Megalaima incognita*	Moustached Barbet		LC
27	ចេកចៅស្លាបខ្មៅ-ស	*Aegithina tiphia*	Common Iora		LC
28	ចេកទុំ	*Oriolus chinensis*	Black-naped Oriole		LC
29	ចេកទុំក្បាលខ្មៅ	*Oriolus xanthornus*	Black-hooded Oriole		LC
30	ចេកខ្ចីថ្ងាសភ្លើង	*Chloropsis aurifrons*	Golden-fronted Leafbird		LC
31	ក្អែក	*Corvus macrohynchos*	Large-billed Crow	R	LC
32	ស្មោញ	*Anhinga melanogaster*	Oriental Darter		NT
33	ក្ងោកបៃតង	*Pavo muticus*	Green Peafowl	II	EN
34	ញ៉ាំង ឬពរាំង	*Aceros undulatus*	Wreathed Hornbill	II	LC
35	កេងកងធំ	*Buceros bicornis*	Great Hornbill	I	NT

Nº	Khmer Name	Scientific Name	English name	ប្រក.កសក CITES	IUCN
36	កេងកងតូច	*Anthracoceros albirostris*	Oriental Pied Hornbill	II, R	LC
37	សេកសោម	*Psittacula eupatria*	Alexandrine Parakeet	II, R	NT
38	សេកអាត់	*Psittacula roseata*	Blossom-headed Parakeet	II	NT
39	សេកត្រិច	*Loriculus vernalis*	Vernal Hanging Parrot	II	LC
40	សេកសក	*Psittacula alexandri*	Red-breasted Parakeet	II	NT
41	អន្ទេបចំពុះក្អែក	*Dicrurus annectans*	Crow-billed Drongo		LC
42	អន្ទេបកំប៉ោយខ្សែ	*Dicrurus hottentottus*	Spangled Drongo		LC
43	អន្ទេបប្រផេះ	*Dicrurus leucophaeus*	Ashy Drongo		LC
44	អន្ទេបខ្មៅ	*Dicrurus macrocercus*	Black Drongo		LC
45	អន្ទេបទងកន្ត្រៃ	*Dicrurus paradiseus*	Greater Racket-tailed Drongo		LC
46	អន្ទេបរំយោល-ភ្នំ	*Dicrurus remifer*	Lesser Racket-tailed Drongo		LC
47	អកពស់ព្រៃ	*Spilornis cheela*	Crested Serpent Eagle	II	LC
48	ប្រម៉ង់	*Pandion haliaetus*	Osprey	II	LC
49	រអាតត្រចៀកប្រផេះ	*Butastur indicus*	Grey-faced Buzzard	II	LC
50	ងាវកក	*Halcyon capensis*	Stork-billed Kingfisher		LC
51	កដបក្បាល ខ្មៅ ឬប៉កគាវ	*Halcyon pileata*	Black-capped Kingfisher	R	LC
52	ចចាតត្រចៀកខៀវ	*Alcedo meninting*	Blue-eared Kingfisher		LC
53	កុកគោ	*Bubulcus ibis*	Cattle Egret	III, R	LC
9	អន្លង់ទឹកភ្លៀវ(អន្លង់ទឹកវិល)	Anlung Toek Pleav (Anlung Toek Vel)	312654	1357580	
10	អន្លង់ដាអូរក្តី	Anlung Da Ou Kdei	313658	1357400	
11	អន្លង់បបុស្ស	Anlung Babors	314354	1358090	
12	អន្លង់ស្បូវ	Anlung Sbov	314823	1358460	
13	អន្លង់បឹង	Anlung Boeng	315603	1359230	មានសត្វក្រពើ
14	អន្លង់ថ្មបែក	Anlung Thma Bek	316501	1360440	
15	អន្លង់ពាមសន្តាំង	Anlung Peam Santaing	317333	1361300	
16	អន្លង់ក្អែន	Anlung Kaen	317949	1361330	
17	អន្លង់ធ្នឹម	Anlung Thnoem	318164	1361640	
18	អន្លង់ជ្រៃ	Anlung Chrey	318554	1362600	មានសត្វក្រពើ
19	អន្លង់ស៊ុមត្រាង	Anlung Soum Trang	319198	1362920	

សម្គាល់៖ *មានអន្លង់១៨គឺស្ថិតនៅក្នុងតំបន់អាង (លេខរៀងពី1ដល់ 18)។ អន្លង់ស៊ុមត្រាងស្ថិតនៅខាងក្រោមទំនប់លេខរៀង 19។*

៥.១.២.៤ ជីវចំរុះ និងជីវសាស្រ្តព្រមទាំងប្រព័ន្ធអេកូឡូស៊ី (Biodiversities and Bio-Ecological Systems)

ដូចបានចែងក្នុងចំណុចទីជំរកខាងលើតំបន់គម្រោងស្ថិតក្នុងតំបន់ព្រៃការពារ និងតំបន់អភិរក្ស ដែលមានប្រព័ន្ធអេកូឡូស៊ី ផ្សេងៗ ដែលពាក់ពន្ធ័គ្នាយ៉ាងសាំញ៉ាំ រួមទាំងចង្វាក់ចំណីអាហារ និងទីជំរករបស់សត្វព្រៃ ទៀតផង។ តំបន់នេះត្រូវបានយកចិត្ត ទុកដាក់ពីរាជរដ្ឋាភិបាល ក្នុងការថែរក្សា និងអភិរក្ស ព្រមទាំងមានការសហការជាមួយអង្គការអភិរក្សនានា។ តំបន់ជួរភ្នំក្រវាញនេះ មានតំបន់ក្រវាញកណ្តាល តំបន់ក្រវាញខាងត្បូង ជាតំបន់ជួរភ្នំ ខ្ពង់រាប និងជ្រលង ដែលតភ្ជាប់គ្នាជាមួយប្រព័ន្ធតំបន់អេកូឡូស៊ីព្រៃត្រូពិកភ្ជាប់ទៅនឹងតំបន់ដែនជំរកសត្វព្រៃ ភ្នំសំកុស ស្ថិតក្នុងខេត្ត ពោធិ៍សាត់និងកោះកុង។ ដូចនេះ ក្នុងការអភិវឌ្ឍគម្រោងក្នុងតំបន់នេះ គប្បីពិចារណា និងធ្វើការកាត់បន្ថយឱ្យដល់កម្រិតតិចបំផុត ដែលអាចទទួលយកបាន (ដូចជាក្នុងការកាត់ផ្តាច់របៀង រំខាន ប្រមាញ់ បំផ្លាញជំរកសត្វព្រៃ និងជំរករបស់វា ដែលគ្មានពីរទាំងនេះ គឺតាមរយៈការធ្វើគន្លងខ្សែបញ្ជូនអគ្គិសនីការ សាងសង់ផ្លូវចូលក្នុងតំបន់ជាដើម។ល។)

៥.១.២.៥ តំបន់ព្រៃលិចទឹកតាមដងស្ទឹង និងតំបន់ដីសើម (Flooded forest and Wetland)

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ សាងសង់នៅកាត់ស្ទឹងពោធិ៍សាត់ ដែលស្ទឹងនេះហូរចូលបឹងទន្លេសាប។ ប្រវែងស្ទឹង ពោធិ៍សាត់គិតពីទំនប់វារីអគ្គិសនីនេះដល់មាត់បឹងទន្លេសាបមានប្រវែង១៦៣គ.ម ហើយនៅរដូវវស្សាទឹកឡើងពីទន្លេមេគង្គ និងទឹក ពីតំបន់ផ្ទៃរងទឹកភ្លៀងរបស់វា ចូលដល់ចំណុចចុងថ្នល់ ចំងាយប្រមាណ៣០គ.ម ពីក្រុងពោធិ៍សាត់។ ស្ទឹងនេះមានទឹកហូរជាប្រចាំ ទាំងប្រាំង និងវស្សា ហើយចាប់ពីខែឧសភា ដល់ខែវិច្ឆិកា ជារដូវវស្សាទឹកភ្លៀង ជន់លិចតាមតំបន់មាត់ស្ទឹង ចំណែកឯ នៅក្នុងតំបន់ គម្រោងប្រមាណចាប់ពី៥ម ទៅដល់២៥ម តាមសណ្ឋានភាពដី។

ក្នុងតំបន់គម្រោង តាមដងស្ទឹងតំបន់លិចទឹកនេះ មានព្រៃលិចទឹក ដែលមានប្រភេទ ព្រៃឈើ ដូចតទៅ: បន្ទាបាយដំណើប (*Acacia thailandica nielsen*), បន្លាយួន (*Minosa pigra L*), ពង្រ (*schleichera oleosa*), ចារ (*Butea monosperma*), ដង្ហិត (*Butea monosperma*), ធ្មេញត្រី (*Brideia cambodiana gagnep*), ត្លៃ(*Cudrania cambodiana gagnep*), ឃ្លេ(*Maclura cochinchinensis*), ល្បៀង(*Cartoxylon prumifera dyer*), រៃទឹក(*Homonoia* *riparia lour)*, អញ្ចាញ(*Gmelina asiatica*), រាំង(*Barringacutangula*), ស្នាយ(*Streblus asper*), ត្រែង(*Phragmites karta*)។

សំណង់ធារាសាស្ត្រដំណាក់អំពិល ថតថ្ងៃទី៩ កញ្ញា ឆ្នាំ២០១២

សំណង់ធារាសាស្ត្រចារីក ថតថ្ងៃទី៩ កញ្ញា ឆ្នាំ២០១២

សំណង់ធារាសាស្ត្រពោធិ៍សាត់៣កំពុងសាងសង់
ថតថ្ងៃទី៩ កញ្ញា ឆ្នាំ២០១២

សំណង់ធារាសាស្ត្រពោធិ៍សាត់៥កំពុងសាងសង់
ថតថ្ងៃទី៩ កញ្ញា ឆ្នាំ២០១២

ទិដ្ឋភាពព្រៃលិចទឹកនៅចុងថ្នល់ ១២គ.មពីមាត់បឹងទន្លេសាប

ទិដ្ឋភាពព្រៃលិចទឹកក្នុងតំបន់គម្រោង

ជាងនេះទៅទៀត ស្ទឹងមានសំណង់ធារាសាស្ត្រ២កន្លែងសង់កាច់ស្ទឹងគឺ ចារីក និង ដំណាក់អំពិល។ ចំណែកឯ នៅដៃស្ទឹង នេះ គឺស្ថិតនៅចន្លោះ ដំណាក់អំពិល កំពុងសាងសង់ទំនប់អាងទឹក ពោធិ៍សាត់៣ និងពោធិ៍សាត់៥ មើលរូបខាងក្រោម។

៥.២ បរិស្ថានសេដ្ឋកិច្ច-សង្គមនៅក្នុងតំបន់គម្រោង (Socio-Ecomomic Environment)

ការសិក្សាវាយតម្លៃបរិស្ថានសេដ្ឋកិច្ច-សង្គមលើគម្រោងវារីអគ្គិសនីពោធិ៍សាត់១នេះ គឺត្រូវបានធ្វើឡើងចំពោះតែគ្រួសារ ដែលរងផលប៉ះពាល់ផ្ទាល់ពីគម្រោងតែប៉ុណ្ណោះ ដើម្បីធ្វើការវិភាគលើសេដ្ឋកិច្ចកម្រិតជីវភាពរស់នៅរបស់ពួកគាត់មុនការអភិវឌ្ឍគម្រោង ទុកជាទិន្នន័យគ្រឹះសម្រាប់វិភាគការប៉ះពាល់ដល់ពួកគាត់ក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោង។ រីឯអ្នកមិនប៉ះពាល់ គឺមិនបានធ្វើការវិភាគលើសេដ្ឋកិច្ចរបស់ពួកគាត់ទេ ក៏ប៉ុន្តែក្រុមការងារបានប្រជុំផ្សព្វផ្សាយ និងទទួលយក មតិសំណូមពររបស់ពួក គេទាំងនោះផងដែរ។

៥.២.១ ប្រជាសាស្ត្រ និងការតាំងលំនៅឋាន

ទីតាំងភូមិសាស្ត្រគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ស្ថិតនៅក្នុងដែនដីគ្រប់គ្រងរដ្ឋបាលរបស់ ភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង នៃខេត្តពោធិ៍សាត់ (ផ្ទៃអាងទំនប់ រន្ធបំពង់ទូនេល អាគារថាមពល ការិយាល័យ កន្លែងស្នាក់នៅ ខ្សែចម្លងអគ្គិសនី។ គម្រោងនេះ ក៏ស្ថិតនៅក្នុងដែនជំរកសត្វព្រៃភ្នំសំកុស, តំបន់ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលដែល ដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន និងតំបន់ដែនបម្រុងព្រៃអចិន្ត្រៃយ៍ ដែលគ្រប់គ្រងដោយ រដ្ឋបាលព្រៃឈើសហការជាមួយអង្គការ CI និង FFI ផងដែរ។ ចំពោះភូមិ ដែលប៉ះពាល់ ដោយសារគម្រោង មាន តែ១ភូមិប៉ុណ្ណោះគឺ:

ភូមិស្ទឹងថ្មី នៅក្នុងតំបន់គម្រោងដែលចែកជាចំណុចជាច្រើន(ឧបសម្ព័ន្ធរបស់ភូមិស្ទឹងថ្មី)ដូចជា ចំណុចដូននាគ ចំណុចតាំងយ៉ និងចំណុចទួលគ្រួស ចំណុចដែលមានចំណុចតូចៗជាច្រើនដូចជា ចំណុចស្រែពាំង ទួលកកោះ អន្លង់ក្រូច អន្លង់យួត អូរតាសូរ អូរធូង អូរសង្កសី និងស្វាយកោង។

ស្ថានភាពប្រជារាស្ត្រ នៅក្នុង ខេត្តពោធិ៍សាត់៖ ខេត្តពោធិ៍សាត់ មានផ្ទៃដីសរុបចំនួន ១២.៦៩២ គ.ម^2 និងមានសណ្ឋានដីជា ដីតំបន់ភ្នំ និងខ្ពង់រាប ភាគខាង លិច និងតំបន់ទំនាបភាគខាងកើតនៃផ្លូវរទេះភ្លើង។ ខេត្តនេះមានស្រុកចំនួន ០៥ ក្រុង ០១ ឃុំចំនួន ៤៩ ភូមិចំនួន ៥០១ និងមានព្រំប្រទល់ខាងកើតទល់នឹងខេត្តកំពង់ឆ្នាំង និងបឹងទន្លេសាប, ខាងលិច ទល់ខេត្តបាត់ដំបង និងប្រទេស ថៃឡង់ មានខ្សែ បន្ទាត់ព្រំដែនប្រមាណ៨០គម, ខាងជើងទល់នឹងបឹងទន្លេសាប ប្រវែងប្រមាណ ៨០គម, ហើយនិងខាងត្បូងទល់នឹង ខេត្តកំពង់ស្ពឺ និង ខេត្តកោះកុង។ ខេត្តនេះមានប្រជាជនសរុប ប្រមាណ ៤៣៥.០០១នាក់ (ទិន្នន័យឆ្នាំ ២០១១ បានពីរបាយការណ៍សន្និបាត បូកសរុប ការងារគ្រប់វិស័យប្រចាំឆ្នាំ ២០១០ និងទិសដៅការងារឆ្នាំ២០១១ នៃសាលាខេត្តពោធិ៍សាត់) រួមមានប្រុសចំនួន ២១២.១៥១នាក់ និងស្រីចំនួន ២២២.៨៥០នាក់ ប្រភពទិន្នន័យបាន ពីឧទ្ទកាល័យខេត្តពោធិ៍សាត់។ ដង់ស៊ីតេប្រជាជនមាន ប្រហែល ៣៣ នាក់/គ.ម^2 ។

៥.២.១.១ អំបូរជនជាតិ

យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងាររបស់ SAWAC បានឱ្យដឹងថា នៅក្នុងនិងក្បែរតំបន់គម្រោងនេះ មាន អំបូរ ជនជាតិ ដូចជា ជនជាតិខ្មែរ ជនជាតិព័រ ហើយចំនួនគ្រួសារនិងភាគរយមានចែងក្នុងតារាង ៥-៥១ខាងក្រោម។

តារាង ៥-៥១: អំបូរជនជាតិដែលមាននៅក្នុងតំបន់គម្រោង (សិក្សាខែតុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ចំនួនគ្រួសារសរុប	អំបូរជនជាតិគិតជាភាគរយ(%)				សរុប	សម្គាល់៖
			ព័រ	%	ខ្មែរ	%		
1	ស្ទឹងថ្មី	304	2	1%	302	99%	100%	ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់
2	ដូននាគ	175	5	3%	170	97%	100%	
3	តាំងយ៉	256	15	6%	241	94%	100%	
4	ទួលគ្រួស	211	24	11%	187	89%	100%	
សរុប		946	46	5%	900	95%	100%	

ប្រភព: ទិន្នន័យផ្តល់ដោយអាជ្ញាធរឃុំប្រម៉ោយឆ្នាំ២០១៧។

៥.២.១.២ ប្រជាពលរដ្ឋដែលរស់នៅក្នុង/ក្បែរតំបន់គម្រោង

នៅក្នុង/ក្បែរតំបន់គម្រោងនេះមានប្រជាពលរដ្ឋ ០១ភូមិ គឺភូមិស្ទឹងថ្មី(ដែលមាន៧ចំណុចដូចជាចំណុចស្ទឹងថ្មី ដូននាគ តាំងយ៉ ទួលគ្រួស អូរតក់ឡាក់ ដំណាក់កន្សែង និងត្រពងពង្យ) ដែលជាចំណុចឧបសម្ព័ន្ធនៃភូមិនេះ ហើយនៅតាមបណ្តាចំណុចទាំងនេះនៅមានចំណុចជាច្រើនទៀតដូចជា៖ នៅចំណុចដូននាគ មានចំណុចតូចៗជាច្រើនដូចជា (ចំណុចអន្លង់ក្រូច ចំណុចអន្លង់យួត) ចំណុចតាំងយ៉ មានចំណុចតូចៗជាច្រើនដូចជា (ចំណុចស្រែតាស៊ូ ចំណុចអូរធូង) និងចំណុច

ទួលគ្រួស មានចំណុចតូចៗជាច្រើនដូចជា (ចំណុចអូរពងមាន់ ចំណុចទួលកកោះ)។ ចំណែកឯចំណុចស្ទឹងថ្មីមានដូចជា ចំណុចអូរស័ង្កសី ចំណុចស្វាយកោង) នៃឃុំប្រម៉ោយ ដែលរស់នៅក្នុង តំបន់គម្រោង។ លំអិតមានចែងក្នុងតារាង៥-៥២ ខាងក្រោម។

តារាង ៥-៥២: ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោងនៃភូមិស្ទឹងថ្មី ឃុំប្រម៉ោយ

(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ចំ.គ្រួសារ សរុប	ចំ.មនុស្ស សរុប	ស្ត្រី	អាយុ ១៨ ឆ្នាំឡើង	១៨ឆ្នាំឡើង ស្រី	ចំនួនមនុស្ស ក្នុងគ្រួសារ
1	ស្ទឹងថ្មី	304	1225	776	646	309	4.0
2	ដូននាគ	175	912	912	373	195	1
3	តាំងយ៉	256	1029	489	582	292	4.0
4	ទួលគ្រួស	211	887	410	431	249	4.2
5	អូរតក់ឡក់	200	898	370	495	186	4.5
6	ដំណាក់កន្ទៀង	165	783	389	415	263	4.7
7	ត្រពាំងពង្យ	93	392	173	212	87	4.2
សរុប		**1404**	**5389**	**3519**	**3154**	**1581**	**3.8**

ប្រភព: ទិន្នន័យផ្តល់ដោយអាជ្ញាធរឃុំប្រម៉ោយ។

ចំណែកឯ ប្រជាពលរដ្ឋនៅក្នុងឃុំប្រម៉ោយវិញ សរុបមាន៣១២១គ្រួសារ ចំនួនមនុស្សសរុប១០៦៨៩នាក់រស់នៅក្នុងឃុំ លម្អិតមើលតារាងខាងក្រោម៖

តារាង ៥-៥៣: ស្ថិតិប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំប្រម៉ោយ ដែលគម្រោងស្ថិតនៅ

(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

#	ឈ្មោះភូមិ	ចំនួនគ្រួសារ សរុប	ចំ.មនុស្ស សរុប	ចំ.មនុស្ស ស្រី សរុប	អាយុ ១៨ ឆ្នាំ ឡើង	ស្រី	សម្គាល់៖
1	ប្រម៉ោយ	1337	3816	1862	2166	1063	ភូមិស្ទឹងថ្មីមាន៧ ចំណុចឧបសម្ព័ន្ធទៀត
2	ទំព័រ	101	351	158	216	111	
3	ឈើទាលជ្រុំ	157	691	302	315	149	
4	ថ្មីកជ្រុំ	122	442	199	235	114	
5	ស្ទឹងថ្មី	1404	5389	3519	3154	1581	
សរុប		**3121**	**10689**	**6040**	**6086**	**3018**	

៥.២.១.៣ ប្រជាជនដែលប៉ះពាល់ដោយសារគម្រោងក្នុងអាង

ការសាងសង់អាងនៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះបានធ្វើឱ្យប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋចំនួន០១ភូមិ គឺ ភូមិស្ទឹងថ្មី ចំណុចពាក់ព័ន្ធមាន ចំណុចស្ទឹងថ្មី ដូននាគ តាំងយ៉ និងទួលគ្រួស ដែលមានប្រជាពលរដ្ឋប៉ះពាល់សរុបចំនួន ៣៤៧ គ្រួសារ ដែលមានមនុស្សសរុប ១២៦៧ នាក់ ក្នុងនោះអ្នកដែលបានមកសម្ភាសមាន ៣១៥គ្រួសារ និងមិនបានសម្ភាស៣២គ្រួសារ ដោយសារ នៅឆ្ងាយមិនអាចទាក់ទងបាន។

<u>សម្គាល់:</u> គ្រួសារប៉ះពាល់គឺដោយសារ តំបន់អាង នៃគម្រោងតែប៉ុណ្ណោះ ចំពោះតាមគន្លងខ្សែ២៣០គ.វ៉ និងតំបន់ហេដ្ឋារចនាសម្ព័ន្ធគម្រោងផ្សេងៗទៀតមិនមាន ដីប្រជាពលរដ្ឋទេ។ ជាងនេះទៅទៀត នៅក្នុងតំបន់អាងប៉ះពាល់ដល់ដំណាំ ឈើហូបផ្លែ និងដំណាំផ្សេងៗសរុបចំនួន ៧៨.៦១៨ដើម/គុម្ព ផ្ទះ៩២ខ្នងជារបស់៧៨គ្រួសារ (មានផ្ទះ៩ប្រភេទ) និងមានសំណង់ ផ្សេងៗដូចជា រោងឡាន/ម៉ូតូចំនួន៥៨ម២ រោងបាយស័ង្កសី ចំនួន២៤ម២ ស្រះទឹក ចំនួន៤.៦០៨,៤ម២ សំយ៉ាបស្លឹកចំនួន ៧៣,៨ម២ សំយ៉ាបស័ង្កសីចំនួន ៩៦៥,៨ម២ គ្រោងផ្ទះចំនួន ១៧៧,៤ម២ ទ្រុងមាន់ចំនួន ១៥ តូបចំនួន ៣ រោងចំនួន ៣៤ ជង្រុកចំនួន២ អង់តែនការពាររន្ទះចំនួន ១ ប្រព័ន្ធទុយោទឹកចំនួន ១១.៤២១ដើម សូឡាបូមទឹកចំនួន ១ និង បេតុងជើងធុងទឹកចំនួន ១ ដែលប៉ះពាល់ និងត្រូវរុះរើចេញពីក្នុងតំបន់អាងនេះផងដែរ។ ជាងនេះទៅទៀត មានដីបម្រុងរបស់អង្គភាពយុទ្ធភូមិភាគ៥ទិសទី៤ ប្រចាំស្រុកវាលវែងសរុប ១៤៤,៤១ ហ.ត និងដីបម្រុងរបស់យោធិនសម្រាប់បង្កបង្កើនផលសរុបចំនួន ១៤៥,៨៨ ហ.ត នឹងត្រូវរងផលប៉ះពាល់ដោយសារគម្រោងនេះ (សរុបដីយោធា ២៩០,២៩ហ.ត) នៅក្នុងតំបន់អាងផងដែរ។

នៅក្នុងចំណោម៣៤៧គ្រួសារ ដែលក្នុងនោះនៅចំណុចស្ទឹងថ្មី ១៩គ្រួសារ នៅចំណុចដូននាគ២០៤គ្រួសារ នៅចំណុចតាំងយ៉៤៤ និង៤៨គ្រួសារទៀតនៅចំណុចទូលគ្រូស ចំណុចទាំងនេះជាឧបសម្ព័ន្ធ របស់ចំណុចស្ទឹងថ្មី) ដែលត្រូវរុះរើ និងផ្លាស់ប្តូរលំនៅឋានទៅកាន់ទីទួលមានសុវត្ថិភាពស្ថិតនៅក្នុង ចំណុចតាំយ៉ (ទួលសុំាញ៉ាំ) នៃភូមិស្ទឹងថ្មី ដែលមាន នីវ៉ូដីខ្ពស់ជាងនីវ៉ូអាងស្តុកទឹក ពី១០,០៧ម ដល់៤១,៧ម។ (មើលផែនទីលេខ៣)។

សម្គាល់៖ *សូមបញ្ជាក់ថា ចំណុចដូននាគ ចំណុចតាំងយ៉ និង ចំណុចទូលគ្រូសនេះជាឧបសម្ព័ន្ធរបស់ភូមិស្ទឹងថ្មី ប៉ុន្តែដោយសារភូមិនេះមានផ្ទៃដីធំធេងពេក បានជាខាង អាជ្ញាធរបង្កើតអោយមានជា ចំណុចនេះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផ្នែករដ្ឋបាលប្រជាពលរដ្ឋ។ ភូមិស្ទឹងថ្មីមានចំណុច ឧបសម្ព័ន្ធដូចជា ចំណុចដូននាគ ចំណុចតាំងយ៉ ចំណុចទូលគ្រូស ចំណុចអូរតក់ឡក់ ចំណុចដំណាក់កន្សែង និងចំណុចត្រពងពង្ស។*

ជាក់ស្តែងពេលដែលក្រុមការងារ SAWAC ចុះទៅធ្វើការសិក្សាផ្ទាល់ចំពោះប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគម្រោង វារីអគ្គិសនី ស្ទឹងពោធិ៍សាត់១ ក្នុងអាងមានចំនួន៣៤៧គ្រួសារ តែក្នុងនោះគ្រួសារ ដែលត្រូវបានចូលរួមសម្ភាសមាន ៣១៥គ្រួសារ គឺស្មើនឹង៩១%។ ចំណែកឯគ្រួសារ ដែលមិនបានជួបសម្ភាសមានចំនួន ៣២គ្រួសារស្មើនឹង៩% គឺដោយសារពួកគាត់ រស់នៅតាមខេត្តផ្សេងៗដែលឆ្ងាយពីតំបន់គម្រោង។ ចំពោះ ប្រភេទផ្ទះដែលប៉ះពាល់ សូមមើលឧបសម្ព័ន្ធ៥ ប្រជាពលរដ្ឋដែលប៉ះពាល់ ដូចមានបង្ហាញក្នុងតារាង៥-៥៤ដូចខាងក្រោម ៖

តារាង ៥-៥៤: ប្រជាពលរដ្ឋដែលនឹងត្រូវប៉ះពាល់នៅក្នុងអាង (តំបន់គម្រោង)

(សិក្សាខែតុលា ដល់វិច្ឆិកា ឆ្នាំ២០១៧)

ល.រ	ឈ្មោះចំណុច	គ្រួសារសរុប (គ្រួសារ)	មនុស្សសរុប (គ្រួសារ)	សរុបគ្រួសារប៉ះពាល់ (គ្រួសារ)	អ្នកបានសម្ភាស (គ្រួសារ)	ភាគរយនៃការប៉ះពាល់ក្នុងតាមចំណុច
1	ស្ទឹងថ្មី	304	1225	23	19	8%
2	ដូននាគ	175	912	223	204	127%
3	តាំងយ៉	258	1029	46	44	18%
4	ទូលគ្រូស	211	887	55	48	26%
សរុប		**948**	**4053**	**347**	**315**	37%

តារាង ៥-៥៥: ប្រភេទផ្ទះដែលនឹងត្រូវប៉ះពាល់ដោយសារអាង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ប្រភេទផ្ទះ: 1a		ប្រភេទផ្ទះ: 1b		ប្រភេទផ្ទះ: 1c		ប្រភេទផ្ទះ: 2a		ប្រភេទផ្ទះ: 2b		ប្រភេទផ្ទះ: 2c		ប្រភេទផ្ទះ: 2d		ប្រភេទផ្ទះ: 2e		ប្រភេទផ្ទះ: 2f		សរុប ចំនួនខ្នងផ្ទះ	សរុប (ម២)
		ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)	ខ្នងផ្ទះ	(ម២)		
1	ស្ទឹងថ្មី							5	239.00			9	395.74	2	264.00					16	898.74
2	ដូននាគ	4	115.08	1	18.80	8	199.71	7	262.66			11	321.41	24	826.08	3	146.62	1	178.45	59	2,068.81
3	តាំងយ៉	2	41.55					2	44.00											4	85.55
4	ទួលគ្រោះ	1	11.40			1	42.00			2	50.00	6	146.80	3	70.40					13	320.60
សរុប		**7.00**	**168.03**	**1.00**	**18.80**	**9.00**	**241.71**	**14.00**	**545.66**	**2.00**	**50.00**	**26.00**	**863.95**	**29.00**	**1,160.48**	**3.00**	**146.62**	**1.00**	**178.45**	**92.00**	**3,373.70**

ប្រភេទផ្ទះដំបូលស្លឹក (ប្រភេទ 1)


ប្រភេទ (1a)


ប្រភេទ (1b)


ប្រភេទ (1c)

ប្រភេទផ្ទះដំបូលស័ង្កសី ឬហ្វិបប្រូ (ប្រភេទ ២)


ប្រភេទ(2a)


ប្រភេទ (2b)


ប្រភេទ (2c)


ប្រភេទ(2d)


បេភេទ (2e)


ប្រភេទ (2f)

សម្គាល់៖

- **(1A)**: គឺផ្ទះមានដំបូល និងជញ្ជាំងស្លឹក/ស្បូវ, សរសរឬស្សី/កូនឈើ, គ្មានកំរាល/រនាប,ផ្ទាល់ដី-ផុតពីដី។
- **(1B)**: គឺផ្ទះមានដំបូល និង ជញ្ជាំងស្លឹក/ស្បូវ, សរសរឬស្សី/កូនឈើ, កំរាលក្តារ, ជាន់ផ្ទាល់ដី-ផុតពីដី។
- **(1C)**: គឺផ្ទះមានដំបូលស្លឹក/ស្បូវ, ជញ្ជាំងក្តារ, សរសរឈើកំរាលក្តារ ជាផ្ទាល់ដី-ផុតពីដី។
- **(2A)**: គឺផ្ទះមានដំបូលសង្ក័សី/ហ្វីប្រូ/ប្លាស្ទិក, ជញ្ជាំងស្លឹក/ស្បូវ/កៅស៊ូតង់, សរសរកូនឈើ/ឈើ, កំរាលក្តារ, ជាន់ផ្ទាល់ដី-ផុតពីដី។
- **(2B)**: គឺផ្ទះមានដំបូលសង្ក័សី/ហ្វីប្រូ/ប្លាស្ទិក, ជញ្ជាំងសង្កសី/ហ្វីប្រូ/ឈើ(បិតមិនជិត),សរសរកូនឈើ/ឈើ, កំរាលក្តារ, ជាន់ផ្ទាល់ដី។
- **(2C)**: គឺផ្ទះមានដំបូលសង្ក័សី/ហ្វីប្រូ/ប្លាស្ទិក,ជញ្ជាំងឈើ, សរសរកូនឈើ/ឈើ, កំរាលក្តារ, ជាន់ផ្ទាល់ដី-ផុតពីដី។
- **(2D)**: គឺផ្ទះមានដំបូលសង្ក័សី/ហ្វីប្រូ/ប្លាស្ទិក,ជញ្ជាំងឈើ, សរសរឈើជ្រុង, កំរាលក្តារល្អ, ជាន់ផ្ទាល់ដី-ផុតពីដី។
- **(2E)**: ដំបូលលោហះ/ហ្វីប្រូ/ផ្លាស្ទិក, ជញ្ជាំងឈើ, សរសរឈើជ្រុងសរសរឈើជ្រុង, ជាន់ផ្ទាល់ដី-ផុតពីដី។
- **(2F)**: ដំបូលលោហះ/ហ្វីប្រូ/ផ្លាស្ទិក, ជញ្ជាំងឈើ/ថ្ម, សរសរឈើជ្រុង និង កំរាលឈើ/បេតុង, ជាន់ផ្ទាល់ដី-ផុតពីដី។

តារាង ៥-៥៦: ដំណាំ និងដើមឈើហូបផ្លែដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង
(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ២០១៧)

ល.រ	ឈ្មោះពូជដំណាំឈើ	ឯកតា	ប្រភេទ១	ប្រភេទ២	ប្រភេទ៣	សរុប
1	ស្វាយ	ដើម	4,219	219	418	4,856
2	ស្រកានាគ	គុម្ព	12	-	192	204
3	ល្ហុង	ដើម	-	-	3,248	3,248
4	មៀន	ដើម	1,534	27	540	2,101
5	ទឹកដោះ	ដើម	2	4	17	23
6	ទំពាំងបាយជូ	ដើម	10	-	-	10
7	ល្មើរ	ដើម	30	3	-	33
8	សាវម៉ាវ	ដើម	256		37	293
9	ធូរេន	ដើម	328	5	157	490
10	ចេក	គុម្ព	3,951	828	6,159	10,938
11	ខ្នុរ	ដើម	140	143	643	926
12	ត្របែក	ដើម	78	8	560	646
13	ទៀបបារាំង	ដើម	7	3	113	123
14	ទៀបបាយ	ដើម	3,056	76	166	3,298
15	ក្រូចពោធិ៍សាត់	ដើម	13,879	20,897	5,673	40,449
16	ក្រូចសើច	ដើម	6	2	3	11
17	ក្រូចថ្លុង	ដើម	99	26	420	545
18	ក្រូចឆ្មារ	ដើម	358	19	166	543
19	ម៉ាក់ប្រាង	ដើម	1	3	-	4
20	ដូង	ដើម	698	48	79	825
21	ទទឹម	ដើម	3	-	3	6
22	ចន្ទី	ដើម	821	1,206	12	2,039
23	ស្លា	ដើម	-	-	14	14

ល.រ	ឈ្មោះពូជដំណាំឈើ	ឯកតា	ប្រភេទ១	ប្រភេទ២	ប្រភេទ៣	សរុប
24	ដើមគ	ដើម	-	-	14	14
25	អំពិលទឹក	ដើម	-	-	29	29
26	អំពិល	ដើម	6	30	116	152
27	កន្ទួត	ដើម	15	6	19	40
28	ល្មុត	ដើម	-	1	-	1
29	ក្រសាំង	ដើម	-	1	3	4
30	ម្កាក់	ដើម	10	-	14	24
31	ពុទ្រា	ដើម	4	1	17	22
32	ម្រេច	ជន្លង់	1,363	-	200	1,563
33	កំពីងរាជ	ដើម	4	1	11	16
34	ក្រខុបបារាំង	ដើម	3	1	4	8
35	ត្នោត	ដើម	1	8	3	12
36	ខ្វិត	ដើម	13	7	14	34
37	ព្រីង	ដើម	10	6	9	25
38	ម្រុំ	ដើម	14	31	211	256
39	ចាន់	ដើម	2	3	-	5
40	អង្កាំ	ដើម	-	2	-	2
41	បឺរ	ដើម	9	-	10	19
42	សណ្ដែកផ្កាយ	គុម្ព	1	3	4,700	4,704
43	ឬស្សី	គុម្ព	-	-	15	15
44	ផ្សេងៗ	ដើម			48	48
	សរុប		30,943	23,618	24,057	78,618

៥.២.១.៤ ការប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដោយសារគម្រោង

ក. ការប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

ក្នុងការអភិវឌ្ឍគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ក៏នឹងធ្វើឱ្យប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួន ដូចជា៖ ផ្លូវលំចូលទៅចំណុច អន្លង់ក្រូច អន្លង់ឃ្មុត ប្រវែង១៥.៧៦៨ម ដែលផ្លូវនេះមានភាពលំបាកក្នុងការធ្វើដំណើរនៅ រដូវវស្សា។

ផ្លូវលំចូលទីចំណុច អន្លង់ក្រូច និងអន្លង់ឃ្មុត (រូបថតនៅ ឆ្នាំ ២០១៧)

ការធ្វើបច្ចុប្បន្នភាព និងសិក្សារៀបចំផែនការផ្លាស់ប្តូរលំនៅឋាន និងការតាំងលំនៅថ្មី ជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងនេះ ពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០១៧ បានបង្ហាញថា ផ្លូវជាតិលេខ ៥៥ ដែលបានបង្ហាញ ក្នុងឆ្នាំ២០១២ បានសាងសង់រួចមានរយៈកម្ពស់ខ្នងផ្លូវ ពី១៩០,២ម (អូរសង្កសី) ដល់២០០,១៧ (អូរពងមាន់) ខ្ពស់ជាងរយៈកម្ពស់តម្កល់ទឹកជាមធ្យមរបស់អាង ពី១០,២ ទៅ២០,១៧ម (នីវ៉ូអាង ១៨០ម)។ ដូចនេះ មិនមានការប៉ះពាល់ ដល់ផ្លូវជាតិលេខ ៥៥ នេះទេ។


គែមមាត់លូនៅចំណុចអូរពងមាន់ EL: 199.87m


ជាយផ្លូវនៅចំណុចអូរពងមាន់ EL: 200.31m


គែមផ្លូវលើលូនៅចំណុចអូរសង្កសី EL: 190.2m


(វាស់រយៈកម្ពស់ដោយឧបករណ៍ DGPS GNSS)

ចំណែកឯ បង្គោលអគ្គិសនី ចំនួន ៦ ដែល ឆ្នាំ ២០១២ បង្ហាញថា ស្ថិតនៅតំបន់អាង មិនមានការប៉ះពាល់ដោយសារគម្រោងនេះទេពោលគឺ មាន ៣ បង្គាលនៅចំណុចអូរពងមាន់ រយៈកម្ពស់ដីជើងបង្គោលលេខ១៩០មាន EL: 198.2m បង្គោលលេខ១៩១មាន EL: 199.34m និងបង្គោលលេខ១៩២មាន EL: 199.98m ។ ចំពោះបង្គាលអគ្គិសនីនៅចំណុចអូរសង្កសីមាន បីបង្គោល គឺរយៈកម្ពស់ដីជើងបង្គោលលេខ២២៥មាន EL: 192.49m បង្គោលលេខ២២៦មាន EL: 189.2m និងបង្គោលលេខ២២៧មាន EL: 194.98m។ ដូចនេះបង្គោលអគ្គិសនីទាំង៦ ដែលស្ថិតក្នុងតំបន់អាងមិនលិចទេ (មិនប៉ះពាល់) គឺ ខ្ពស់ជានីវ៉ូស្តុកទឹកធម្មតារបស់អាង(១៨០ម) ពី៩,២ម ដល់១៩,៩៨ម។


បង្គាលអគ្គិសនីលេខ១៩០នៅចំណុចអូរពងមាន់EL: 198.2m, លេខ១៩១EL: 199.34m, លេខ១៩២EL: 199.98m

បង្គោលអគ្គិសនីនៅចំណុចអូរសង្កែ លេខ២២៥ EL: 192.49m, លេខ២២៦EL: 189.2m, លេខ២២៧ EL: 194.98m

ខ. ការប៉ះពាល់សហគមន៍តំបន់ការពារធម្មជាតិ

យោងតាមការសិក្សាជាក់ស្តែងនៅទីតាំងគម្រោង នៅឆ្នាំ២០១២, ឆ្នាំ២០១៥ និង ឆ្នាំ២០១៧ គម្រោងនេះប៉ះពាល់ដល់ សហគមន៍តំបន់ការពារធម្មជាតិ ២កន្លែង គឺសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មីដែលមានផ្ទៃប៉ះពាល់ ៩,៨៩ ហ.ត និងសហគមន៍តំបន់ការពារធម្មជាតិស្រែពាំងដែលមានផ្ទៃប៉ះពាល់ ៣៤១,៧៣ហ.ត។

៥.២.១.៥. ខ្សែបញ្ជូនអគ្គិសនី ២៣០គ.វ៉

ចំពោះខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉ ដែលមានប្រវែងប្រមាណជា ៥គ.ម នោះគឺមិនមានប៉ះពាល់ដីរបស់ប្រជាពលរដ្ឋទេ ។ បង្គោលចំនួន១៣នោះស្ថិតនៅក្នុងដីព្រៃដែលគ្រប់គ្រងដោយរដ្ឋបាលរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

៥.២.២ ស្ថានភាពសេដ្ឋកិច្ច-សង្គម

៥.២.២.១ អាជីព និងមុខរបរ

ក. មុខរបរសំខាន់ៗ

យោងតាមទិន្នន័យដែលបានថែងក្នុងតារា៤៥ ខាងក្រោម បង្ហាញថាមុខរបរសំខាន់ៗរបស់មេគ្រួសារនៃប្រជាពលរដ្ឋដែល បានសម្ភាសនៅក្នុងតំបន់គម្រោងមានចំនួន ៧៤% ជាកសិករ ៦% ជាកម្មករ ៨% ជាមន្ត្រីរាជការ (មេឃុំ, សមាជិកឃុំ មេភូមិ ទាហ៊ាន គ្រូបង្រៀន) ១% ជាសិប្បកម្ម ១% ជាងម៉ូតូ ១% ជាបុគ្គលិកក្រុមហ៊ុន ៩%ជាអ្នកលក់ដូរ ១% ផ្សេងៗ (ចាស់ជរាដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ)។ មើលតារាងលេខ ៥-៥៧ ខាងក្រោម អំពីមុខរបរសំខាន់ៗរបស់មេគ្រួសារ។

តារាង ៥-៥៧: មុខរបររបស់មេគ្រួសារដែលបានសម្ភាសនៅក្នុងតំបន់គម្រោង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	មុខរបរសំខាន់ៗរបស់មេគ្រួសារដែលបានសម្ភាសន៍									គិតជាភាគរយ (%)								
		កសិករ	កម្មករ	រាជការ	សិប្បកម្ម	ជាងម៉ូតូ	បុគ្គលិកក្រុមហ៊ុន	លក់ដូរ	ផ្សេងៗ	សរុប	កសិករ	កម្មករ	រាជការ	សិប្បកម្ម	ជាងម៉ូតូ	បុគ្គលិកក្រុមហ៊ុន	លក់ដូរ	ផ្សេងៗ	សរុប
1	ស្ទឹងថ្មី	15				1		3		19	79%				5%		16%		100%
2	ដូនទាត	151	11	21	2	2	1	15	1	204	74%	5%	10%	1%	1%	0%	7%	0%	100%
3	តាំងយ៉	30	7	2				4	1	44	68%	16%	5%				9%	2%	100%
4	ទួលគ្រួស	36	1	2			1	7	1	48	75%	2%	4%			2%	15%	2%	100%
	សរុប	232	19	25	2	3	2	29	3	315	74%	6%	8%	1%	1%	1%	9%	1%	100%



គ. ចំណាកស្រុក

យោងតាមការសម្ភាសប្រជាពលរដ្ឋ ៣១៥គ្រួសារបានឱ្យដឹងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោងទាំង ៤ចំណុច មានតែចំណុចដូននាគ ចំណុចតាំងយ៉ និង ចំណុទួលគ្រួស ដែលមានមនុស្សចំណាកស្រុកសរុប ៣៩នាក់ ក្នុងនោះចំណាក់ស្រុកក្នុងប្រទេសមាន ៧៤% និងប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ ១៨៨,៥៣ ដុល្លារ ហើយចំណាក់ស្រុកក្រៅប្រទេសមានតែ ២៦% ចំនែកឯប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ៗ ៧៦៨ ដុល្លារក្នុងមួយខែ។ ការចំណាកស្រុករបស់ប្រជាពលរដ្ឋដោយសារភាពក្រីក្រ ដោយគ្មានលទ្ធភាពធ្វើស្រែចំការបាន ទើបប្រជាពលរដ្ឋ មួយចំនួនតូចនាំគ្នា ស្វែងរកទីផ្សាការងារ ដែលមានប្រាក់បៀវត្សរ៍ខ្ពស់ សម្រាប់ទ្រទ្រង់ជីវភាពរបស់ពួកគាត់ទៅថ្ងៃអនាគត។ (លម្អិតសូមមើលតារាងខាងក្រោម)

តារាង ៥-៦១: ចំនួនប្រជាពលរដ្ឋដែលចំណាកស្រុកតាមចំណុចនីមួយៗ (សិក្សា ខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០១៧)

ល.រ	ឈ្មោះចំណុច	ឈ្មោះភូមិ	ចំ.គ្រួសារដែលបានសម្ភាស	ចំ.អ្នកចំណាកស្រុកសរុប	ចំ.ប្រុស	ចំ.ស្រី	ចំណាកទៅធ្វើការក្នុងប្រទេស (ខេត្តបាត់ដំបង, បន្ទាយមានជ័យ, រតនគិរី, ព្រះវិហារ និង ភ្នំពេញ)				ចំណាកទៅធ្វើការក្រៅប្រទេស (ថៃ កូរ៉េ និង ជប៉ុន)			
							ចំនួនអ្នកចំណាក	គិតជា (%)	ប្រាក់ចំណូល ($/ខែ)	ប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ ($/ខែ)	ចំនួនអ្នកចំណាក	គិតជា (%)	ប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ ($/ខែ)	ប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ ($/ខែ)
1	ស្ទឹងថ្មី	ស្ទឹងថ្មី	19	0	0	0	0	0	0	0	0	0	0	0
2	ដូននាគ	ស្ទឹងថ្មី	204	22	10	12	14	64%	$ 2,490.00	$ 177.86	8	36%	$ 6,310.00	$ 788.75
3	តាំងយ៉	ស្ទឹងថ្មី	44	12	3	9	10	83%	$ 1,807.50	$ 180.75	2	17%	$ 1,370.00	$ 685.00
4	ទួលគ្រួស	ស្ទឹងថ្មី	48	5	3	2	5	100%	$ 1,170.00	$ 234.00	0	0%	0	0
សរុប			315	39	16	23	29	74%	$ 5,467.50	$ 188.53	10	26%	$ 7,680.00	$ 768.00

៥.២.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន (Land Use and Land Occupation)

យោងតាមការចុះសិក្សាដោយផ្ទាល់នៅតំបន់គម្រោងគិតចាប់ពីអាងនៅឃុំប្រម៉ោយ (មើលផែនទី២) បានបង្ហាញឱ្យ ឃើញថា ដីដែលបានប្រើប្រាស់ដោយប្រជាពលរដ្ឋសរុបមានចំនួន ប្រមាណ ២០០.៥៣ហិកតា (ដីកសិកម្ម(ស្រែ និងដីចំការ) ដីបុស្ស ដីលំនៅដ្ឋាន) ដែលប៉ះពាល់នៅក្នុងអាង។ ចំពោះដីដែលកាន់កាប់ដោយប្រជាជនទាំងនេះគឺ មានការអនុញ្ញាតិពីថ្នាក់ភូមិ ឬឃុំ ក៏ប៉ុន្តែ ប្រជាជនទាំង អស់នោះ ខ្លះមានប័ណ្ណសម្គាល់៖ សិទ្ធិកាន់កាប់អចលនវត្ថុដែលចេញដោយអគ្គនាយកសុរិយោដី និងភូមិសាស្ត្រ របស់ក្រសួងរៀប ចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងខ្លះទៀតមិនមានប័ណ្ណសម្គាល់នៅឡើយទេ។

យោងតាមច្បាប់ភូមិបាលមាត្រាលេខ៥ និង៣០ ក្នុងជំពូក៣ ខាងលើក្នុងទំព័រ៥៨ ប្រជាពលរដ្ឋដែលជាម្ចាស់ដីទាំងនេះ ត្រូវបាន ការពារដោយច្បាប់ភូមិបាលនេះ។ ក៏ប៉ុន្តែប្រជាពលរដ្ឋ ដែលរស់នៅក្នុងគម្រោង គឺជាកន្លែងអភិរក្សដែលការពារដោយរដ្ឋបាល ព្រៃឈើសហការជាមួយអង្គការអភិរក្សអន្តរជាតិCI និងដែនជំរកសត្វព្រៃភ្នំសំកុសរបស់ក្រសួងបរិស្ថាន។

ការប្រើប្រាស់ដីនៅក្នុងតំបន់គម្រោងចែកចេញជា០៤តំបន់គឺ តំបន់-១: ផ្ទៃអាង តំបន់-២: ហេដ្ឋារចនាសម្ព័ន្ធ តំបន់-៣: ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉ តំបន់-៤: (កន្លែងតាំងទីលំនៅថ្មី) តំបន់គម្រោងមានផ្ទៃដីសរុបចំនួន ៩.៣៥៥ហ.ត។ ការប្រើប្រាស់ដីតាមតំបន់និមួយៗមានលំអិត ដូចបាន ចែងក្នុង តារាង ៥-៦២ ខាងក្រោម)

តារាង ៥-៦២: ការប្រើប្រាស់ដីនៅតំបន់គម្រោង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

Zone:1 ផ្ទៃអាង (Reservoir)

No.	Landuse Type	Area in 2017 (ha)
1	ដីបុស្ស(Bos Land)	1068.4
2	ដីកសិកម្ម (Agriculture)	932.13
3	ដីលំនៅដ្ឋាន (Residential Land)	38.44
4	ដី បម្រុង យោធា(Army Land)	290.29
5	ដីឈូសឆាយដោយក្រុមហ៊ុន NEO VISION Agriculture (KOREA)	184.02
6	ព្រៃស្រោង (Evergreen Forest)	735.05
7	ព្រៃពាក់កណ្តាលស្រោង (Semi-evergreen Forest)	847.62
8	ព្រៃល្បោះ (Deciduous Forest)	4253.02
9	ផ្លូវNR55 និងផ្លូវរទេះ (Road/Oxcart Road)	73.4
10	ស្ទឹង អូរ (River/Pond)	169.03
	Sub-Total Area (Zone 1)	8591

Zone:2 ហេដ្ឋារចនាសម្ព័ន្ធ (Infrastructures)

	ផ្លូវចេញចូល (*Access Road)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	52.23
2	ព្រៃពាក់កណ្តាលស្រោង (Semi-Evergreen Forest)	1.07
	Total Area	53.3
	កន្លែងស្នាក់នៅ និងការិយាល័យ (*Camp & Office Area)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	5.37
	Total Area	5.37
	កន្លែងសាងសង់ទំនប់ ទូនេលពង្វៀងទឹក ទំនប់បណ្តោះអាសន្ន (*Dam Construction Site)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	11.68
	Total Area	11.68
	អាគារថាមពល (*Powerhouse)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	2.05
	Total Area	2.05
	អាគារថាមពលតូចនៅខាងក្រោមសំណង់បង្ហូរទឹកសម្រាប់បរិស្ថាន *(Small Powerhouse – Ecoflow Structure)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	0.56
	Total Area	0.56
	កន្លែងយកថ្ម (*Quarry Site)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	23.47
	Total Area	23.47
	កន្លែងចាក់កម្ទេចថ្មចោល មានពកន្លែង (*Spoil Field)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	10.73
	Total Area	10.73
	កន្លែងទុកដាក់សរសរ និងបង្គាលពកន្លែង (*Stock Pile)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	2.17
	Total Area	2.17
	កន្លែងសាងសង់រោងចក្រលាយបេតុង និងកិនថ្ម *(Crushing and Mixing Plant)*	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	2.29

No.	Landuse Type	Area (ha)
	Total Area	**2.29**
	កន្លែងសាងសង់ឃ្លាំងស្តុក គ្រឿងមេកានិក និងគ្រឿងបន្លាស់ ***(M/E Warehouse)***	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	6.14
	Total Area	**6.14**
	កន្លែងសាងសង់រណ្តៅទុកដាក់សំណល់រឹង២កន្លែង ***(Solid Waste Disposal Site)***	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	0.5
	Total Area	**0.5**
	កន្លែងសាងសង់រោងជាងជួសជុល២កន្លែង ***(Workshop)***	
No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	1.99
	Total Area	**1.99**
	ដីព្រៃមិនសម្អាត ***(Non Cleared Forest)***	
No.	Landuse Type	Area (ha)
1	ព្រៃរក្សាទុក តាមទូនេល និងតំបន់ផ្សេងៗ Forest (Non Cleared Forest)	431.17
2	ស្ទឹង អូរ (River/Stream)	7.66
3	ផ្លូវរទេះ (Road/Oxcart Road)	0.83
	Total Area	***439.66***
	Sub-Total Area (Zone 2)	**559.91**

Zone:3 ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ (Transmission Route)

No.	Landuse Type	Area (ha)
1	ព្រៃស្រោង (Evergreen Forest)	11.31
2	ព្រៃពាក់កណ្តាលស្រោង (Semi-evergreen Forest)	1.58
3	ផ្លូវរទេះ (Oxcart Road)	0.03
4	ស្ទឹង អូរ (River/Pond)	0.72
	Sub-Total Area (Zone 3)	**13.64**

Zone:4 កន្លែងតាំងទីលំនៅថ្មី (Relocation Site)

No.	Landuse Type	Area (ha)
1	ព្រៃល្បោះ (Deciduous Forest)	38.5
2	ផ្លូវរទេះ (Oxcart Road)	0.82
3	ដីមិនមែនព្រៃ (None Forest)	150.88
4	ស្ទឹង អូរ (River/Pond)	0.25
	Sub-Total Area (Zone 4)	**190.45**
	Total Project Area Zone1+2+3+4	**9355**

សម្គាល់៖ *តំបន់៤ គឺស្ថិតនៅ ក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ១៣,៤៥ ហ.ត និងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រម៉ោយ)១៧៧ហ.ត តំបន់នេះមានទីតាំងសមស្របសម្រាប់បង្កើតជាកន្លែងតាំងលំនៅឋានថ្មី ដោយយោងតាមការពិភាក្សាជាមួយតំណាងមេគ្រួសារប៉ះពាល់ ៣១៥នាក់ បានបញ្ជាក់ថា ប្រសិនបើតំបន់តាំងលំនៅឋាននេះនៅឆ្ងាយលើសពី ៥គ.ម ពួកគេមិនព្រមទៅនៅទេ។*

ចំណែកឯ ការប្រើប្រាស់ដីនៅក្នុងឃុំប្រម៉ោយវិញ មានចែងក្នុងតារាង៥-៦៣ ខាងក្រោម:

តារាង ៥-៦៣: ការប្រើប្រាស់ដីនៅក្នុងឃុំប្រម៉ោយ (ទិន្នន័យឆ្នាំ២០១៦)

No.	Landuse Type	Area (ha)
1	ដីលំនៅឋាន(ដីភូមិ) (Residential Land)	5500
2	ដីស្រែ (Rice Field)	2200
3	ដីចំការ (Chamkar Land)	36000
4	ដីផ្សេងៗ (Other Land)	470
	Total Area	**44170**

ប្រភព: ទិន្នន័យផ្តល់ដោយរាជធានីឃុំប្រម៉ោយ ឆ្នាំ ២០១៧។

៥.២.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (Water Supply and Sanitation)

យោងតាមការសម្ភាសផ្ទាល់របស់ក្រុមការងារ SAWAC អំពីការផ្គត់ផ្គង់ទឹក និងអនាម័យនៅក្នុងតំបន់គម្រោងបានបង្ហាញថា ប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោងពុំមានប្រព័ន្ធទឹកស្អាតសំរាប់ផ្គត់ផ្គង់ប្រើប្រាស់ទេ គឺមានតែអ្នកដែលរស់នៅតាមទីក្រុង ឬតាមទីរួមខេត្តទេដែលមានដីនៅទីនេះ ហើយមកម្តងម្កាលទេ ដូចនេះមានការប្រើប្រាស់បណ្តាញទឹកស្អាត។ ប្រភពទឹកដែលប្រជាពលរដ្ឋ យកមកប្រើប្រាស់មានដូចតទៅ៖ ទឹកស្ទឹង/អូរ ២៧% បឹង/ស្រះ/ត្រពាំង ២៨% អណ្តូងជីក/អណ្តូងលូ ៣% អណ្តូងស្នប់ ៥% ទឹកភ្លៀង ៣៦% និង ផ្សេងៗមាន ១%។ ចំពោះផ្នែកអនាម័យប្រជាពលរដ្ឋភាគច្រើនគ្មានបង្គន់ប្រើបាស់ទេ ពួកគាត់បន្ទោរបង់តាម ទីវាល/ជីកដីកប់ រឺក្នុងព្រៃ មានតែ៤៤% ប៉ុណ្ណោះ ដែលមានបង្គន់អនាម័យប្រើ ចំពោះអនាម័យផ្នែកសំរាមនៅតាមភូមិពួកគេគរចោលរួចដុតទៅតាម ផ្ទះនីមួយៗ តែមាន កន្លែងខ្លះការបោះសំរាមគ្មានសណ្តាប់ធ្នាប់ជាពិសេសកន្លែងលក់ដូរ ខ្វះការយល់ដឹងពីបញ្ហាថែរក្សាសុខភាព អនាម័យ នៅមានកំរិតនៅឡើយ។ តារាង ៥-៦៤ និង ៥-៦៥ ខាងក្រោមនេះ បង្ហាញអំពី ការផ្គត់ផ្គង់ទឹក និងការប្រើ ប្រាស់បង្គន់របស់អ្នកភូមិក្នុងតំបន់៖

តារាង ៥-៦៤: ការផ្គត់ផ្គង់ទឹក និងអនាម័យនៅជុំវិញ និងក្នុងតំបន់គម្រោង

(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧) (គិតជាគ្រួសារអ្នកបានសម្ភាស)

ល.រ	ឈ្មោះចំណុច	សរុបគ្រួសារប៉ះពាល់	ចំនួនករណីការប្រើប្រាស់	ការប្រើប្រាស់ទឹករបស់មេគ្រួសារដែលបានសម្ភាសន៍											
				អូរ/ស្ទឹង	%	បឹង/ស្រះ	%	អណ្តូងជីក /លូ	%	អណ្តូងស្នប់	%	ទឹកភ្លៀង	%	ផ្សេងៗ	%
1	ស្ទឹងថ្មី	19	108	88	81%	3	3%			2	2%	15	14%		
2	ដូនទាត	204	340	49	14%	118	35%	13	4%	17	5%	138	41%	5	1%
3	តាំងយ៉	44	79	7	9%	32	41%	3	4%	7	9%	30	38%		
4	ទួលគ្រួស	48	76	20	26%	15	20%	3	4%	4	5%	33	43%	1	1%
សរុប		315	603	164	27%	168	28%	19	3%	30	5%	216	36%	6	1%

<u>សម្គាល់</u>៖ ក្នុងមួយគ្រួសារអាចប្រើប្រាស់ប្រភពទឹក ២ ឬ ៣ ប្រភព។



តារាង ៥-៦៥: ការប្រើប្រាស់បង្គន់អនាម័យក្នុងតំបន់គម្រោង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)
(គិតជាគ្រួសារអ្នកបានសម្ភាស)

ល.រ	ឈ្មោះចំណុច	ឈ្មោះភូមិ	សរុបគ្រួសារប៉ះពាល់	មានបង្គន់	%	គ្មានបង្គន់អនាម័យ	%
1	ស្ទឹងថ្មី	ស្ទឹងថ្មី	19	12	63%	7	37%
2	ដូននាគ	ស្ទឹងថ្មី	204	92	45%	112	55%
3	តាំងយ៉	ស្ទឹងថ្មី	44	14	32%	30	68%
4	ទួលគ្រួស	ស្ទឹងថ្មី	48	20	42%	28	58%
សរុប			**315**	**138**	**44%**	**177**	**56%**



៥.២.៥ ការប្រើប្រាស់ថាមពល

ក.ថាមពលសំរាប់បំភ្លឺ

យោងតាមការសម្ភាសផ្ទាល់របស់ក្រុមការងារ SAWAC អំពីការប្រើប្រាស់ថាមពល គឺមានថាមពលសំរាប់ចំអិន និង ថាមពលសំរាប់បំភ្លឺ នៅក្នុងតំបន់គម្រោង មានការប្រើប្រាស់ថាមពលសំរាប់បំភ្លឺដូចជា ប្រើចង្កៀង/ទៀនគឺមាន ៤%. អាគុយ ៣៦% ពន្លឺព្រះអាទិត្យ ១៧% ម៉ាស៊ីនភ្លើង ១% និង បណ្តាញអគ្គិសនី ៤៣%។ លំអិតមានចែងក្នុងតារាងលេខ ៥-៦៦ និង ៥-៦៧ ខាងក្រោម ៖

តារាង ៥-៦៦: ការប្រើប្រាស់ថាមពលបំភ្លឺរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង
(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧) (គិតជាគ្រួសារអ្នកបានសម្ភាស)

ល.រ	ឈ្មោះចំណុច	សរុបគ្រួសារប៉ះពាល់	ចំនួនករណី	ចង្កៀងទៀន	%	អាគុយ	%	ពន្លឺព្រះអាទិត្យ	%	ម៉ាស៊ីនភ្លើង	%	បណ្តាញអគ្គិសនី	%
1	ស្ទឹងថ្មី	19	18			2	11%	6	33%			10	56%
2	ដូននាគ	204	204	7	3%	61	30%	36	18%			100	49%
3	តាំងយ៉	44	47	5	11%	29	62%	5	11%			8	17%
4	ទួលគ្រួស	48	49			23	47%	6	12%	2	4%	18	37%
សរុប		**315**	**318**	**12**	**4%**	**115**	**36%**	**53**	**17%**	**2**	**1%**	**136**	**43%**

ក្រាហ្វិកនៃការប្រើប្រាស់ថាមពលបំភ្លឺរបស់មេគ្រួសារដែលបានសម្ភាស
(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ២០១៧)



<u>សម្គាល់៖</u> ក្នុងមួយគ្រួសារអាចប្រើប្រាស់ប្រភេពថាមពល ២ ឬ ៣ប្រភេទ។

ខ. *ថាមពលសំរាប់ចំអិន*

យោងតាមការសម្ភាសផ្ទាល់របស់ក្រុមការងារ SAWAC អំពីការប្រើប្រាស់ថាមពលគឺមានថាមពលសំរាប់ចំអិន និងថាមពលសំរាប់បំភ្លឺ។ នៅក្នុងតំបន់គម្រោងបានបង្ហាញថា អំពីប្រភពថាមពលសំរាប់ចំអិនដែលយកមកប្រើប្រាស់មានដូចតទៅ៖ អុស/ធ្យូង ៨៦% ចង្ក្រានហ្គាស៨% និង ចង្ក្រានអគ្គិសនីមាន ៦%។

<u>តារាង ៥-៦៧</u>: ការប្រើប្រាស់ថាមពលចំអិនរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង

(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧) (គិតជាគ្រួសារអ្នកបានសម្ភាស)

ល.រ	ឈ្មោះចំណុច	សរុបគ្រួសារ ប៉ះពាល់	ចំនួនករណីការប្រើប្រាស់	ការប្រើប្រាស់ថាមពលចំអិនរបស់មេគ្រួសារដែលបានសម្ភាស					
				ចង្ក្រានអុស/ធ្យូង	%	ចង្ក្រានឧស្ម័ន	%	ចង្ក្រានអគ្គិសនី	%
1	ស្ទឹងថ្មី	19	20	18	90%	1	5%	1	5%
2	ជូននាគ	204	221	193	87%	14	6%	14	6%
3	តាំងយ៉	44	49	44	90%	4	8%	1	2%
4	ទួលគ្រួស	48	57	44	77%	10	18%	3	5%
សរុប		315	347	299	86%	29	8%	19	6%

ក្រាហ្វិកនៃការប្រើប្រាស់ថាមពលចំអិនរបស់មេគ្រួសារ ដែលបានសម្ភាស
(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ២០១៧)



<u>សម្គាល់៖</u> ក្នុងមួយគ្រួសារអាចប្រើប្រាស់ប្រភេពថាមពល ២ ឬ ៣ប្រភេទ។

៥.២.៦ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ (Road Network)

ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សម្រាប់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នេះមានទីតាំងស្ថិតនៅ ចំងាយប្រមាណ ៩៥,៥ គីឡូម៉ែត្រ ភាគបច្ចឹម ពីទីរួមខេត្តពោធិ៍សាត់ ដល់ទីតាំងទំនប់ (គិតពីផ្លូវជាតិលេខ៥ត្រង់ចំណុចប្រសព្វផ្លូវទៅក្រវាញ ដល់ស្ពានវត្ត ទទួលគ្រួស ចំងាយ ៧៩គ.ម. រួចបន្តទៅមុខ ១,៤គ.មទៀត ដល់ផ្លូវរទេះបត់ឆ្វេង និងតាមផ្លូវរទេះ ចំងាយ១៥,១ គ.ម ដល់ ទីតាំងសាងសង់ទំនប់ត្រង់ចំណុចអន្លង់ធ្មឹម)។ ទីតាំងគម្រោងនេះស្ថិតក្នុងភូមិស្ទឹងថ្មី ឃុំ ប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ សព្វថ្ងៃផ្លូវជាតិលេខ ៥៥ បានសាងសង់រួចហើយគិតពីក្រុងពោធិ៍សាត់ដល់ផ្លូវចូលតំបន់គម្រោង។ ក្រុមហ៊ុន នឹងត្រូវស្តារ និងសាងសង់ផ្លូវថ្មីសម្រាប់ចេញចូលតំបន់គម្រោងដូចមានក្នុងតារាងខាងក្រោម។ *<u>សម្គាល់</u> ប្រវែង កំណាត់ផ្លូវជាតិលេខ៥៥ ចាប់ពីផ្លូវជាតិលេខ៥ ដល់ផ្លូវក្រុមហ៊ុនគ្រោងថ្មីសម្រាប់ចូលទៅតំបន់គម្រោង ត្រង់ចំណុចអូរច្រកព្រាលគឺ ៧៤,២២គ.ម។*

<u>តារាង ៥-៦៨</u>: ការស្តារ និងធ្វើផ្លូវថ្មីចូលទៅការដ្ឋានសាង់សង់វារីអគ្គិសនីស្ទឹងពោធិ៍សាត់ គិតពីផ្លូវជាតិលេខ៥៥ ដល់ទីតាំងគម្រោង

No.	Description	Length (km)
1	R1- Access Road Line1 (from Road No.55 to Dam) in which Oxcart Road (Rehabilitation Road) = 0.87 km	12
2	R2- Access Road Line 2 (from Road Intersection Line1 to Quarry Site)	2.81
3	R3- Access Road Line 3 (from Main dam to Power House)	12.71
4	R4- Access Road Line 4 (from R3 to Spilway)	1
5	R5- Access Road Line 5 (from Coffer dam to Intake)	0.7
6	R6- Access Road Line 6 (from R3 to Adit no.2)	0.78
	Total	**30**

ផ្លូវលេខ ៥៥ និងផ្លូវលំក្នុងតំបន់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១
រូបថតថ្ងៃទី ១៤ វិច្ឆិកា ២០១៧

៥.២.៧ វិស័យអប់រំ និងសិក្សាធិការ (Education)

តាមការសិក្សា និងធ្វើការសម្ភាសជាមួយអាជ្ញាធរភូមិ ឃុំ នាយកសាលាបថមនិងប្រជាពលរដ្ឋនៅជុំវិញ និងក្នុង តំបន់គម្រោង បានរកឃើញថា មានសាលាបឋមសិក្សា០៧កន្លែងមាន ១៧ ខ្នង ដែលមានបន្ទប់សរុប ៥៤បន្ទប់ ចំនួន សិស្ស ១៥៨៤នាក់ ក្នុងនោះស្រី ៦៩៧នាក់ និងគ្រូ ៤៩នាក់ ក្នុងនោះគ្រូស្រីចំនួន ១៩នាក់ (មើលតារាងខាងក្រោម)។ តាមតារាងខាងក្រោមនេះបានបង្ហាញថា នៅសាលាបឋមសិក្សា គ្រូម្នាក់បង្រៀនសិស្សជាមធ្យម ៣២នាក់ ហើយ នៅក្នុង

ចំណុចតាំងយ៉នេះ មានអនុវិទ្យាល័យ ២ខ្នង ស្មើនឹង ១០បន្ទប់ មានសិស្សសរុប ១១៩នាក់ ក្នុងនោះស្រី ៦៣នាក់ នៅក្នុងតំបន់គម្រោងមិនមានវិទ្យាល័យទេ ប្រសិនបើចង់បន្តការសិក្សានៅវិទ្យាល័យ ពួកគេត្រូវទៅរៀននៅប្រម៉ោយដែលមានចំងាយប្រមាណជា ១៤.៥គ.ម។ ចំពោះកំរិតនៃការសិក្សារៀនសូត្ររបស់អ្នកភូមិមានកំរិតទាបនៅឡើយ។ តាមតារាងខាងក្រោម នេះបាន បង្ហាញថា មេគ្រួសារដែល បានសម្ភាសចំនួន៣១៥ គ្រួសារ ក្នុងនោះមានមេគ្រួសារ ជាបុរសចំនួន ២០៤នាក់ និង ស្ត្រី ដែលជាមេគ្រួសារចំនួន ៤២នាក់ដែលចេះអាន និងសរសេរអក្សរខ្មែរ(កំរិតវប្បធម៌ត្រឹមថ្នាក់ទី៥ ដល់ទី១២)។ បើគិតជាភាគរយ មានមេគ្រួសារ៧៨%ជាអ្នកចេះអាន និងសរសេរអក្សរខ្មែរនៃចំនួនគ្រួសារសរុបដែលបានសម្ភាស។ ចំពោះមេគ្រួសារ ដែលមិនចេះអាន និងសរសេរអក្សរខ្មែរ ជាបុរសមានចំនួន៤៥នាក់ និងស្ត្រី ២៤នាក់។ បើគិតជាភាគរយ មានមេគ្រួសារ២២% ដែលមិនចេះអាន និងសរសេរអក្សរខ្មែរ។ មើលតារាងលេខ ៥-៦៩ និង ៥-៧០ ខាងក្រោម ៖

<u>តារាង ៥-៦៩</u>: ស្ថិតិសាលាបឋមសិក្សានៅក្នុងតំបន់គម្រោង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឃុំចំណុច	កម្រិតសាលា	ចំនួនខ្នង/កន្លែង		ចំនួនបន្ទប់	ចំនួនគ្រូបង្រៀន		ចំនួនសិស្ស	
			ឈើ	ថ្ម		ប្រុស	ស្រី	ប្រុស	ស្រី
1	ស្ទឹងថ្មី	បឋមសិក្សា	1	1	8	3	6	140	136
2	ជួននាគ	បឋមសិក្សា		1	6	4	3	81	98
3	តាំងយ៉	បឋមសិក្សា	5		15	6	5	259	156
		អនុវិទ្យាល័យ		2	10	6	3	56	63
4	ទួលគ្រួស	បឋមសិក្សា	2	1	7	5		160	135
5	អូរតក់ឡក់	បឋមសិក្សា	2		2	1	2	92	43
6	ដំណាក់កន្សែង	បឋមសិក្សា	1		2	2		65	33
7	ត្រពងពង្ស	បឋមសិក្សា	1		4	3		34	33
សរុប			12	5	54	30	19	887	697

<u>តារាង ៥-៧០</u>: ស្ថិតិរបស់មេគ្រួសារក្នុងតំបន់គម្រោងដែលចេះអាន និងសរសេរអក្សរខ្មែរ

(សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ឈ្មោះភូមិស្ទឹងថ្មី	ចំនួនគ្រួសារ ប៉ះពាល់	មេគ្រួសារចេះអក្សរ			
			សរុប	ប្រុស	ស្រី	សរុប	%
1	ស្ទឹងថ្មី	ស្ទឹងថ្មី	19	17	1	18	95%
2	ជួននាគ	ស្ទឹងថ្មី	204	130	32	162	79%
3	តាំងយ៉	ស្ទឹងថ្មី	44	25	3	28	64%
4	ទួលគ្រួស	ស្ទឹងថ្មី	48	32	6	38	79%
សរុប			315	204	42	246	78%



សាលាបឋមសិក្សាដែលស្ថិតនៅក្បែរតំបន់គម្រោង
ថតនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៧

៥.២.៨ សុខភាព និងសុខុមាលភាពសាធារណៈ (Health and Public Welfare)

យោងតាមការសិក្សាអង្កេតរបស់ក្រុមការងារ SAWAC បានឱ្យដឹងថានៅក្នុងតំបន់គម្រោង ក្នុងចំណុចដូននាត ចំណុចតាំងយ៉ ចំណុចទួលគ្រួស និង ចំណុចស្ទឹងថ្មី មិនមានមណ្ឌលសុខភាពទេ។ ពេលដែលមានជម្ងឺពួកគាត់ភាគច្រើនទៅមណ្ឌលសុខភាពនៅឃុំប្រម៉ោយ ដែលមានចំងាយប្រមាណជា១២គ.ម គិតពីចំណុចតាំងយ៉ និងប្រមាណជា ៦គ.ម គិតពីចំណុចស្ទឹងថ្មី។ ក្នុងករណីមានជំងឺធ្ងន់ធ្ងរត្រូវ បញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបង្អែក ខេត្តពោធិ៍សាត់ចំងាយមធ្យមប្រមាណ៨០គ.ម (ស្ថានភាពផ្លូវបច្ចុប្បន្ននេះមានភាពងាយស្រួលក្នុងការធ្វើដំណើរ តាមផ្លូវជាតិលេខ ៥៥ ចាក់កៅស៊ូ)។ យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារ SAWAC បានរកឃើញថាសុខភាពរបស់ប្រជាពលរដ្ឋ ភាគច្រើនអ្នកនៅក្នុងតំបន់នេះ ច្រើនតែកើតមានជំងឺគ្រុនចាញ់ប្រមាណ ១៨%, ភ្នែកក្រហម ៧%, ផ្លូវដង្ហើម ៥% និងជំងឺកើតឡើងដោយសារទឹកដូចជា រាគ ១២%, សើស្បែក ៥%, គ្រុនពោះវៀន ២៨%, ព្រូន ១%, គ្រុនឈាម ៦%, និងគ្រុនក្តៅសន្ទំ ១៧% និង ថ្លើម ១%។ មើលតារាងលេខ ៥-៧១ ខាងក្រោម៖

តារាង ៥-៧១: ប្រភេទជំងឺសំខាន់ៗដែលកើតនៅក្នុងតំបន់គម្រោងនៅពេលសាងសង់ (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ករណីនៃប្រភេទជំងឺ	គ្រុនចាញ់	%	គ្រុនឈាម	%	គ្រុនសន្ធំ	%	រាគ	%	គ្រុនពោះវៀន	%	សើស្បែក	%	ព្រូន	%	ថ្លើម	%	ភ្នែកក្រហម	%	ផ្លូវដង្ហើម	%
1	ស្ទឹងថ្មី	43	7	16%	1	2%	7	16%	5	12%	12	28%	4	9%					3	7%	4	9%
2	ដូនទាត	570	98	17%	39	7%	103	18%	66	12%	163	29%	31	5%	3	1%	6	1%	40	7%	21	4%
3	តាំងយ៉	118	30	25%	7	6%	16	14%	12	10%	29	25%	4	3%			1	1%	9	8%	10	8%
4	ទួលគ្រួស	131	23	18%	7	5%	21	16%	20	15%	36	27%	8	6%			2	2%	10	8%	4	3%
សរុប		862	158	18%	54	6%	147	17%	103	12%	240	28%	47	5%	3	1%	9	1%	62	7%	39	5%



បញ្ជាក់ : មួយគ្រួសារអាចកើតជំងឺ ២ ទៅ ៣ករណី

មណ្ឌលសុខភាពប្រម៉ោយស្ថិតនៅក្បែរតំបន់គម្រោង
(រូបថតថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧)

៥.២.៩ ជំនឿសាសនា និងវប្បធម៌របស់ប្រជាពលរដ្ឋ

ក. ជំនឿសាសនា

តាមការសិក្សា និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោងបានឱ្យដឹងថាមានវត្ត០៣កន្លែង ចំនួនព្រះសង្ឃ ០១៥ អង្គ។ នៅក្នុងភូមិស្ទឹងថ្មី មានវិហារកាតូលិកចំនួន ០១ ចំនួនអ្នកកាន់សាសនាគ្រឹះ ៣% និងវិហារអ៊ីស្លាម ៧%។ លំអិតមើល តារាង ៥-៧២ ខាងក្រោម។ ចំពោះអ្នកកាន់សាសនានៅក្នុងតំបន់គម្រោងគឺព្រះពុទសាសនា ១០០%។ ប្រពៃណីវប្បធម៌របស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង គឺមានលក្ខណៈជាតិខ្មែរទាំងស្រុង ទោះបីមានជនជាតិព័ររស់នៅលាយជាមួយខ្មែរក៏ដោយ។

តារាង ៥-៧២: ចំនួនវត្តដែលមាននៅក្នុងតំបន់គម្រោង (សិក្សាខែ តុលា ដល់ វិច្ឆិកា ឆ្នាំ ២០១៧)

ល.រ	ឈ្មោះចំណុច	ឈ្មោះភូមិ	ឈ្មោះឃុំ	សាសនាព្រះពុទ្ធ			សាសនាគ្រឹះ		សាសនាអ៊ីស្លាម	
				ចំ.វត្ត	ចំ.ព្រះសង្ឃ	ចំ.អ្នកកាន់ (%)	ចំ.វិហារ	ចំ.អ្នកកាន់ (%)	ចំ.វិហារ	ចំ.អ្នកកាន់ (%)
1	ស្ទឹងថ្មី	ស្ទឹងថ្មី	ប្រម៉ោយ	1	6	90%	1	3%	1	7%
2	ដូននាគ	ស្ទឹងថ្មី	ប្រម៉ោយ							
3	តាំងយ៉	ស្ទឹងថ្មី	ប្រម៉ោយ	1	5					
4	ទួលគ្រួស	ស្ទឹងថ្មី	ប្រម៉ោយ	1	4					
សរុប				3	15	90%	1	3%	1	7%

នៅក្នុងភូមិស្ទឹងថ្មី មានជនជាតិព័រចំនួន ៤៦ គ្រួសារ តែប៉ះពាល់១០គ្រួសារប៉ុណ្ណោះ។ យោងតាមការសម្ភាសផ្ទាល់ជាមួយជនជាតិព័រចំនួន ១០គ្រួសារទាំងនេះ បានឱ្យដឹងថា ទំនៀមទំលាប់ របស់ពួកគាត់គឺដូចជា ជនជាតិខ្មែរក្នុងតំបន់ផងគម្រោងដែរ។ មិនមាន កន្លែងកប់សព ឬព្រៃអារក្ស ឬទីជំនឿ ផ្សេងៗទៀតឡើយ។ ក្រុមការងារបានសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ ក៏បានបញ្ជាក់ជនជាតិព័រ ក្នុងតំបន់គម្រោង មិនទាន់មានការតំណាត់អតសញ្ញាណច្បាស់លាស់នៅឡើយ ពោលគឺគាត់មាន ការគោរពជំនឿសាសនាព្រះពុទ្ធ និងទំនៀមទំលាប់ដូចខ្មែរផងដែរ។

វត្ត កែវ ជុំ ហៅ វត្តទួលគគោះ
ថតនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២

វត្ត បទុមសិរីរតនារាម (តាំងយ៉) ថតនៅថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ខ.សម្បត្តិវប្បធម៌

យោងតាមក្រុមសិក្សារបស់ក្រុមការងារ SAWAC បានឱ្យដឹងថានៅក្បែរ និងក្នុងតំបន់គម្រោងនោះពុំមានសំណង់ប្រវត្តិសាស្រ្ត រឺប្រាសាទបុរាណទេ ទាំងក្នុងអាង តំបន់ហេដ្ឋារចនាសម្ព័ន្ធគម្រោងផ្សេងៗ និងតំបន់តាមគន្លងខ្សែ២៣០គ.វ៉។

៤.២.១០ តំបន់ទេសចរណ៍ (Resort)

យោងតាមការសិក្សាបានបង្ហាញអោយឃើញថា នៅក្នុងតំបន់គម្រោង និងតំបន់ក្បែរខាងនៃវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ដែលស្ថិត នៅក្នុងឃុំប្រម៉ោយនេះ មានតំបន់ទេសចរណ៍ធម្មជាតិពីរកន្លែងសំខាន់ៗដូចជា ទួលលោកតាគ្រី ដែលយើងអាចឡើងទៅលើទួលខ្ពស់ហើយមើលទេសភាពដ៏ស្រស់ក្រកាលនៅជុំវិញទីនោះ, និងអន្លង់ក្រពើលោកយាយស្តើងស្ថិតនៅ ខាងឆ្វេងដៃ តាមផ្លូវទៅប្រម៉ោយ ដែលជាតំបន់អាចមានសក្តានុពលសំរាប់ទេសចរណ៍ ឬអេកូទេសចរណ៍ទៅថ្ងៃអនាគត។ ទៅថ្ងៃអនាគ ពេលដែល វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ដំណើរការបង្កើតបានជាអាងទឹក គេអាចបង្កើតជាតំបន់កំសាន្តតាមទូក មើលសត្វ ព្រៃ និងសត្វទឹក ប្រសិនបើបញ្ឈប់ ឬទប់ស្កាត់ការកាប់ឆ្ការបំផ្លាញព្រៃឈើបន្ថែមទៀត ចាប់ដីធ្វើកម្មសិទ្ធឱ្យមានប្រសិទ្ធិភាពខ្ពស់ នៅតាមតំបន់ជុំវិញ អាង និងតំបន់ព្រៃការពារក្រវាញភាគខាងត្បូង, ក្រវាញកណ្តាលរួមទាំង តំបន់ដែនជំរក សត្វព្រៃ ភ្នំសំកុស ផងដែរ។



អន្លង់ក្រពើលោកយាយស្តើង

ទួលលោកតាគ្រី

៤.២.១១ សន្និដ្ឋានជារួមលើផ្នែកសេដ្ឋកិច្ចសង្គម

យោងតាមការរៀបរាប់លំអិតខាងលើរួចមក យើងអាចធ្វើការសន្និដ្ឋានដូចតទៅ៖

- ប្រជាពលរដ្ឋសរុបចំនួន ៣៤៧គ្រួសារ មានមនុស្សសរុបចំនួន ១២៦៧នាក់ ដែលក្នុងនោះមាន ១ភូមិ ១ឃុំ ដែលក្រុមការងារបានសម្ភាសផ្ទាល់អំពីជីវភាពរស់នៅរបស់បងប្អូនដែលរស់ នៅក្នុងតំបន់គម្រោងនេះ។
- មុខរបរសំខាន់ៗរបស់មេគ្រួសារនៃប្រជាពលរដ្ឋដែល បានសម្ភាសនៅក្នុងតំបន់គម្រោងមានចំនួន ៧៤% ជាកសិករ, ៦% ជាកម្មក, ៨% ជាមន្រ្តីរាជការ (មេឃុំ, សមាជិកឃុំ, មេភូមិ, ទាហ៊ាន, គ្រូបង្រៀន) , ១% ជាសិប្បកម្ម, ១% ជាងម៉ូតូ, ១% ជាបុគ្គលិកក្រុមហ៊ុន, ៩%ជាអ្នកលក់ដូរ, ១% ផ្សេងៗ (ចាស់ជរាដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ)។
- ប្រាក់ចំណូលប្រចាំគ្រួសារក្នុងមួយខែនៅក្នុងចំណុចទាំងបួន មានកំរិតចាប់ពី $១០១-$៣០០ មាន ៤២%, ពី $៣០១-$៥០០ មាន ៣១%, និង ចាប់ពី $៥០១-$១០០០ មានតែ ២៧% ប៉ុណ្ណោះ។
- ភាពក្រីក្រ យោងតាមការប្រឹក្សាយោបល់ជាមួយអ្នកស្រី **សេក សំអាត** ជាមេឃុំ ប្រម៉ោយ សិក្សាថ្ងៃទី ២៦ តុលា ដល់ ២៩ វិច្ឆិកា ឆ្នាំ២០១៧ បានឱ្យដឹងថា អ្នកក្រីក្រដែលមានប័ណ្ណក្រីក្ររស់នៅក្នុងឃុំប្រម៉ោយមានការថយចុះ ១,៣០% ។ ចំណែកឯ ចំនួនប្រជាពលរដ្ឋដែលមាន ប័ណ្ណក្រីក្រកាលពីឆ្នាំ២០១៣ មានចំនួន ១៥,៣០% ប៉ុន្តែចំនួននេះមានការថយចុះមកត្រឹម ១,៣០% វិញក្នុងឆ្នាំ ២០១៦ ។
- ចំណាកស្រុក យោងតាមការសម្ភាសប្រជាពលរដ្ឋ ៣១៥គ្រួសារបានឱ្យដឹងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោងទាំង ៤ចំណុច មានតែចំណុចដូននាគ ចំណុចតាំងយ៉ៃ និង ចំណុទួលគ្រួស ដែលមានមនុស្សចំណាកស្រុកសរុប ៣៩នាក់ ក្នុងនោះចំណាក់ស្រុកក្នុងប្រទេសមាន ៧៤% និងប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ ១៨៨,៥៣ ដុល្លារ

ហើយចំណាក់ស្រុកក្រៅប្រទេសមានតែ ២៦% ចំនែកឯប្រាក់ចំណូលជាមធ្យមក្នុងម្នាក់ៗ ៧៦៨,០០ ដុល្លារក្នុងមួយខែ។ ការចំណាកស្រុករបស់ប្រជាពលរដ្ឋដោយសារភាពក្រីក្រ ដោយគ្មានលទ្ធភាពធ្វើស្រែចំការបាន ទើបប្រជាពលរដ្ឋមួយចំនួនតូចនាំគ្នាស្វែងរកទីផ្សារការងារ និងមានប្រាក់បៀវត្សរ៍ខ្ពស់សម្រាប់ទ្រទ្រង់ជីវភាពរបស់ពួកគាត់ទៅថ្ងៃអនាគត។

- ការប្រើប្រាស់ដីដោយប្រជាពលរដ្ឋសរុបមានចំនួនប្រមាណ ២០០.៥៣ហិកតា (ដីកសិកម្ម(ស្រែ និងដីចំការ) ដីបុស្ស ដីលំនៅដ្ឋាន) ដែលប៉ះពាល់នៅក្នុងអាង នៃតំបន់គម្រោង។
- ការប៉ះពាល់ផ្ទះរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោងសរុប ៩២ខ្នងផ្ទះ ដូចជា នៅចំណុចស្ទឹងថ្មី ១៦ខ្នងផ្ទះ ចំណុចដូនទាត ៥៩ខ្នងផ្ទះ ចំណុចតាំងយ៉ ៤ខ្នងផ្ទះ និង ចំណុចទួលគ្រួស ១៣ខ្នងផ្ទះ។ ចំណែកឯ ចំនួនក្រឡាផ្ទៃសរុបទាំងអស់ដែលប៉ះពាល់មាន ៣.៣៧៣,៧ម២។
- ការប៉ះពាល់សំណង់ផ្សេងៗ មានដូចជា រោងឡាន/ម៉ូតូ ចំនួន៥៨ម២ រោងបាយស័ង្កសី ចំនួន២៤ម២ ស្រះទឹក ចំនួន ៤.៦០៨,៤ម២ សំយ៉ាបស្លឹកចំនួន ៧៣,៨ម២ សំយ៉ាបស័ង្កសីចំនួន ៩៦៥,៨ម២ គ្រោងផ្ទះចំនួន ១៧៧,៤ម២ ទ្រុងមាន់ចំនួន ១៥ តូបចំនួន ៣ រោងចំនួន ៣៤ ជង្រុកចំនួន២ អង់តែនការពាររន្ទះចំនួន ១ ប្រព័ន្ធទុយោទឹកចំនួន ១១.៤២១ដើម សូឡាបូមទឹកចំនួន ១ និង បេតុងជើងធុងទឹកចំនួន ១ ដែលប៉ះពាល់ និងត្រូវរុះរើចេញពីក្នុងតំបន់អាងនេះផងដែរ។ ចំណែកឯ ការប៉ះពាល់ដល់ដំណាំ ឈើហូបផ្លែ និងដំណាំផ្សេងៗសរុបចំនួន ៧៨.៦១៨ដើម/គុម្ព។
- ប្រភពទឹកដែលប្រជាពលរដ្ឋ យកមកប្រើប្រាស់មានដូចតទៅ ៖ ទឹកស្ទឹង/អូរ ២៧% បឹង/ស្រះ/ត្រពាំង ២៨% អណ្តូងជីក/ អណ្តូងលូ ៣% អណ្តូងស្នប់ ៥% ទឹកភ្លៀង ៣៦% និង ផ្សេងៗមាន ១%។
- ការប្រើប្រាស់បង្គន់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់គម្រោងប្រមាណជា ៤៤ % ប្រជាពលរដ្ឋភាគច្រើនគ្មានបង្គន់ប្រើប្រាស់ទេ ពួកគាត់បន្ទោរបង់តាម ទីវាល/ជីកដីកប់ រឺក្នុងព្រៃ។
- នៅក្នុងតំបន់គម្រោង ប្រជាពលរដ្ឋភាគច្រើន ប្រមូលសំរាមគរដុតចាលនៅចំហៀង ឬក្រោយផ្ទះរៀងៗខ្លួន និងបោះចោលចូលទៅក្នុងទឹកជាដើម។
- ប្រភពថាមពលសំរាប់បំភ្លឺ នៅក្នុងតំបន់គម្រោង មានការប្រើប្រាស់ថាមពលសំរាប់បំភ្លឺដូចជា ប្រើចង្កៀង/ទៀនគឺមាន ៤% អាគុយ ៣៦% ពន្លឺព្រះអាទិត្យ ១៧% ម៉ាស៊ីនភ្លើង ១% និង បណ្តាញអគ្គិសនី ៤៣%។
- យោងតាមការសម្ភាសផ្ទាល់របស់ក្រុមការងារបានអោយដឹងថា ការប្រើប្រាស់ថាមពល គឺមានថាមពលសំរាប់ចំអិន និងថាមពលសំរាប់បំភ្លឺ។ នៅក្នុងតំបន់គម្រោងបានបង្ហាញថា អំពីប្រភពថាមពលសំរាប់ចំអិនដែលយកមកប្រើប្រាស់មានដូចតទៅៈ អុស/ធ្យូង ៨៦%, ចង្ក្រានហ្គាស៨% និង ចង្ក្រានអគ្គិសនីមាន ៦ %។
- ក្នុងតំបន់គម្រោង បានរកឃើញថា មានសាលាបឋមសិក្សា០៧កន្លែងមាន ១៧ ខ្នង ដែលមានបន្ទប់សរុប ៥៤បន្ទប់ ចំនួនសិស្ស ១៥៨៤នាក់ ក្នុងនោះស្រី ៦៩៧នាក់ និងគ្រូ ៤៩នាក់ ក្នុងនោះគ្រូស្រីចំនួន ១៩នាក់ ។ ចំនែកឯនៅសាលារៀន គ្រូម្នាក់បង្រៀនសិស្សជាមធ្យម ៣២នាក់ ហើយ នៅក្នុងចំណុចតាំងយ៉ាំនេះ មានអនុវិទ្យាល័យ ២ខ្នង ស្មើនឹង ១០បន្ទប់ មានសិស្សសរុប ១១៩នាក់ ក្នុងនោះស្រី ៦៣នាក់ នៅក្នុងតំបន់គម្រោងមិនមានវិទ្យាល័យទេ ប្រសិនបើចង់បន្តការសិក្សានៅវិទ្យាល័យ ពួកគេត្រូវទៅរៀននៅប្រម៉ោយដែលមាន ចំងាយប្រមាណជា ១៤.៥គ.ម។
- តាមការសម្ភាសចំនួន៣១៥ គ្រួសារ ក្នុងនោះមានមេគ្រួសារ ជាបុរសចំនួន ២០៤នាក់ និង ស្ត្រី ដែលជាមេគ្រួសារចំនួន ៤២នាក់ដែលចេះអាន និងសរសេរអក្សរខ្មែរ(កំរិតវប្បធម៌ត្រឹមថ្នាក់ទី៥ ដល់ទី១២)។ បើគិតជាភាគរយ មានមេគ្រួសារ៧៨%ជាអ្នកចេះអាន និងសរសេរអក្សរខ្មែរនៃចំនួនគ្រួសារសរុបដែលបានសម្ភាស។ ចំពោះមេគ្រួសារ ដែលមិនចេះអាន និងសរសេរអក្សរខ្មែរ ជាបុរសមានចំនួន៤៥នាក់ និងស្ត្រី ២៤នាក់ ។ បើគិតជាភាគរយមានមេ គ្រួសារ២២% ដែលមិនចេះអាន និងសរសេរអក្សរខ្មែរ។
- យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារ SAWAC បានរកឃើញថាសុខភាពរបស់ប្រជាពលរដ្ឋ ភាគច្រើនអ្នកនៅក្នុងតំបន់នេះ ច្រើនតែកើតមានជំងឺដូចជា គ្រុនចាញ់ប្រមាណ ១៨%, ភ្នែកក្រហម ៧%, ផ្លូវដង្ហើម ៥% និងជំងឺកើតឡើងដោយសារទឹកដូចជា រាគ ១២% . សើស្បែក ៥%, គ្រុនពោះវៀន ២៨%, ព្រូន ១%, គ្រុនឈាម ៦%, និងគ្រុនក្តៅសន្ធំ ១៧% និង ថ្លើម ១%។

- ចំពោះអ្នកកាន់សាសនានៅក្នុងតំបន់គម្រោងគឺព្រះពុទសាសនា ១០០%។ ប្រពៃណីវប្បធម៌របស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង គឺមានលក្ខណៈជាតិខ្មែរទាំងស្រុង ទោះបីមានជនជាតិព័ររស់នៅលាយជាមួយខ្មែរក៏ដោយ។
- យោងតាមការសិក្សាបានបង្ហាញអោយឃើញថានៅក្នុងតំបន់គម្រោង និងតំបន់ក្បែរខាងនៃវារីអគ្គិសនីស្ទឹងពោធិ៍សាត់ ១ ដែលស្ថិត នៅក្នុងឃុំប្រម៉ោយនេះ មានតំបន់ទេសចរណ៍ធម្មជាតិពីរកន្លែងសំខាន់ៗដូចជា ទួលលោកតាគ្រីដែលយើងអាច ឡើង ទៅ លើទួលខ្ពស់ហើយមើលទេសភាពដ៏ស្រស់ត្រកាលនៅជុំវិញទីនោះ, និងអន្លង់ក្រពើលោកយាយស្ដើងស្ថិតនៅ ខាងឆ្វេងដៃ តាមផ្លូវទៅប្រម៉ោយ ដែលជាតំបន់អាចមានសក្ដានុពលសំរាប់ទេសចរណ៍ ឬអេកូទេសចរណ៍ទៅថ្ងៃអនាគត។ ទៅថ្ងៃអនាគ ពេលដែល វារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ ដំណើរការបង្កើតបានជាអាងទឹក គេអាចបង្កើតជាតំបន់កំសាន្តតាមទូក មើលសត្វ ព្រៃ និងសត្វទឹក ប្រសិនបើបញ្ឈប់ ឬទប់ស្កាត់ការកាប់ឆ្ការបំផ្លាញព្រៃឈើបន្ថែមទៀតចាប់ដីធ្វើកម្មសិទ្ធឱ្យមានប្រសិទ្ធិភាពខ្ពស់ នៅតាមតំបន់ជុំវិញ អាង និងតំបន់ព្រៃការពារក្រវាញភាគខាងត្បូង, ក្រវាញកណ្ដាលរួមទាំង តំបន់ដែនជំរក សត្វព្រៃ ភ្នំសំកុស ផងដែរ។